សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាព ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥ ដល់ ២០១៨

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ **ក. ហ៊ីម ស៊ីវ៉ស់**
**ក. ម៉ាន ស្រស់**

សាស្ត្រាចារ្យណែនាំ
លោកបណ្ឌិត **អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាព
# ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥ ដល់ ២០១៨

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **ក. ហ៊ីម ស៊ីវ៉ស់**

**ក. ម៉ាន ស្រស់**

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហ៊ឹម ស៊ីវស៍** និងនាងខ្ញុំឈ្មោះ **ម៉ាន ស្រស់** ជានិស្សិតបរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។

## សូមគោរពថ្លែងអំណរគុណចំពោះ

- **លោកអ្នកមានគុណ** ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំទាំងពីរ ជាពិសេសលោកទាំងពីរតែងតែអប់រំទូន្មាន ដាស់តឿន និងប្រៀនប្រដៅកូនឲ្យក្លាយជាបុគ្គលដ៏ល្អ ព្រមទាំងជួយ ជម្រុញ និងលើកទឹកចិត្តដល់កូនឲ្យមានចិត្តតស៊ូព្យាយាមក្នុងការសិក្សា និងទំនុកបម្រុងកូនទាំងសម្ភារៈ និងថវិកា រហូតដល់កូនទទួលបានជោគជ័យក្នុងថ្ងៃនេះ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង** ព្រមទាំងសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ អប់រំ ផ្តល់ចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនដល់រូបនាងខ្ញុំទាំងពីររហូតទទួលបានជោគជ័យ និងឈានទៅដល់ការបញ្ចប់ការសិក្សានេះ។
- **ឯកឧត្តមអភិបាលខណ្ឌឬស្សីកែវ** និង **អភិបាលរងខណ្ឌ** ព្រមទាំងមន្ត្រីនៃសាលាខណ្ឌ ឬស្សីកែវទាំងអស់ ដែលបានផ្តល់ឯកសារជាច្រើនពាក់ព័ន្ធទៅនឹងប្រធានបទ នៃការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរ។
- លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** ដែលបានដឹកនាំ និងចង្អុលបង្ហាញពីវិធីសាស្ត្រល្អជាច្រើនដែលទាក់ទងទៅនឹងប្រធានបទសារណា ព្រមទាំងបានចំណាយពេលដ៏មានតម្លៃតាំងពីដើមរហូតដល់បញ្ចប់ក្នុងការសិក្សាស្រាវជ្រាវនេះ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងពីរសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ព្រមទាំងសូមប្រសិទ្ធពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចំពោះលោកមានគុណទាំងអស់កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលជាង៣ឆ្នាំកន្លងមក យើងខ្ញុំយល់ឃើញថា បានទទួលនូវចំណេះដឹងជាច្រើន ផ្នែកជំនាញរដ្ឋបាលសាធារណៈ ព្រមទាំងទទួលបាននូវបទពិសោធន៍ពីការសិក្សាជាច្រើន ដែលលោកគ្រូ អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យលោកបានតម្រង់ទិស និងជួយណែនាំបំភ្លឺរាល់ចម្ងល់ដែលទាក់ទងទៅនឹងបញ្ហាក្នុងការសិក្សាក៏ដូចជាក្នុងសង្គមជាច្រើន។ យ៉ាងណាមិញ នៅក្នុងឆ្នាំបញ្ចប់នៃការសិក្សារបស់យើងខ្ញុំទាំងពីរនាក់ មានចំណាប់អារម្មណ៍ទៅលើការសរសេរសៀវភៅ ដើម្បីទុកជាបទពិសោធន៍ និងដើម្បីទទួលបាននូវចំណេះដឹងបន្ថែមទៀត។ ក្នុងនោះផងដែរ យើងខ្ញុំទាំងពីរនាក់បានជ្រើសរើសប្រធានបទដែលទាក់ទងទៅនឹងមុខវិជ្ជា នីតិនគរូបនីយកម្ម និងសំណង់ ដែលយើងខ្ញុំបានសិក្សារួចមកហើយ។

យើងខ្ញុំទាំងពីរ បានជ្រើសរើសដើម្បីសរសេរជាសៀវភៅឡើងនោះគឺ "**ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨**" យើងខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទនេះឡើង គឺដោយសារតែយើងខ្ញុំទាំងពីរបានរស់នៅក្នុងខណ្ឌឫស្សីកែវ ព្រមទាំងមានចិត្តស្រឡាញ់ វិស័យនគរូបនីយកម្ម និងសំណង់ ព្រមទាំងចង់បង្ហាញពីការអភិវឌ្ឍរបស់ខណ្ឌឫស្សីកែវផ្ទាល់តែម្តង។

បន្ថែមទៅលើគោលបំណងនៃការជ្រើសរើសប្រធានបទខាងលើនេះផងដែរ យើងខ្ញុំទាំងពីរនាក់ ចង់ឲ្យប្រជាពលរដ្ឋ សាធារណៈជន ព្រមទាំងសិស្សានុសិស្ស និងនិស្សិតជំនាន់ក្រោយទាំងអស់បានជ្រួតជ្រាបពី ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពរបស់ខណ្ឌឫស្សីកែវ ព្រមទាំងយល់ដឹងពីបញ្ហាប្រឈម និងដំណោះស្រាយចំពោះបញ្ហាប្រឈម ដែលមាននៅក្នុងខណ្ឌឫស្សីកែវនេះតែម្តង។ លើសពីនេះទៅទៀត យើងខ្ញុំទាំងពីរមានបំណងចង់ឲ្យបុគ្គលគ្រប់រូប ជាពិសេសប្រជាពលរដ្ឋ និងសិស្ស-និស្សិតជំនាន់ក្រោយ បានដឹងពីការអភិវឌ្ឍក្នុងខណ្ឌឫស្សីកែវនាពេលបច្ចុប្បន្ន និងបន្តយកស្នាដៃនេះទុកជាចំណេះដឹងបន្ថែម និងសម្រាប់ធ្វើជាឯកសារពិគ្រោះបានមួយផ្នែកក្នុងការសិក្សាផងដែរ។

យើងខ្ញុំទាំងពីរជឿជាក់ថា ស្នាដៃនេះពិតជាមានចំណុចខ្វះខាត និងមានកំហុសបន្តិចបន្តួចនៅត្រង់កន្លែងណាមួយជាក់ជាពុំខានឡើយ ប៉ុន្តែយើងខ្ញុំទាំងពីរនាក់នឹងរង់ចាំទទួលរាល់ការរិះគន់ ក្នុងន័យស្ថាបនា ពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និស្សិត និងមិត្តអ្នកអាន ព្រមទាំងអ្នកស្រាវជ្រាវទាំងអស់ ដើម្បីឲ្យស្នាដៃនេះ ក្លាយទៅជាស្នាដៃមួយដ៏ល្អប្រសើរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរ សូមគោរពជូនពរដល់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និស្សិត និងមិត្តអ្នកអាន ព្រមទាំងអ្នកស្រាវជ្រាវទាំងអស់ សូមឲ្យជួបតែសេចក្តីសុខ និងសេចក្តីចម្រើន ព្រមទាំងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**សេចក្តីផ្តើម** ..... ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១
៣. គោលបំណងនៃការស្រាវជ្រាវ ..... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ..... ២
៦. វិធីសាស្រ្តស្រាវជ្រាវ ..... ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៣

**ជំពូកទី១**

**ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨**

១.១. ទិដ្ឋភាពទូទៅនៃការរៀបចំសណ្តាប់ធ្នាប់ ..... ៥
១.១.១. បុព្វហេតុដែលនាំឲ្យមានការរៀបចំ ..... ៨
១.១.១.១. កំណើនប្រជាជន ..... ៨
១.១.១.២. ភាពក្រីក្រ ..... ៩
១.១.១.៣. កម្រិតជីវភាពនៃការរស់នៅ ..... ១០
១.១.១.៤. ការដាក់សម្ពាធបរិស្ថាន ..... ១១
១.១.១.៥.គមនាគមន៍ ..... ១២
១.១.១.៦. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..... ១២
១.១.២. រចនាសម្ព័ន្ធខណ្ឌឫស្សីកែវ ..... ១៤
១.១.២.១. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ..... ១៤
១.១.២.២. រចនាសម្ព័ន្ធខណ្ឌ ..... ១៨
១.២. ទិសដៅនៃការរៀបចំខណ្ឌឫស្សីកែវ ..... ២០
១.២.១. សមិទ្ធិផលនៃការរៀបចំ ..... ២១
១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ..... ២១
១.២.១.២. ការអភិវឌ្ឍសំណង់លំនៅឋាន ..... ២៨
១.២.២. ទិសដៅនៃការអភិវឌ្ឍខណ្ឌ ..... ៣០
១.២.២.១. គោលដៅ និងយុទ្ធសាស្រ្តនៃការអភិវឌ្ឍ ..... ៣០

## ជំពូកទី២

## ការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥ ដល់ ២០១៨


២.១. ទិដ្ឋភាពទូទៅនៃការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ ....................................................៣៥

២.១.១. បុព្វហេតុដែលនាំឲ្យមានការរៀបចំ ....................................................................៣៧

២.១.១.១. តម្រូវការរបស់ប្រជាជន ....................................................................................៣៨

២.១.១.២. តម្រូវការរបស់ខណ្ឌ ........................................................................................៣៨

២.១.១.៣. ផលវិបាកនៃការបាត់បង់សោភណ្ឌភាព...............................................................៣៩

២.២. ការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ........................................................................ ៤០

២.២.១. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ............................................................................... ៤១

២.២.១.១. ការដាំដើមឈើតាមដងផ្លូវ.................................................................................. ៤២

២.២.១.២. ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ ..............................................................................៤៣

២.២.១.៣. ការរៀបចំសំណង់អគារតាមដងផ្លូវ ......................................................................៤៧

២.២.២. ការរៀបចំសោភណ្ឌភាពសម្រាប់លំអនៅពេលយប់.................................................... ៤៨

២.២.២.១. ការបំពាក់ភ្លើងតាមដងផ្លូវនៅពេលយប់................................................................. ៤៨

២.២.២.២. ការបំពាក់ភ្លើងតាមសួនច្បារ.............................................................................. ៤៨

២.២.២.៣. ការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌តាមអគារសាធារណៈ អគារឯកជន និងការកសាងកន្លែងកំសាន្តនាពេលរាត្រី.................................................................................................... ៤៩

២.៣. ការរៀបចំបរិស្ថានក្នុងខណ្ឌឫស្សីកែវ ......................................................................... ៥០

២.៣.១. ការរៀបចំកាកសំណល់ក្នុងខណ្ឌ ........................................................................... ៥០

២.៣.១.១. ការរៀបចំកន្លែងទុកដាក់កាកសំណល់ក្នុងខណ្ឌ...................................................... ៥១

២.៣.១.២. ការរៀបចំកាកសំណល់តាមទីសាធារណៈ និងឯកជន ............................................. ៥២

២.៣.២. ការវេចខ្ចប់កាកសំណល់.......................................................................................... ៥២

២.៣.២.១. ការញែក កាកសំណល់រឹង និងរាវ.......................................................................៥៣

២.៣.២.២. ការសំអាត ការទុកដាក់ និងការបញ្ចេញសំរាម ......................................................៥៣

២.៣.៣. ការចាត់វិធានការ ចំពោះការមិនគោរពច្បាប់បរិស្ថាន .................................................. ៥៤

២.៣.៣.១. ការចុះណែនាំពីបញ្ហាកាកសំណល់ ...................................................................... ៥៤

២.៣.៣.២. ការផាកពិន័យ................................................................................................. ៥៥

២.៣.៤. ការរៀបចំប្រព័ន្ធលូទឹកស្អុយក្នុងខណ្ឌ ................................................................... ៥៦

២.៣.៤.១. ការរៀបចំប្រព័ន្ធបង្ហូរទឹកស្អុយ .......................................................................... ៥៦

២.៣.៤.២. ផលប៉ះពាល់នៃការបង្ហូរទឹកស្អុយដោយមិនបានធ្វើការចម្រោះ ...........................៥៧

២.៤. បញ្ហាប្រឈម និងដំណោះស្រាយចំពោះសោភណ្ឌភាព ........ ៥៨
២.៤.១. បញ្ហាប្រឈម ........ ៥៨
២.៤.២. ដំណោះស្រាយ ........ ៥៩
**សេចក្តីសន្និដ្ឋាន** ........ ៦១
**អនុសាសន៍** ........ ៦៣
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបណ្តាប្រទេសនីមួយៗ នៅលើសាកលលោកយើងនេះ តែងតែងមានការអភិវឌ្ឍ និងមានការរៀបចំនូវសណ្តាប់ធ្នាប់ និងសោភណ្ឌភាពរបស់ប្រទេសខ្លួនជានិច្ច។ ជាក់ស្តែងបើយើងក្រឡេកមកមើលប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ គឺមានការអភិវឌ្ឍស្ទើរតែគ្រប់ទីកន្លែងនៅក្នុងប្រទេស។ នៅក្នុងការអភិវឌ្ឍនេះដែរ ប្រទេសកម្ពុជាយើងបានធ្វើការរៀបចំនូវសណ្តាប់ធ្នាប់ និងសោភណ្ឌភាពគ្រប់កន្លែង មានដូចជា ទីក្រុង ស្រុក ខណ្ឌ នានា ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់នីមួយៗនៃប្រទេស។

ព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ បានធ្វើការអភិវឌ្ឍប្រទេស ដោយស្របទៅតាមការកំណត់នៃប្លង់គោល ដែលត្រូវបានរៀបចំដោយគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ខេត្តនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន។[1] ចំពោះការអភិវឌ្ឍក្នុងខណ្ឌទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ក៏បានធ្វើការយកចិត្តទុកដាក់ទៅលើការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាព ដែលជាបញ្ហាសំខាន់ដែលខណ្ឌនីមួយៗបាននឹងកំពុងយកចិត្តទុកដាក់កែលម្អ ឲ្យមានភាពល្អប្រសើរឡើង ដោយស្របទៅតាមប្លង់គោល និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឲ្យ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានសណ្តាប់ធ្នាប់ និងសោភណ្ឌភាពល្អ ដែលកត្តាទាំងនេះហើយ ញ៉ាំងឲ្យមានការជ្រើសរើសនូវប្រធានបទ "**ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់២០១៨**" នេះឡើង។

ដោយមើលឃើញពីបញ្ហាប្រឈមនានាដែលបានកើតឡើង រាជរដ្ឋាភិបាល ព្រមទាំងគណៈអភិបាលខណ្ឌឫស្សីកែវបានធ្វើការស្តារ និងជួសជុលទៅលើប្រព័ន្ធបង្ហូរទឹក ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ រៀបចំបន្ថែមទៅលើសណ្តាប់ធ្នាប់ និងសោភណ្ឌភាពនៅក្នុងខណ្ឌ ដែលកត្តាទាំងនេះជាមូលហេតុនាំឲ្យមានការអភិវឌ្ឍនៅក្នុងខណ្ឌឫស្សីកែវ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងខណ្ឌឫស្សីកែវ គឺមានទាំងគណៈអភិបាលខណ្ឌ និងអភិបាលរងខណ្ឌ ព្រមជាមួយមន្ត្រីទាំងអស់ ដែលមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍ និងរៀបចំក្នុងខណ្ឌនេះឲ្យបានល្អ។

[1] មាត្រា៥ នៃច្បាប់ស្តីពី "ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់"

ទោះជាយ៉ាងនេះក្តី ដើម្បីឲ្យសិស្សនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណៈជនទាំងអស់បានយល់ដឹងច្បាស់ពីខណ្ឌឫស្សីកែវនេះ គឺបានចោទជាសំនួរថា **"តើគួរធ្វើយ៉ាងដូចម្តេចដើម្បីឲ្យខណ្ឌឫស្សីកែវមានសណ្តាប់ធ្នាប់ និងសោភណ្ឌភាពល្អ? "តើខណ្ឌឫស្សីកែវមានការទិសដៅអភិវឌ្ឍន៍អ្វីខ្លះនាពេលអនាគត"? តើខណ្ឌមានដំណោះស្រាយអ្វីខ្លះ ចំពោះបញ្ហាប្រឈមដែលកើតមានក្នុងខណ្ឌ?**

ដូចនេះនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់ប្រាកដជាយល់ដឹងពីការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពក្នុងខណ្ឌឫស្សីកែវ ថែមទាំងអស់អាចយកស្នាដៃស្រាវជ្រាវមួយនេះទៅធ្វើជាឯកសារពិគ្រោះ និងជំនួយដល់ស្មារតីបានទៀតផង។

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការស្រាវជ្រាវទាំងអស់ គឺសុទ្ធសឹងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ដោយឡែក ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺចង់ឲ្យនិស្សិត សាធារណជន បានយល់ដឹងពីការអភិវឌ្ឍនៃ ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពនៃខណ្ឌនៅក្នុងប្រទេសរបស់ខ្លួន។ ជាពិសេស គឺចង់ឲ្យនិស្សិតជំនាន់ក្រោយៗបានយល់ដឹង និងជ្រួតជ្រាបច្បាស់ពីការអភិវឌ្ឍ ព្រមទាំងអាចយកឯកសារនេះសម្រាប់ជាជំនួយស្មារតីបន្ថែមលើការស្រាវជ្រាវរបស់ខ្លួន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទាំងអស់ គឺតែងតែមានដែនកំណត់របស់ខ្លួន។ ដូច្នេះអ្វីដែលទាក់ទងនឹងប្រធានបទ **"ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨"** គឺយើងនឹងធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើអ្វីដែលទាក់ទង នឹងសណ្តាប់ធ្នាប់ និងសោភណ្ឌភាពក្នុងខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨ តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ គឺមានសារៈសំខាន់ដល់និស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ សាធារណជនទាំងអស់ អាចជួយសម្រួលដល់ការអភិវឌ្ឍ ឬការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពក្នុងខណ្ឌឫស្សីកែវទៀតផង។ ជាពិសសមិត្តអ្នកអាន សាធារណជនទាំងអស់ អាចធ្វើការផ្សព្វផ្សាយពីការអភិវឌ្ឍខណ្ឌឫស្សីកែវយកទៅអភិវឌ្ឍន៍ក្នុងខណ្ឌដទៃទៀត ឬក្នុងស្រុកណាមួយបានថែមទៀត។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ **"ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់២០១៨"** គឺធ្វើបកស្រាយ និងបំភ្លឺទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា

មានបញ្ហាប្រឈម និងដំណោះស្រាយរបស់ខណ្ឌព្រមទាំងឯកសារ ដែលទទួលបានពីសាលាខណ្ឌឫស្សីកែវ ដោយលោកអភិបាលខណ្ឌបានអនុញ្ញាតិ និងផ្តល់ឲ្យ ព្រមទាំងឯកសារមួយចំនួនទៀតដែលបានពីគេហទំព័រផ្សេងៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះដែរ គឺបានធ្វើការបែងចែកជា២ជំពូក ក្នុងនោះមានៈ

**១. ជំពូកទី១** ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨ ហើយជំពូកទី១នេះបានចែកចេញជាពីរផ្នែក ដោយផ្នែកទី១ បកស្រាយអំពីទិដ្ឋភាពទូទៅ រីឯផ្នែកទី២វិញ បកស្រាយអំពីទិសដៅនៃការរៀបចំខណ្ឌឫស្សីកែវ។

**២. ជំពូកទី២** ការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨ ដែលជំពូកទី២នេះបានបែងចែកជា២ផ្នែក ដោយផ្នែកទី១ បកស្រាយអំពីទិដ្ឋភាពទូទៅនៃការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ ចំណែកឯផ្នែកទី២វិញ បកស្រាយអំពី ការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ។

# ជំពូកទី១
# ការរៀបចំសណ្ដាប់ធ្នាប់
# ខណ្ឌឫស្សីកែវ
# ឆ្នាំ២០១៥ ដល់២០១៨

# ជំពូកទី១

## ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់ ២០១៨

បើយោងតាមការវិភាគពីស្ថានភាព ក៏ដូចជាបញ្ហាសណ្តាប់ធ្នាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះសរបញ្ជាក់ឲ្យឃើញថា ការរៀបចំសណ្តាប់ធ្នាប់នៅក្នុងខណ្ឌឫស្សីកែវនៅតាមទីសាធារណៈត្រូវបានសាលាខណ្ឌធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយសាលាខណ្ឌបានធ្វើការរក្សាសន្តិសុខសុវត្ថិភាព ព្រមទាំងសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋក្នុងការរស់នៅផងដែរ។ ប៉ុន្តែ បញ្ហាសណ្តាប់ធ្នាប់ក្នុងខណ្ឌឫស្សីកែវ ក៏នៅតែជាបញ្ហាចោទសម្រាប់សាលាខណ្ឌនៅឡើយ ដោយសារតែប្រជាពលរដ្ឋមួយចំនួនគាត់មិនបានយល់ដឹងច្បាស់ពីច្បាប់ និងប្រជាពលរដ្ឋមួយចំនួនបានបំពានច្បាប់ ដែលជាហេតុធ្វើឲ្យសណ្តាប់ធ្នាប់ក្នុងខណ្ឌមិនទាន់មានភាពល្អប្រសើរ។ បញ្ហាទាំងនេះហើយ គឺជាបញ្ហាចោទដ៏សំខាន់មួយ ដែលអាជ្ញាធរខណ្ឌគួរគប្បីធ្វើការដោះស្រាយបញ្ហាឲ្យទាន់សភាពការណ៍ ដើម្បីការពារនូវសណ្តាប់ធ្នាប់ក្នុងខណ្ឌឲ្យមានភាពល្អប្រសើរឡើង។

ម្យ៉ាងវិញទៀត មុននឹងឈានដល់ការរៀបចំ ឬការអភិវឌ្ឍត្រូវពិនិត្យមើលទៅលើប្លង់គោលជាមុនសិនក្នុងការរៀបចំសណ្តាប់ធ្នាប់ឲ្យមានរបៀបរៀបរយ។

ប្លង់គោលជាឯកសារ ឬជាគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍរាជធានីដល់ឆ្នាំ២០២០។ ប្លង់គោល ជាប្លង់គ្រឹះ និងជាប្លង់តម្រង់ទិសក្នុងការរៀបចំបែងចែក កំណត់ផ្ទៃដី សម្រាប់តំបន់សំណង់ តំបន់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍។[2]

ដូចមានក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រង់មាត្រា៧ បានចែងថាដីអាចសាងសង់បាន ឬសាងសង់មិនបានមានដូចតទៅ ៖

- តំបន់សម្រាប់ការពារជាតិ
- តំបន់សម្រាប់កសិកម្ម
- តំបន់សម្រាប់ពាណិជ្ជកម្ម
- តំបន់សម្រាប់ឧស្សាហកម្ម
- តំបន់សម្រាប់សិប្បកម្ម
- តំបន់សម្រាប់វប្បធម៌
- តំបន់សម្រាប់ទេសចរណ៍
- តំបន់សម្រាប់សាសនា
- តំបន់សម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ។[3]

[2] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី១៨៤

[3] មាត្រា៧ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤

## ១.១. ទិដ្ឋភាពទូទៅនៃការរៀបចំសណ្ដាប់ធ្នាប់

ទីតាំងភូមិសាស្ត្រនៅសម័យមហានគរ មានឥទ្ធិពលធំធេងដល់កំណាកំណើតការលូតលាស់ របាយធនធានធម្មជាតិ ប្រជាជន សេដ្ឋកិច្ច វប្បធម៌...ដែលទឹកដីនេះបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធិជាមួយភូមិភាគអាស៊ីអាគ្នេយ៍ ទាំងដីគោក និងដីកោះ លើលក្ខខណ្ឌធម្មជាតិ និងប្រវត្តិសាស្ត្រ។

នៅដើមសតវត្សទី១ នៃគ្រិស្តសករាជ តំបន់នេះជាដែនដីសុវណ្ណភូមិ មានមនុស្សខ្មែរតាំងទីរស់នៅពីយូរលង់ណាស់មកហើយ ដោយបង្កើតបានជាសង្គមមានរបៀបរៀបចំច្បាប់រដ្ឋច្បាស់លាស់ ដឹកនាំដោយស្ត្រីសោយរាជ្យឈ្មោះព្រះនាងសោមា តាមភាសាចិនហៅថាព្រះនាងលីវយី នៅនគរកោះគោកធ្លក ដែលមានអង្គរបុរី ជារាជធានីទី១ នៃអាណាចក្រភ្នំ ឬនគរភ្នំ(ខេត្តតាកែវសព្វថ្ងៃ)។ ព្រះនាងបានរៀបអភិសេកជាមួយព្រាហ្មណ៍ ដែលមកពីប្រទេសឥណ្ឌា ឈ្មោះព្រះបាទកៅណ្ឌិន្យ តាមភាសាចិនហៅថាព្រះបាទហ៊ុនទៀន។ អាណាចក្រភ្នំ ឬនគរភ្នំមានអាយុចាប់ពី សតវត្សទី១ ដល់សតវត្សទី៦ តាមភាសាចិនហៅថា ហ្វូណន។[4] ម៉្យាងវិញទៀត នៅសម័យ អាណាចក្រភ្នំមានឈ្មោះថ្កុំថ្កើងរុងរឿង ក៏ដោយសារតែយល់នូវសារៈសំខាន់នៃសេដ្ឋកិច្ច។ កសិកម្មមានការរីកចម្រើនលូតលាស់ខ្លាំង ហើយអ្នកស្រុកចេះជីកព្រែកខ្វាត់ខ្វែង ដែលមានសល់ដានរហូតដល់សព្វថ្ងៃនេះនៅត្រង់កម្ពុជាក្រោមខាងលិច។ តាមយោបល់អ្នកជំនាញការ បណ្ដាញព្រែកជីកនេះ គេបានកសាងឡើងសម្រាប់បង្ហូរទឹកជំនន់ទន្លេមេគង្គចេញផងសម្រាប់លាងសម្អាតឲ្យស្អាតនៅទីភក់ល្បាប់ និងបន្សាបអំបិលដែលជ្រាបទៅក្នុងដីផង សម្រាប់ជាគមនាគមន៍រវាងទីក្រុងទាំងឡាយ និងសម្រាប់ឲ្យសំពៅ និងទូកឆ្លងកាត់ទៅបាន ពីសមុទ្រចិនទៅឈូងសមុទ្រសៀម។[5] បន្ទាប់ពីសម័យនគរភ្នំ នៅចន្លោះពីស.វទី៦ ដល់ស.វទី៨ ខ្មែរភាគខាងជើងបានបង្កើតរដ្ឋមួយឈ្មោះថា អាណាចក្រចេនណា ខ្មែរធ្លាប់មានជោគជ័យក្នុងនយោបាយទឹកតាំងពីសម័យអាណាចក្រភ្នំមកម្ល៉េះ ចូលមកដល់សម័យចេនឡា នយោបាយទឹកមានសភាពរឹតតែប្រសើរឡើងថែមទៀត ជាហេតុញុាំងឲ្យមានការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹង និងមានកសិកម្មលូតលាស់រីកចម្រើនជាលំដាប់។[6]

បន្តមកដល់សម័យអង្គរ ចាប់ផ្ដើមពីគ.ស៨០២ គឺជាឆ្នាំដែលព្រះបាទជ័យវរ្ម័នទី២ ធ្វើពិធីទេវរាជនៅលើភ្នំគូលេន ហើយចប់នៅគ.ស ១៤៣១ ជាឆ្នាំដែលព្រះបាទពញាយ៉ាតបានចាកចោលក្រុងអង្គរបានសេចក្ដីថា រយៈពេល ៦២៩ឆ្នាំ គឺជាសម័យកាលមួយដែលប្រទេសខ្មែរ បានស្គាល់នូវភាពរុងរឿងក្នុង

---

[4] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វីឌី ត្រង់ទំព័រទី៥ និង៦

[5] សៀវភៅប្រវត្តិសាស្ត្រខ្មែរភាគទី១ បោះពុម្ពលើកទី១ គ.ស១៩៧៣ ព.ស ២៥១៧ ដោយសាស្ត្រាចារ្យ ត្រឹង ងា ត្រង់ទំព័រទី៦២ និង៦៣

[6] សៀវភៅប្រវត្តិសាស្ត្រខ្មែរភាគទី១ បោះពុម្ពលើកទី១ គ.ស១៩៧៣ ព.ស ២៥១៧ ដោយសាស្ត្រាចារ្យ ត្រឹង ងា ត្រង់ទំព័រទី៧៨

ប្រវត្តិសាស្ត្រមនុស្សលោក។ ព្រះបាទយសោវរ្ម័នទី១ គឺជាស្ថាបនិកដំបូងគេក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលបានកសាងទីក្រុងថ្មី គឺទីក្រុងអង្គរ។ បុព្វបុរសខ្មែរជាមនុស្សមានគំនិតច្នៃប្រឌិត ដោយបានរៀបចំបុរី និងបានធ្វើនយោបាយកសិកម្ម ផ្អែកទៅលើរបៀបចាត់ប្រព័ន្ធទឹកជា មូលដ្ឋាន។ ការរៀបចំប្រទេសដែលបានធ្វើឡើង នៅរាជព្រះបាទឥន្ទ្រវរ្ម័ន អាស្រ័យដោយស្ថានភាព និងអំណាចរបស់ប្រទេសមានស្ថិរភាព មានកម្លាំងគ្រប់គ្រាន់ រួមនឹងជំនឿសាសនាដែលមានលក្ខណៈមុតមាំ។ នយោបាយទឹកនៅជំនាន់ព្រះបាទឥន្ទ្រវរ្ម័ន គឺមានលក្ខណៈផុសផុលខ្លាំងក្លា មានព្រែកជីកខ្វាត់ខ្វែងជាប្រព័ន្ធមួយស្អែកស្កះ និងមានបារាយណ៍ ព្រមទាំងគូរទឹកផ្សេងៗជាគោល។ ហេតុផលទាំងនេះ គឺបានធ្វើឲ្យសេដ្ឋកិច្ចប្រទេសមានការរីកចម្រើនឡើង សង្គមមានស្ថិរភាព អំណាចរឹងមាំ និងបានធ្វើឲ្យអាណាចក្រខ្មែរថ្កុំថ្កើងរុងរឿង ដោយសារតែការរៀបចំនគរនៅពេលនោះមានលក្ខណៈពិសេសដែលប្រទេសនេះ បានផ្តោតការយកចិត្តទុកដាក់លើនយោបាយទឹក។ ក្សត្រគ្រងរាជនៅសម័យអង្គរក្នុងរជ្ជកាល នៃអង្គព្រះមហាក្សត្រនីមួយៗ ក៏ដូចប្រជារាស្ត្រទូទាំងប្រទេសដែរ គឺមានបំណងចង់ធ្វើឲ្យទីក្រុងកាន់តែមានការរីកចម្រើនលើសដើមជានិច្ច។ តាមរយៈសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុក និងស្លាកស្នាមដែលនៅសេសសល់រហូតដល់សព្វថ្ងៃ។[7]

ម្យ៉ាងវិញទៀតលក្ខណៈពិសេសនៃសង្គមខ្មែរ គឺការកសាងប្រព័ន្ធបង្ហូរទឹក ដើម្បីស្រោចស្រពស្រែចំការ តាមរយៈបារាយណ៍ធំៗ ដែលអាចផ្ទុកទឹកបានចំនួនច្រើនអតិបរមា។ ដូច្នេះ ការរីកចម្រើនខាងវិស័យបច្ចេកទេស ដែលគេឲ្យឈ្មោះថានយោបាយទឹក បាននាំមកនូវផលិតកម្មយ៉ាងល្អប្រសើរ ដែលជាហេតុនាំឲ្យមានការរីកដុះដាលនៃប្រជាជនខ្មែរ ក្នុងចក្រភពមហានគរ ហើយទន្ទឹមនឹងនេះ ប្រាង្គប្រាសាទជាច្រើន ក៏ត្រូវបានកសាងឡើងជាលំដាប់លំដោយផងដែរ។[8]

ជាបន្តបន្ទាប់មកដល់ស.វទី១៥ ក្នុងអំឡុងរជ្ជកាលព្រះបាទស្រីសុរិយោព័រ(ពញាយ៉ាត) គឺនៅពេលដែលព្រះអង្គបានបោះចោលរាជធានីអង្គរ ហើយមកសាងសង់រាជធានីថ្មីមួយទៀតនៅទួលបាសានក្នុងខេត្តស្រីសឈរ ដែលសព្វថ្ងៃត្រូវបានគេស្គាល់ថា ជាស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ព្រះអង្គបានគង់នៅទីនោះបានតែមួយឆ្នាំគត់ ដោយសារតែមានទឹកជំនន់រាល់រដូវវស្សា ព្រះអង្គបានផ្លាស់ប្តូររាជធានី ហើយបានមកសាងសង់រាជធានីថ្មីមួយទៀតតាមបណ្តោយមាត់ទន្លេចតុមុខ(ទន្លេមុខបួន) នៅក្នុងឆ្នាំ១៤៣៤ ដែលសព្វថ្ងៃជារាជធានីភ្នំពេញ។ ការកសាងព្រះបរមរាជវាំងនៅរាជធានីភ្នំពេញមានពីរលើកទី១ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាតក្នុងស.វទី១៥ និងលើកទី២ក្នុងរជ្ជកាលព្រះបាទនរោត្តមក្នុងស.វទី១៩ ទើបបិតបេរ មូលហេតុដែលមានការកសាងព្រះបរមរាជវាំងចំនួន២លើកបែបនេះដោយសារតែការកសាងលើកទី១នៅ(ឆ្នាំ១៤៣៤-១៤៣៧) រាជវាំងត្រូវបានផ្លាស់ប្តូរទៅអង្គរវិញ ក្រោយពីទៅអង្គរ

[7] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វ៉ៃ ត្រង់ទំព័រទី៨,៩,១០

[8] សៀវភៅប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដោយបណ្ឌិត មីសែល ត្រាណេ ឆ្នាំ២០០៦

ទៅពោធិ៍សាត់ រួចទៅបរិបូរណ៍ បន្ទាប់មកទៅលង្វែកហើយទៅឧត្តុង្គ។ បន្ទាប់ពីឧដុង្គ រាជវាំងបានត្រលប់មកសាងសង់ជាលើកទី២នៅរាជធានីភ្នំពេញ។[9] រីឯនៅសម័យឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ ដែលជាសម័យអាណានិគមបារាំង ប្លង់រាជធានីភ្នំពេញ និងប្លង់ទីក្រុងតាមខេត្តនានាមានរាងជាក្រឡាចត្រង្គ គេសង្កេតឃើញមានសំណង់បុរាណត្រូវអភិរក្សមួយចំនួន ដែលនៅសេសសល់រហូតដល់សព្វថ្ងៃ និងមានតម្លៃជាប្រវត្តិសាស្ត្រចាំបាច់ត្រូវថែរក្សា។ សំណង់ទាំងនេះច្រើនជាសំណង់អគាររដ្ឋបាលនានា ឬជាលំនៅឋានរបស់ មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជាជនជាតិបារាំង ដែលមកធ្វើការនៅស្រុកខ្មែរ និងច្រើនមានទម្រង់ជាអគារ ឬសំណង់យកតាមលំនាំវប្បធម៌បែបអឺរ៉ុប នៅសម័យក្លាស៊ីក ឬណេអូក្លាស៊ីក ដូចជានៅតាមតំបន់រដ្ឋបាល មានសាលាខេត្ត សាលាក្រុងភ្នំពេញ និងនៅរាជធានីភ្នំពេញ គេសង្កេតឃើញមាននៅតំបន់រដ្ឋបាល និងនៅសង្កាត់វត្តភ្នំ ដែលជាតំបន់លំនៅឋានរបស់មន្ត្រីជាន់ខ្ពស់បារាំង។[10] បន្តពីឆ្នាំ១៩៥៣ ដល់១៩៧០ កម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំងនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ក្រោយពេលដែលប្រទេសកម្ពុជាបានទទួលឯករាជ្យ កម្ពុជាមានការរីកចម្រើនឡើងជាពិសេស នៅទស្សវត្សឆ្នាំទី៦០។ ទន្ទឹមនឹងដំណើរនគរូបនីយកម្ម គេសង្កេតឃើញមាន សំណង់ស្ថាបត្យកម្មបានកើតឡើង និងរីកដុះដាលនៅតាមរាជធានី ទីក្រុង ទីរួមខេត្តនានា។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក៏បានបន្តពង្រីក និងមានការចាក់ដីលុបបំពេញបឹង និងតំបន់នានា មានចំការមន បឹងកេងកង...ដើម្បីអភិវឌ្ឍន៍ទីក្រុងភ្នំពេញ ដែលពេលនោះរាជធានី ឬក្រុងភ្នំពេញមានខ្សែរក្រវ៉ាត់ក្រុងនៅតូច។ នៅសម័យនោះ សំណង់ស្ថាបត្យកម្មជាតិដែលលេចធ្លោគឺ ពហុកីឡាដ្ឋានជាតិ បានសាងសង់ឡើងសម្រាប់ប្រារព្ធក្នុងពិធីប្រកួតកីឡាហ្គាណឺហ្វូលើកទីមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជានៅកម្ពុជានាឆ្នាំ១៩៦៦ ដែលបានធ្វើឲ្យតំបន់នេះមានសំណង់ថ្មីចាប់ផ្តើមឡើងជាបន្តបន្ទាប់ ជំនួសឲ្យផ្ទះឈើ និងធ្វើឲ្យតំបន់នេះកាន់តែមានភាពអ៊ូអរឡើង ព្រោះស្ថិតនៅជិតផ្សារអូឡាំពិច ដែលជាផ្សារលក់ទំនិញសម្រាប់នាំចេញទៅខេត្តនានា។ ផ្សារអូឡាំពិចបច្ចុប្បន្នជាសំណង់ ដែលទើបបានសាងសង់ឡើងវិញលើទីតាំងចាស់ និងបានដាក់ឲ្យប្រើប្រាស់ក្នុងអំឡុងឆ្នាំ១៩៩៤។[11] បន្តទៅមើលសម័យប៉ុលពតវិញ ក្នុងការដែលខ្មែរក្រហមចូលមកកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញចោលទីក្រុង គ្រប់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លិចបំផ្លាញ ធ្ងន់ធ្ងរបំផុតជារួមក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ទីក្រុងភ្នំពេញបានក្លាយទៅជាទីក្រុងខ្មោច។ ប៉ុន្តែក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនបានវិលត្រឡប់មករស់នៅស្រុកកំណើត

---

[9] គេហទំព័ររបស់សាលារាជធានីភ្នំពេញ www.phnompenh.gov.kh

[10] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វ៉ន្នី ត្រង់ទំព័រទី៨៨,៨៩

[11] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វ៉ន្នី ត្រង់ទំព័រទី៩៥, ៩៦, ៩៧

វិញក្នុងស្ថានភាពទប់ស្កាត់ ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ផង ការស្តារ និងការកសាងប្រទេសផង រដ្ឋអំណាច និងប្រជាជន បានរួមគ្នាជំនះរាល់ការលំបាកគ្រប់យ៉ាងជាបន្តបន្ទាប់ និងបានកែប្រែស្ថានភាពទីក្រុង រាជធានីភ្នំពេញឲ្យកាន់តែស្រស់ស្អាត។ រាជធានីភ្នំពេញសព្វថ្ងៃ ជាផ្លូវដ៏វែងឆ្ងាយឆ្ពោះទៅកាន់រាជធានីភ្នំពេញ ដែលមានសុខសន្តិភាព និងភាពរីកចម្រើន។[12]

### ១.១.១. បុព្វហេតុដែលនាំឲ្យមានការរៀបចំ

ជាទូទៅរាល់ការអភិវឌ្ឍទាំងឡាយ ឬធ្វើអ្វីមួយបានទាល់តែមានការរៀបចំនូវគម្រោងដើម្បីរៀបចំ ឬធ្វើផែនការជាមុនសិន។ ទន្ទឹមនឹងនេះ មុននឹងឈានទៅដល់ការរៀបចំ ឬអភិវឌ្ឍន៍អ្វីមួយ គឺវាបណ្តាលមកពីមានភាពខ្វះចន្លោះ ដែលជាហេតុនាំឲ្យកើតមានឡើងនូវបញ្ហាផ្សេងៗផងដែរ។ តួយ៉ាង បើយើងធ្វើការក្រឡេកទៅមើលបណ្តាតំបន់នានា ដូចជា ភូមិ ឃុំ ស្រុក ខណ្ឌ ក្នុងប្រទេសនានា ក៏ដូចជាប្រទេសកម្ពុជាយើង តែងតែមានការរៀបចំនូវគម្រោង ឬផែនការសកម្មភាពអភិវឌ្ឍន៍នានាទៅតាមតំបន់ដែលជួបនូវបញ្ហាខ្វះខាត ដែលត្រូវតែមានការរៀបចំឲ្យល្អប្រសើរ។

ដូច្នេះហើយ ផលដែលត្រលប់មកពីការរៀបចំមានដូចជា ផ្លូវថ្នល់ ប្រព័ន្ធលូ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ (រថយន្តក្រុងសាធារណៈ) ការបំពាក់ភ្លើងសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺផ្លូវសាធារណៈ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ជាពិសេស ប្រកបដោយ អនាម័យ សន្តិសុខ សៀមស្ងាត់ សម្រាប់ប្រជាពលរដ្ឋ។[13] លទ្ធផលនៃការរៀបចំទាំងនេះហើយ គឺជាបញ្ហាដែលគួរគប្បីធ្វើការយកចិត្តទុកដាក់រៀបចំថែរក្សា ការពារ និងអភិវឌ្ឍន៍ជារៀងរាល់ឆ្នាំ ដើម្បីធ្វើឲ្យទីក្រុងមានសណ្តាប់ធ្នាប់ល្អ។ ការរៀបចំក្រុង គឺជាកត្តាមួយដែលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវធ្វើការយកចិត្តទុកដាក់ឲ្យបានម៉ត់ចត់ ហើយបុព្វហេតុនៃការរៀបចំក្រុងមានកត្តាមួយចំនួនដូចខាងក្រោម៖

#### ១.១.១.១. កំណើនប្រជាជន

ជាទូទៅ មាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗ៖ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ បានធ្វើឲ្យមានការកើនឡើងយ៉ាងលឿនរហ័សនៃចំនួនប្រជាជន ចំណែកកំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែក ប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះ ជាទីជនបទគ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។[14]

---

[12] គេហទំព័ររបស់សាលារាជធានីភ្នំពេញ www.phnompenh.gov.kh ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

[13] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី១

[14] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី៦

បញ្ហានៃការកើនឡើងប្រជាជន គឺជាកត្តាមួយនៅក្នុងចំណោមកត្តាជាច្រើនដែលជម្រុញឲ្យមានការរៀបចំទីក្រុង។ កត្តាកំណើនប្រជាជនក្នុងទីក្រុង ដែលកំណើនជាលក្ខណៈធម្មជាតិដែលបង្កកំណើតដោយមនុស្ស រីឯកំណើនដោយសារចំណាកស្រុកពីជនបទ គឺជាការកើនឡើងដោយសារការធ្វើចំណាកស្រុករបស់ប្រជាជនពីទីជនបទ ឬតាមបណ្ដាខេត្តផ្សេងៗមកកាន់ទីក្រុងដើម្បីរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត ចំណែកឯ កំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃទីក្រុងថ្មី គឺជាការកែប្រែតំបន់មួយដែលមានលក្ខណៈជនបទ មកជាតំបន់អភិវឌ្ឍន៍ដែលទាក់ទាញប្រជាជនមករស់នៅតំបន់នោះដែលមានការកើនឡើងចំនួនប្រជាជននូវតំបន់ដែលអភិវឌ្ឍន៍ថ្មីនោះ។

នាពេលបច្ចុប្បន្ននេះ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម សេដ្ឋកិច្ច សង្គមកិច្ច សន្តិសុខ ទេសចរណ៍ សោភណ្ឌភាព ការប្រមូលផ្ដុំវប្បធម៌ជាតិ និងឧស្សាហកម្មដ៏ធំមួយដែលមានការលូតលាស់និង រីកចម្រើនគួរឲ្យកត់សម្គាល់។ រាជធានីភ្នំពេញកាលអំឡុងឆ្នាំ២០១៥ មានផ្ទៃដី **៦៧៨,៤៦** គីឡូម៉ែត្រក្រឡា មានខណ្ឌចំនួន **១២**ខណ្ឌ សង្កាត់ចំនួន **៩៦**សង្កាត់ ភូមិចំនួន **៨៩៧**ភូមិ មានប្រជាពលរដ្ឋចំនួន **២៣៩.៦២៥**គ្រួសារ ស្មើនឹង **១.២៣៥.៧៣៨**នាក់ ស្រីចំនួន **៦៤៩.២៦៨**នាក់ ដង់ស៊ីតេ **១.៨២១**នាក់/គម² ។[15] ចំពោះចំនួនប្រជាជនដែលរស់នៅក្នុងរាជធានីភ្នំពេញនៅក្នុងឆ្នាំ ២០១៨ មានផ្ទៃដីចំនួន **៦៩២,៤៦**គីឡូម៉ែត្រក្រឡា មានខណ្ឌចំនួន **១២**ខណ្ឌ សង្កាត់ចំនួន **១០៥**សង្កាត់ ភូមិ**៩៥៣**ភូមិ មានប្រជាពលរដ្ឋចំនួន **៣០៥.៧៦៧**គ្រួសារ ស្មើនឹង **១.៤៧០.៣០៣**នាក់ ស្រីចំនួន **៩៦០.០៨១**នាក់ មានដង់ស៊ីតេ **២.២១៣**នាក់/គម² ។[16]

### ១.១.១.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រ មានការលំបាកនៅក្នុងការកំណត់នោះ តែជាទូទៅភាពក្រីក្រសំដៅដល់តម្រូវការការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើន បានកំណត់ពីភាពក្រីក្រ តាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅឋាន ការងារធនធានទឹក អគ្គិសនី អនាម័យសុខុមាលភាពសង្គមមានការខ្វះខាត។ លើសពីនេះ សិទ្ធិសេរីភាពផ្នែកស្មារតី និយាយជារួម និងនិយាយដោយឡែក សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។

ការសម្គាល់ពីភាពក្រីក្រ ត្រូវបានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជាៈ ចំនួននៃករណី ឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យម មិនអាចយក

[15] គេហទំព័រ mrd.gov.kh>2015-01-Phnom-Penh របាយការណ៍ខែមករា ឆ្នាំ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ
[16] គេហទំព័រ http://phnompenh.gov.kh ចូលមើលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩

មកជំនួសដោយការវាស់ស្ទង់ តាមរយៈប្រាក់ចំណូលនេះឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។[17]

ម៉្យាងវិញទៀត ប្រសិនបើយើងធ្វើការវាស់វែង និងប្រៀបធៀបរវាងភាពក្រីក្រនៅទីក្រុង និងភាពក្រីក្រនៅទីជនបទ គឺពុំមានលក្ខណៈសមភាពគ្នានោះទេមូលហេតុនោះ គឺដោយសារតែជាធម្មតាចំណាយនៅទីក្រុងខ្ពស់ជាងជនបទដាច់ស្រយាលឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះអ្នករស់នៅតាមទីជនបទអាចមានឱកាសស្វែងរកការចិញ្ចឹមជីវិតតាមរយៈការទទួលអំណោយ ភោគផលពីធម្មជាតិច្រើនជាងអ្នកនៅទីក្រុង។ តាមរយៈនេះ គេអាចនិយាយបានថាអ្នកក្រនៅទីក្រុង ក្រជាង និងមានស្ថានភាពលំបាកជាងអ្នកក្រនៅជនបទ។[18]

ទោះបីជាកំណើនសេដ្ឋកិច្ច មានការកើនឡើងក៏ដោយ នៅតែមានប្រជាពលរដ្ឋមួយចំនួនតូចមានជីវភាពខ្វះខាតនៅឡើយ នេះបណ្តាលមកពីពួកគាត់ខ្វះចំណេះដឹង ជំនាញ និងទុន ដើម្បីធ្វើជាមុខរបរចិញ្ចឹមជីវិត។ ក៏ប៉ុន្តែ ប្រជាពលរដ្ឋមួយចំនួនធំមានជីវភាពល្អប្រសើរផងដែរ ដោយមានការជួយជ្រោមជ្រែងពីសំណាក់ស្ថាប័នផ្សេងៗ និងមានការងារធ្វើ មានប្រាក់ខែសមរម្យ សម្រាប់ចិញ្ចឹមជីវិតបាន។[19]

### ១.១.១.៣. កម្រិតជីវភាពនៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាព គឺជាកត្តាចម្បង ដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាជុំវិញការជម្រុញឱ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សន៍ខ្ពស់នៅទីក្រុង ជាកត្តាទាក់ទាញមនុស្សឱ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ ប្រជាពលរដ្ឋនៅជនបទនៅតែចង់មករស់នៅទីក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និង អត្រានិកម្មភាពខ្ពស់ជាកត្តាជម្រុញចំណាកស្រុកដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូច្នេះ ទោះជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះនៅទីក្រុងមានប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរ ខណៈពេលសេវាសុខាភិបាល និងអប់រំមានសម្បូរបែប រឹតរឹងតែធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថា មានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។[20] ម៉្យាងវិញទៀតភាពក្រីក្រ ក៏ជាកត្តាចម្បងមួយដែលនាំឲ្យមានការអភិវឌ្ឍ។ កាលណាប្រជាជនមានកម្រិតជីវភាពក្រីក្រ នោះតម្រូវការរបស់ប្រជាជនក៏មានការកើនឡើង។ ដូច្នេះ ដើម្បីឆ្លើយតបតបទៅនឹងតម្រូវការរបស់ប្រជាជន គេបានបង្កើន

---

[17] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី៧

[18] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី៨

[19] សៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ឆ្នាំ២០១៥-២០១៧ របស់ខណ្ឌឫស្សីកែវ ទំព័រទី០៥

[20] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី៩

ការវិនិយោគ ដោយមានការកសាងនូវរោងចក្រ សហគ្រាស ភោជនីយដ្ឋាន សាលារៀន មន្ទីរពេទ្យ ដើម្បីបង្កើតលទ្ធភាពការងារ ក៏ដូចជាការបណ្តុះបណ្តាលដល់ប្រជាជនផងដែរ។ លើសពីនេះ កាលណាមានការបង្កើននូវផលិតភាពការងារកាន់តែកើនឡើងនោះតម្រូវការមធ្យោបាយដឹកជញ្ជូនផលិតផល ព្រមទាំងទំនិញនានា ដែលបានមកពីការផលិតរបស់ប្រជាជន ដែលតម្រូវឲ្យមានការកសាងផ្លូវនានាសម្រាប់ដឹកជញ្ជូនទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស។ កត្តាទាំងនេះ សុទ្ធតែធ្វើឲ្យវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តបាន កសាងឡើងជាបន្តបន្ទាប់ ដែលធ្វើឲ្យនគរូបនីយកម្មក្នុងប្រទេសកាន់តែមានការរីកចម្រើនជាលំដាប់។

### ១.១.១.៤. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទ ពាក់ព័ន្ធវិស័យបរិស្ថានគឺ កង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើនក្នុងករណី ដែលដីរបស់ពួកគេទទួលបានពីដូនតា ឪពុកម្តាយរបស់ខ្លួន ត្រូវបានគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូចមិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងៗឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីវជាតិទៀត។ ប្រសិនបើក្រលេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែពួកគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ។ ករណីនេះ ច្រើនកើតនៅប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់មេគង្គក្រោម។[21] ដោយឡែក ចំពោះបញ្ហាការដាក់សម្ពាធបរិស្ថានក្នុងប្រទេសកម្ពុជា ដែលបាននឹងកំពុងគំរាមកំហែងប្រជាជនមួយចំនួនធំដោយសារតែបញ្ហាគ្រោះធម្មជាតិមានដូចជា ទឹកជំនន់ទន្លេ ទឹកជំនន់ទឹកភ្លៀង ខ្យល់កន្ត្រាក់ ដែលគ្រោះធម្មជាតិទាំងនេះបានធ្វើឲ្យមានការលិចលង់ផ្លូវ ស្ពះប្រព័ន្ធលូ និងឈានទៅដល់ការខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធមួយចំនួនធំទៀតផង។

ម្យ៉ាងវិញទៀត កាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ ទឹកជំនន់បានបង្កឡើង ដែលធ្វើឲ្យតំបន់មួយចំនួននៅតាមបណ្តោយទន្លេក្នុងរាជធានីភ្នំពេញមានការប្រឈមនឹងការជន់លិច និងបានធ្វើឲ្យច្រាំងទន្លេនៅតាមភូមិចំនួនក្នុងរាជធានីភ្នំពេញ ដែលធ្វើឲ្យផ្លូវលំបាកបាក់ចូលទៅក្នុងទន្លេដែលបញ្ហានេះបានធ្វើឲ្យការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋត្រូវបានផ្អាកទាំងស្រុង។ ដើម្បីស្តារនូវស្ថានភាពនេះឡើង មន្ទីរធនធានទឹក និងមន្ទីរសាធារណការ ដែលជាក្រុមបច្ចេកទេសបានចុះធ្វើការត្រួតពិនិត្យ និងរៀបចំឲ្យផ្លូវលំមានសភាពល្អប្រសើរឡើងសម្រាប់ប្រជាពលរដ្ឋធ្វើដំណើរវិញ។[22] ដោយសារតែកត្តាសំពាធបរិស្ថានទាំងនេះ ហើយក៏ជាកត្តាមួយដ៏សំខាន់តម្រូវឱ្យមានការរៀបចំសណ្តាប់ធ្នាប់នៅតាមតំបន់ដូចជា ក្រុង ស្រុក ខណ្ឌឱ្យមានរបៀបរៀបរយ ល្អប្រសើរ។

---

[21]សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី៩

[22] គេហទំព័រ https://khmersaharika.com ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨

### ១.១.១.៥. គមនាគមន៍

គមនាគមន៍ គឺជាបញ្ហាមួយសំខាន់ដែលជម្រុញឲ្យមានការអភិវឌ្ឍ ដែលវាបានធ្វើការផ្តោតសំខាន់ទៅលើការអភិវឌ្ឍផ្លូវ។ ផ្លូវ ជាបញ្ហាចោទមួយសម្រាប់ទីក្រុង ដែលគួរគប្បីធ្វើការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ ដែលធ្វើឲ្យទីក្រុងមានសណ្តាប់ធ្នាប់ល្អ តាមរយៈការធ្វើដំណើរទៅមកប្រកបដោយសន្តិសុខ និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេស។ កាលណាមានផ្លូវល្អ គ្មានខូចខាត ដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រកបរបរចិញ្ចឹមជីវិត នោះសេដ្ឋកិច្ចជាតិក៏កាន់តែរីកចម្រើនដែរ។

ការលូតលាស់ផ្នែក កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការរីកចម្រើនខាងផ្លូវគមនាគមន៍។ ផ្លូវគមនាគមន៍នៅកម្ពុជាយើងសព្វថ្ងៃមានដូចជា ផ្លូវគោក ផ្លូវដែក ផ្លូវទឹក ផ្លូវអាកាស ដែលមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ធ្វើដំណើរ និងធ្វើពាណិជ្ជកម្ម ដែលធ្វើការដឹកជញ្ជូនទំនិញនានាឆ្លងដែនទៅក្រៅប្រទេស ដែលមានលក្ខណៈជាអន្តរជាតិ។[23]

ដូចនេះ វិស័យគមនាគមន៍ជាមធ្យោបាយមួយដ៏សំខាន់ ដែលជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិសម្រាប់ដឹកជញ្ជូនទំនិញចេញចូលក្នុង និងក្រៅប្រទេស ព្រមទាំងសម្រាប់ធ្វើដំណើរដែលមិនអាចខ្វះបាន។ កាលណាគមនាគមន៍រីកចម្រើន ជួយសម្រួលដល់ការដឹកជញ្ជូនភ្ញៀវទេសចរណ៍ ផលិតផលកសិកម្ម និងឧស្សាហកម្ម វត្ថុធាតុដើម ទំនិញនាំចេញនាំចូលរហ័សទាន់ពេលវេលា ចំណាយសោហ៊ុយតិច និង ប្រកបដោយជាសុខភាព សុវត្ថិភាព។

### ១.១.១.៦. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវបានអាជ្ញាធរគ្រប់ជាន់ថ្នាក់ធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីការពារនូវសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ ដែលអនុវត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ក្នុងនោះមានគណៈបញ្ជាការឯកភាពរដ្ឋបាលទាំងថ្នាក់ខណ្ឌសង្កាត់ ដែលបាននឹងកំពុងអនុវត្តគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាពធានាបាននូវលក្ខណៈសម្បត្តិ ៥ យ៉ាង ៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហឹង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង

[23] សៀវភៅភូមិវិទ្យា សេដ្ឋកិច្ច និងមនុស្ស នៃប្រទេសកម្ពុជា ដែលរៀបរៀងដោយ គណៈកម្មការរៀបរៀង គឺលោក-លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៤

- គ្មានការលេងល្បែងស៊ីសងប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។[24]

ចំពោះការអនុវត្តនូវគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ក្នុងគោលដៅថែរក្សា ការពារ នូវសន្តិសុខ និងសណ្តាប់ធ្នាប់ទាំងផ្លូវកាយ និងផ្លូវចិត្តសម្រាប់ប្រជាពលរដ្ឋដែលបានរស់នៅក្នុង ភូមិ ឃុំ សង្កាត់នានា និង ការទប់ស្កាត់ គ្រប់គ្រង ព្រមទាំងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព គ្មានការត្រួតពិនិត្យខុសច្បាប់។ រដ្ឋបាលខណ្ឌ សង្កាត់ បាននឹងកំពុងគ្រប់គ្រងអនុវត្តការងាររបស់ខ្លួនជាប្រចាំ។ ប៉ុន្តែបញ្ហាប្រឈមនៅតែកើតមាន ដែលតម្រូវឱ្យរដ្ឋបាលខណ្ឌ សង្កាត់ យកចិត្តទុកដាក់ និងដោះស្រាយជាបណ្តើរៗដូចជា ៖ ការលួច ឆក់ ប្លន់ ការគំរាមកំហែង ការប្រើប្រាស់គ្រឿងញៀន ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋ ការគ្រប់គ្រងអ្នកស្នាក់នៅបណ្តោះអាសន្ន អំពើហិង្សាក្នុងគ្រួសារ ក្មេងទំនើង ល្បែងស៊ីសង សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាពសង្គម។

[24] ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" អនុម័តថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

## ១.១.២. រចនាសម្ព័ន្ធខណ្ឌឬស្សីកែវ

### ១.១.២.១. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល




❖ ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- គ្រប់គ្រង និងថែរក្សាត្រារដ្ឋបាលខណ្ឌតាមការកំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន
- ការងារបុគ្គលិក ក្របខណ្ឌ ប្រវត្តិរូប និងកម្រៃផ្សេងៗរបស់មន្ត្រីបុគ្គលិកសាលាខណ្ឌ
- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងាររបស់មន្ត្រីបុគ្គលិកសាលាខណ្ឌ
- ការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌ

- សិក្សា និងលើកយោបល់លើការបង្កើតការកែសម្រួល និងការរំសាយការិយាល័យចំណុះសាលាខណ្ឌ
- ការបណ្ដុះបណ្ដាល និងកសាងសមត្ថភាពមន្ត្រីបុគ្គលិកសាលាខណ្ឌ
- រៀបចំសេចក្ដីព្រាង របៀបវារៈ ខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌ
- រៀបចំ និងបែងចែកលិខិតប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌ
- ទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមដល់សមាជិកក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌ និងអភិបាលរងខណ្ឌ ព្រមទាំងក្រសួង ស្ថាប័នមន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឲ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងរដ្ឋបាលខណ្ឌ
- រៀបចំ និងបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងខណ្ឌ
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ តាមសាលាសង្កាត់នានាក្នុងខណ្ឌ
- ជម្រុញ និងអនុវត្តកិច្ចការពាក់ព័ន្ធ ការបញ្ជ្រៀបយេនឌ័រ និងបង្កើនសិទ្ធិអំណាចស្ត្រី
- អនុវត្តនូវកិច្ចការផ្សេងៗទៀត តាមការប្រគល់របស់នាយករដ្ឋបាលសាលាខណ្ឌឫស្សីកែវ និងតាមការតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[25]

❖ ការិយាល័យផែនការ និងអភិវឌ្ឍន៍

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌ ដើម្បីបញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី

[25] របាយការណ៍ស្ដីពី តួនាទី ភារកិច្ចរបស់ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុខណ្ឌឫស្សីកែវ

- ជួយក្រុមការងារកសាងផែនការខណ្ឌក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ
- ចូលរួមក្នុងការវិភាគស្ថានភាពខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ
- គាំទ្រដល់សង្កាត់ក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍របស់សង្កាត់
- ការគាំទ្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការផ្តល់សេវាក្នុងចំនោមសង្កាត់នានា
- ជួយសម្របសម្រួល និងជម្រុញអាជ្ញាធរភូមិ សង្កាត់ ក្នុងការស្រង់ទិន្នន័យភូមិ សង្កាត់ ខណ្ឌ
- ជួយក្រុមការងារកសាងផែនការ ក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យភូមិ សង្កាត់ខណ្ឌ
- សហការជាមួយក្រុមការងារកសាងផែនការខណ្ឌក្នុងការរៀបចំបណ្តាឧបករណ៍សម្រាប់ចូលរួមសិក្ខាសាលា សមាហរណកម្មនៅខណ្ឌ និងវេទិកាពិគ្រោះយោបល់នៅថ្នាក់រាជធានី
- ការិយាល័យច្រកចេញចូលតែមួយ
- ការងារនីត្យានុកូលកម្ម
- វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- វិស័យអប់រំយុវជន និងកីឡា
- វិស័យទេសចរណ៍
- វិស័យកសិកម្ម
- ការងារអត្រានុកូលដ្ឋាន
- វិស័យសំណង់
- វិស័យឧស្សាហកម្ម រ៉ែ និងថាមពល
- វិស័យពាណិជ្ជកម្ម
- វិស័យសាធារណការ និងដឹកជញ្ជូន
- វិស័យសុខាភិបាល
- វិស័យសុរិយោដី

- ការិយាល័យអន្តរវិស័យ
- ការងារដីធ្លី និងសំណង់
- កាងារសេដ្ឋកិច្ច(ពាណិជ្ជកម្ម កសិកម្ម ទេសចរណ៍)
- ការងារធម្មការ និងសាសនា
- ការងារសាធារណៈការ
- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារបរិស្ថាន
- ការងារព័ត៌មាន
- ការងារវប្បធម៌
- ការងារដោះស្រាយវិវាទនៅមូលដ្ឋាន
- ការិយាល័យប្រជាពលរដ្ឋ
- ទទួលពាក្យបណ្តឹង
- សម្របសម្រួល
- បញ្ជូនបន្ត
- អង្គភាពលទ្ធកម្ម
- ការងារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗ
- ការងារផ្សព្វផ្សាយលទ្ធកម្មនៃការដេញថ្លៃ
- សេចក្តីព្រាងកិច្ចសន្យាដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យា
- តាមដាន និងទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬទីប្រឹក្សា
- រៀបចំរបាយការណ៍ស្តីពីកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

### ១.១.២.២. រចនាសម្ព័ន្ធខណ្ឌ




សាលាខណ្ឌឫស្សីកែវ គឺត្រូវបានដឹកនាំដោយអភិបាលខណ្ឌ ០១រូប និងអមដោយអភិបាលរងខណ្ឌ ០៤រូប។ នៅក្នុងសាលាខណ្ឌនេះ អភិបាលនៃគណៈអភិបាលខណ្ឌត្រូវទទួលបន្ទុកដូចជា៖

- ដឹកនាំការងាររួម
- ដឹកនាំផ្ទាល់លើកិច្ចការទូទៅ
- ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ

ចំណែកឯអភិបាលរងខណ្ឌ ០៤រូប ទៀតទទួលបន្ទុកការងារមួយចំនួនមានដូចខាងក្រោម៖

➢ អភិបាលរងខណ្ឌ ០១រូប ទទួលបន្ទុកលើការងារការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
   - កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
   - កិច្ចការអប់រំយុវជន និងកីឡា
   - កិច្ចការព័ត៌មាន
   - កិច្ចការអត្រានុកូលដ្ឋាន
   - ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
   - កិច្ចការវេទិកាសាធារណៈ
   - កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- កិច្ចការធនាគារ និងរតនាគារ ពន្ធដារ សាខាកាំកុងត្រូល
- កិច្ចការសាខាគយ និងរដ្ឋាករខណ្ឌ
- កិច្ចការអង្គការក្រៅរដ្ឋាភិបាល
- កិច្ចការគណៈបក្សនយោបាយ

➢ អភិបាលរងខណ្ឌ ០១រូបទទួលបន្ទុកលើការងារការិយាល័យផែនការ និងអភិវឌ្ឍន៍

- កិច្ចការវិនិយោគ
- កិច្ចការអភិវឌ្ឍន៍
- កិច្ចការលទ្ធកម្ម
- កិច្ចការសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សហគមន៍ សមាគមន៍
- កិច្ចការកម្មវិធី ផែនការអភិវឌ្ឍន៍ ៣ឆ្នាំរំកិលខណ្ឌ (ផ.អ.៣ខណ្ឌ)
- កិច្ចការអភិវឌ្ឍន៍ជនបទ
- កិច្ចការធនធានទឹក ឧត្តុនិយម និងធារាសាស្ត្រ
- កិច្ចការបរិស្ថាន
- កិច្ចការរ៉ែ និងថាមពល
- កិច្ចការគ្រប់គ្រងកាកសំនល់រឹង និងរាវ
- កិច្ចការផែនការស្ថិតិ

➢ អភិបាលរងខណ្ឌ ០១រូបទទួលបន្ទុកលើការងារការិយាល័យអន្តរវិស័យ

- កិច្ចការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ
- កិច្ចការពាណិជ្ជកម្ម និងទទួលជួយកិច្ចការកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ
- កិច្ចការគ្រប់គ្រងផ្សាររដ្ឋ និងផ្សារឯកជន
- កិច្ចការគ្រោះមហន្តរាយ
- កិច្ចការការិយាល័យច្រកចេញចូលតែមួយ
- កិច្ចការអនុសាខាកាកបាទក្រហមកម្ពុជា
- កិច្ចការធម្មការ និងសាសនា

➢ អភិបាលរងខណ្ឌ ០១រូបទទួលបន្ទុកលើការងារការិយាល័យអន្តរវិស័យខណ្ឌ កិច្ចការនារី និងកុមារ

- កិច្ចការទេសចរណ៍
- កិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ

- កិច្ចការសុខាភិបាល
- កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- កិច្ចការឧស្សាហកម្ម និងសិប្បកម្ម
- កិច្ចការប្រៃសនីយ៍ និងទូរគមនាគមន៍។[26]

## ១.២. ទិសដៅនៃការរៀបចំខណ្ឌឫស្សីកែវ

ខណ្ឌឫស្សីកែវ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញ ដែលមានសង្កាត់ចំនួន០៧ និងមានភូមិចំនួន៣០ មានសង្កាត់ចំនួន០១ ដែលទើបនឹងបង្កើតថ្មី គឺសង្កាត់ទួលសង្កែទី២ ដែលបំបែកចេញពីសង្កាត់ទួលសង្កែទី១។ ក្នុងនោះផងដែរ សង្កាត់ទាំង០៧ក្នុងខណ្ឌឫស្សីកែវមានដូចជា សង្កាត់គីឡូម៉ែត្រលេខ៦ សង្កាត់ស្វាយប៉ាក សង្កាត់ច្រាំងចំរេះទី១ សង្កាត់ច្រាំងចំរេះទី២ សង្កាត់ឫស្សីកែវ សង្កាត់ទួលសង្កែទី១ និងសង្កាត់ទួលសង្កែទី២។ ខណ្ឌនេះជាខណ្ឌមួយដែលមានសក្តានុពលសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ព្រោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរសេវាកម្ម មុខរបរក្រៅពីពីវិស័យកសិកម្មមាន ៩៦,២% កសិកម្ម(នេសាទ) មាន៣,៨% ទាំងនេះបង្ហាញឲ្យឃើញពីស្ថានភាពការអភិវឌ្ឍផ្នែកអាជីវកម្មផ្សេងៗ។ ម្យ៉ាងវិញទៀត វិស័យឯកជន គឺជាក្បាលម៉ាស៊ីនដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ច ដូច្នេះទាមទារឲ្យមានការវិនិយោគផ្ទាល់ពីវិស័យឯកជនក្នុងមូលដ្ឋានខណ្ឌទាំងមូល ដូចជាការបង្កើតសហគ្រាស សិប្បកម្ម ដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

ដូច្នេះ ដើម្បីឲ្យវិស័យឯកជន ចូលមកវិនិយោគក្នុងមូលដ្ឋានខណ្ឌ ត្រូវដាក់ចេញនូវគោលការណ៍មួយចំនួនដូចខាងក្រោម៖

- លើកទឹកចិត្ត និងជម្រុញការចូលរួមរបស់វិស័យឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ តាមការពិនិត្យឡើងវិញ ច្បាប់ស្តីសម្បទាន ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត។
- បន្តការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងឡាយ ដែលគាំទ្រដល់ការបង្កើតធុរកិច្ច និងលើកម្ពស់ការវិនិយោគ។
- បង្កបង្កើតបរិយាកាសអំណោយផល សម្រាប់ការទទួលការវិនិយោគ ក្នុងមូលដ្ឋានរួមមាន ការសម្រួលការចុះបញ្ជី ការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតិផ្សេងៗជាពិសេសតាមយន្តការច្រកចេញចូលតែមួយ ដើម្បីពន្លឿនរាល់ប្រតិបត្តិការនានា ពាក់ព័ន្ធនឹងធុរកិច្ច និងការវិនិយោគ ព្រមទាំងការកាត់បន្ថយចំណាយក្រៅផ្លូវការ។

---

[26] តារាងរចនាសម្ព័ន្ធខណ្ឌឫស្សីកែវឆ្នាំ២០១៩

- បន្តអនុវត្តយន្តការវេទិកាពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋ និងវិស័យឯកជន ដើម្បីពង្រឹងឲ្យកាន់តែមានជីវភាពល្អប្រសើរ និងកាន់តែមានភាពជាម្ចាស់។
- ផ្តោតការយកចិត្តទុកដាក់លើការផ្សព្វផ្សាយ និងទាក់ទាញការវិនិយោគផ្ទាល់ ព្រមទាំងលើកម្ពស់សេវាថែរក្សាវិនិយោគដែលមានស្រាប់។[27]

### ១.២.១. សមិទ្ធិផលនៃការរៀបចំ

ខណ្ឌឫស្សីកែវ បានការអភិវឌ្ឍទៅលើវិស័យជាច្រើនគួរឲ្យកត់សម្គាល់។ ប៉ុន្តែខណៈពេលនេះសូមលើកយកនូវសមិទ្ធិផលមួយចំនួន ដែលខណ្ឌធ្វើការសម្រេចបានមានដូចជា ការអភិវឌ្ឍទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ សំណង់លំនៅឋាន ការងាររៀបចំសណ្តាប់ធ្នាប់ និងការងារសាធារណៈការ។

#### ១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

បណ្តាហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌឫស្សីកែវមានដូចជា កសាងផ្លូវ ប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងការកសាងស្ពាន។ ការសាងកសាងផ្លូវ ប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងការកសាងស្ពាន ពិតជាមានសារៈសំខាន់ណាស់ ដែលជួយធ្វើឲ្យខណ្ឌមានសណ្តាប់ធ្នាប់ និងជួយកាត់បន្ថយការស្ទះប្រព័ន្ធលូ និងការកកស្ទះចរាចរណ៍លើដងផ្លូវបានមួយចំណែកធំផងដែរ។

##### ក. ការកសាងផ្លូវ

ការងារកសាងផ្លូវក្នុងខណ្ឌឫស្សីកែវមានដូចតទៅ ៖

- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ច្រាំងចំរេះទី១ ប្រវែង ១៩៣០ម² ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់គីឡូម៉ែត្រលេខ៦ ប្រវែង ២៤៧៥ម² ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ឫស្សីកែវ ប្រវែង ២២៦៩ម² ដែលចាប់ផ្តើមធ្វើ នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ទួលសង្កែទី១ ប្រវែង ២២៨៨ម² ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមានរយៈពេល០១ឆ្នាំ

[27] សៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឆ្នាំ ២០១៥-២០១៧ របស់ខណ្ឌឫស្សីកែវ ទំព័រទី០១

- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ទួលសង្កែទី២ ប្រវែង ១១០២ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ស្វាយប៉ាក ប្រវែង ៤២០ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមានរយៈពេល ០១ឆ្នាំ។[28]
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់គីឡូម៉ែត្រលេខ៦ ប្រវែង ១៤៤០ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ឫស្សីកែវ ប្រវែង ៩៧២ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានរយៈពេល ០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ទួលសង្កែទី១ ប្រវែង ១៣២០ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ទួលសង្កែទី១ ប្រវែង ២០៥៧ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ស្វាយប៉ាក ប្រវែង ៣០២៤ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានរយៈពេល០១ឆ្នាំ
- ជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក នៅសង្កាត់ច្រាំងចំរេះទី១ ប្រវែង ៦៦៦ម$^2$ ដែលចាប់ផ្តើមធ្វើនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលមានរយៈពេល០១ឆ្នាំ[29]
- ស្ថាបនាផ្លូវបេតុងឆ្អឹងដែកពីចំណុចផ្លូវ ៥៩៨ ដល់ផ្លូវអនុវត្តឆ្នាំ២០០៦ កម្រាស់ ០,១៥ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់ច្រាំងចំរេះទី១ ប្រវែង ៤៤៣ម៉ែត្រ×៨ម៉ែត្រ រយៈពេល០១ឆ្នាំ

[28] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៥-២០១៧ ទំព័រទី១២
[29] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៦-២០១៨ ទំព័រទី១៥

- ស្ថាបនាផ្លូវបេតុងឆ្អឹងដែកពីចំណុចផ្លូវ ៩០៧ ដល់បុរីវដ្ឋនីដា កម្រាស់ ០,១៥ ម៉ែត្រ ស្ថិតនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ប្រវែង ៩៥៧ម៉ែត្រ×៨ម៉ែត្រ រយៈពេល០១ឆ្នាំ។[30]

## ខ. ប្រព័ន្ធលូបង្ហូរទឹកក្នុងខណ្ឌឫស្សីកែវ

ខណ្ឌឫស្សីកែវមានការស្ថាបនាប្រព័ន្ធលូបង្ហូរទឹក ដើម្បីកាត់បន្ថយនូវការជន់លិច ដែលបណ្តាលមកពីការស្ទះលូ ខណ្ឌបានយកចិត្តទុកដាក់ ដោយបានធ្វើការស្ថាបនាប្រព័ន្ធលូថ្មីៗនៅ តាមសង្កាត់នានាក្នុងខណ្ឌ និងជួសជុលនូវប្រព័ន្ធលូចាស់ៗទៀតផង។ ចំពោះការស្ថាបនាប្រព័ន្ធ ប្រឡាយទាំងនោះមានដូចខាងក្រោមះ

- មានការសាងសង់ប្រព័ន្ធលូថ្មី ស្ថិតនៅសង្កាត់ស្វាយប៉ាក ដែលមានប្រវែង ៦០៩ម៉ែត្រ×០,៨ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការសាងសង់ប្រព័ន្ធលូថ្មី ស្ថិតនៅសង្កាត់ទួលសង្កែ ដែលមានប្រវែង ៥៧៩ ម៉ែត្រ×១ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការសាងសង់ប្រព័ន្ធលូថ្មី ស្ថិតនៅសង្កាត់ទួលសង្កែ ដែលមានប្រវែង ១០៨០ម៉ែត្រ×០,៨ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការសាងសង់ប្រព័ន្ធលូថ្មី ស្ថិតនៅសង្កាត់ច្រាំងចំរេះទី២ ដែលមានប្រវែង ៥៨៩ម៉ែត្រ×០,៨ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការសាងសង់ប្រព័ន្ធលូថ្មី ស្ថិតនៅសង្កាត់ឫស្សីកែវ ដែលមានប្រវែង ៣៩៣ ម៉ែត្រ×១ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការសាងសង់ប្រព័ន្ធលូថ្មី ស្ថិតនៅសង្កាត់ឫស្សីកែវ ដែលមានប្រវែង ២១៩ ម៉ែត្រ×០,៨ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ

[30] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៨-២០២០ ទំព័រទី២៧

- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ច្រាំងចំរេះទី២ ដែលមានប្រវែង ៥៥០ម៉ែត្រ×០,៥ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ច្រាំងចំរេះទី២ ដែលមានប្រវែង ៣១៧ម៉ែត្រ×០,៩ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ គីឡូម៉ែត្រលេខ៦ ដែលមានប្រវែង ២៣០០ម៉ែត្រ×០,៦ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ គីឡូម៉ែត្រលេខ៦ ដែលមានប្រវែង ១២០ម៉ែត្រ×០,៥ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ឫស្សីកែវ ដែលមានប្រវែង ៣៥០ ម៉ែត្រ×០,៨ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ឫស្សីកែវ ដែលមានប្រវែង ២៧១០ ម៉ែត្រ×០,៦ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ឫស្សីកែវ ដែលមានប្រវែង ១៨០៥ ម៉ែត្រ×០,៥ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ទួលសង្កែ ដែលមានប្រវែង ៥៥០ ម៉ែត្រ×១ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្តារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ទួលសង្កែ ដែលមានប្រវែង ២០១៥ម៉ែត្រ×០,៦ម៉ែត្រ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ

- មានការស្ដារប្រព័ន្ធលូចាស់ ស្ថិតនៅសង្កាត់ ទួលសង្កែ ដែលមានប្រវែង ៣៣០ ម៉ែត្រ×០,៥ម៉ែត្រ ចាប់ផ្ដើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការស្ដារប្រព័ន្ធលូចាស់ (ស្ដារលូអ៊ុត) ស្ថិតនៅសង្កាត់ ទួលសង្កែ ដែលមានប្រវែង២ម៉ែត្រ×៣,៦ម៉ែត្រ ចាប់ផ្ដើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការជួសជុលអណ្ដូងលូ ស្ថិតនៅសង្កាត់ គីឡូម៉ែត្រលេខ៦ ជួសជុលចំនួន ៣៨ អណ្ដូង ចាប់ផ្ដើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល១ឆ្នាំ
- មានការជួសជុលអណ្ដូងលូ ស្ថិតនៅសង្កាត់ ឫស្សីកែវ ជួសជុលចំនួន ២៣ អណ្ដូង ចាប់ផ្ដើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ
- មានការជួសជុលអណ្ដូងលូ ស្ថិតនៅសង្កាត់ ទួលសង្កែ ជួសជុលចំនួន ៥៨ អណ្ដូង ចាប់ផ្ដើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល០១ឆ្នាំ។[31]
- ដាក់ប្រព័ន្ធលូ២ខ្សែ សងខាងផ្លូវផ្សារ ពីផ្លូវជាតិលេខ៥ ដល់ផ្សារគីឡូម៉ែត្រលេខ៧ចាស់ ស្ថិតនៅស្ថិតនៅភូមិ៦១ និង ភូមិ៦២ សង្កាត់ច្រាំងចំរេះទី២ មានប្រវែង ១៩១ម៉ែត្រ×០,៨ម៉ែត្រ រយៈពេល០១ឆ្នាំ
- ដាក់ប្រព័ន្ធលូពីចំណុចវិទ្យាល័យឫស្សីកែវ ដល់ខាងត្បូងវត្តឧត្តរាវត្តី ស្ថិតនៅភូមិបឹងសាឡាង និងភូមិឃ្លាំងសាំង សង្កាត់ឫស្សីកេវ មានប្រវែង ២៥០ម៉ែត្រ×០,៨ម៉ែត្រ រយៈពេល០១ឆ្នាំ
- ស្ដារប្រព័ន្ធលូពីបណ្ដោយផ្លូវជាតិលេខ៥ ចំណុចកែងឃ្លាំងសាំង ដល់ភ្លើងស្តុបកែងផ្លូវ ៦៨ និង អណ្ដូងលូ ៥០ ស្ថិតនៅសង្កាត់ឫស្សីកែវ និង សង្កាត់ទួលសង្កែទី១ មានប្រវែង ១,៦៦១មាន ៦០អណ្ដូង រយៈពេល០១ឆ្នាំ។[32]

[31] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៥-២០១៧ ទំព័រទី១៦
[32] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៨-២០២០ ទំព័រទី២៧

### គ. ការដាក់បង្គោលភ្លើងបំភ្លឺសាធារណៈ

ក្នុងខណ្ឌឫស្សីកែវមានការរៀបចំដាក់បង្គោលភ្លើងបំភ្លឺសាធារណៈតាមដងផ្លូវនានា ដើម្បីជួយសម្រួលដល់ការបើកបររបស់ប្រជាជននាពេលរាត្រី ប្រកបដោយសុវត្ថិភាពនៅលើដងផ្លូវមានដូចជាៈ

- មានការរៀបចំដាក់បង្គោលភ្លើង និងអំពូលភ្លើង បំភ្លឺតាមដងផ្លូវក្នុងមូលដ្ឋាន ដែលស្ថិតនៅក្រុមទី៥ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ដែលមានចំនួន២ខ្សែ ស្មើនឹង ៣៦បង្គោល និង ៣៦អំពូល
- មានការរៀបចំដាក់បង្គោលភ្លើងបំភ្លឺសាធារណៈ ចំនួន៦៥០ដើម នៅសង្កាត់ទាំង៦ក្នុងខណ្ឌ[33]
- ដាក់បង្គោលភ្លើងបំភ្លឺតាមផ្លូវសាធារណៈបាន ៥០បង្គោល នៅឆ្នាំ២០១៥ និង ២៥០ បង្គោល នៅឆ្នាំ ២០១៩។[34]

### ឃ. ការកសាងស្ពាន

ស្ពាន គឺជាមធ្យោបាយធ្វើដំណើរដ៏សំខាន់មួយសម្រាប់ប្រពលរដ្ឋក្នុងការធ្វើដំណើរ ព្រមទាំងជាមធ្យោបាយដ៏សំខាន់ក្នុងការដឹកជញ្ជូន ដែលបម្រើដល់វិស័យសេដ្ឋកិច្ចបានមួយផ្នែកធំ។ ក្នុងនោះផងដែរ ខណ្ឌឫស្សីកែវក៏មានស្ពានចំនួនបួនដែលភ្ជាប់ទៅខណ្ឌសព្វថ្ងៃមានដូចជា ស្ពានជ្រោយចង្វាទី១(ស្ពានមិត្តភាពកម្ពុជា-ជប៉ុន) ស្ពានជ្រោយចង្វាទី២(ស្ពានមិត្តភាពកម្ពុជា-ចិន) ស្ពានបាឡេ និងស្ពានព្រែកព្នៅ។

ក្នុងនោះផងដែរ ស្ពានដែលជាបន្ទុករបស់ខណ្ឌឫស្សីកែវគឺ ស្ពានបាឡេ ដែលជាស្ពានថ្មី ឆ្លងកាត់ទន្លេសាប ពីចំណុចឃ្លាំងស្តុកប្រេងសូគីម៉ិចផ្លូវជាតិលេខ៥ ក្នុងខណ្ឌឫស្សីកែវ ឆ្ពោះមកកាន់តំបន់អភិវឌ្ឍន៍ទីក្រុងរណបជ្រោយចង្វា ខណ្ឌជ្រោយចង្វា បានបើកសម្ពោធដាក់ឲ្យចរាចរណ៍ជាផ្លូវការ នៅរសៀលថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ក្រោយពីបានដំណើរការសាងសង់ អស់រយៈពេល៦ខែ កន្លងមកនេះ។ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានបញ្ជាក់ថា ស្ពានបាឡេឆ្លងកាត់ទន្លេសាប បានបញ្ចប់ការសាងសង់កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៨ និងបានសាកល្បងធ្វើតេស្តទ្រទម្ងន់នៃស្ពាន ដើម្បីធានាសុវត្ថិភាពនៃការធ្វើចរាចរណ៍ ការដំឡើងស្លាកសញ្ញាចរាចរណ៍ ការលាបគំនូសចរាចរណ៍ និងដំឡើងភ្លើងស្តុបថ្មី ដែលឈានទៅដាក់ឲ្យដំណើរការធ្វើចរាចរណ៍តែម្តង។ ស្ពានបាឡេថ្មីនេះមានទទឹង ១២ម៉ែត្រ និងបណ្តោយ ៥០០ម៉ែត្រ ដោយចំណាយថវិកាសាងសង់ ចំនួន៩លានដុល្លារ ប្រើពេលសាងសង់៦ខែ។ ពេលដំណើរការ រថយន្តទម្ងន់លើសពី១៥តោន និងមានកម្ពស់លើស ២,៨ម៉ែត្រ មិនអនុញ្ញាតឲ្យឆ្លងកាត់ឡើយ។

[33] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៦-២០១៨ ទំព័រទី៥៥

[34] សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩

នៅថ្ងៃអនាគតស្ពានបាឡេនេះ ត្រូវបានធ្វើការរុះរើ និងប្តូរទៅជាស្ពានបេតុងខ្សែកាបវិញ ដែលស្ពានបេតុងខ្សែកាបនេះ ឆ្លងកាត់ទន្លេសាប ចាប់ពីផ្លូវជាតិលេខ៥ ក្នុងតំបន់ឫស្សីកែវ ឆ្ពោះទៅតំបន់អភិវឌ្ឍន៍ជ្រោយចង្វា ផ្លូវជាតិលេខ៦ ត្រូវបានចុះបឋមសិលាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ គម្រោង២៨ខែ ប្រវែង ៩២២ម៉ែត្រ តួស្ពាន ២០៥ម៉ែត្រ ទទឹង ២០,៥ម៉ែត្រ។

ដោយក្នុងនោះ ស្ពានបាឡេឫស្សីកែវដែលជាស្ពាន សម្រាប់ប្រើប្រាស់បណ្តោះអាសន្នត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីឆ្នាំ២០១៨កន្លងទៅនោះ ឥឡូវនេះ ក្រុមហ៊ុនបានចាប់ផ្តើម ដំណើរការសាងសង់ស្ពានបេតុងខ្សែកាបឆ្លងកាត់ទន្លេសាបហើយ។ ស្ពានបេតុងខ្សែកាបដែលតភ្ជាប់ពីផ្លូវជាតិលេខ៥ ក្នុងតំបន់ឫស្សីកែវ ឆ្ពោះទៅកាន់តំបន់អភិវឌ្ឍន៍ជ្រោយចង្វារ ផ្លូវជាតិលេខ៦នេះ ត្រូវបានបញ្ចុះបឋមសិលាសាងសង់ តាំងពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧កន្លងទៅ។ ស្ពានបេតុងខ្សែកាបឆ្លងកាត់ទន្លេសាបនេះនឹងចំណាយ ថវិការសាងសង់ ៣៥លានដុល្លារសហរដ្ឋអាមេរិក ជាស្ពានទំហំធំ អាចបើកបរបាន៣គន្លងទៅ និង៣គន្លងមក។ ដោយឡែកចំពោះការសាងសង់ស្ពានបេតុងខ្សែកាបនេះ ក្រុមហ៊ុនកំពុងធ្វើការ ជាមួយនឹងអាជ្ញាធរខណ្ឌឫស្សីកែវ និងសាលារាជធានីភ្នំពេញ ដោយបានដោះស្រាយ ជាមួយនឹងគ្រួសារ ដែលរងការប៉ះពាល់អស់មួយចំនួនហើយ។ បើតាមការគ្រោងទុក មិនយូរប៉ុន្មានទៀតនោះទេ ស្ពានថ្មីនឹងកសាងឡើង ឲ្យតែគ្រួសារ ដែលប៉ះពាល់ចូលរួមសហការ។ ហើយស្ពាននេះ គ្រោងប្រើពេលសាងសង់ ២៨ខែ។ បើតាមរបាយការណ៍ពីមន្ទីរសាធារណការរាជធានីភ្នំពេញបញ្ជាក់ថា ស្ពានបេតុងខ្សែកាបនេះ មានប្រវែងសរុប ៩២២ ម៉ែត្រ មានតួស្ពានប្រវែង ៥០៩ម៉ែត្រ ទទឹង២០,៥ ម៉ែត្រ ដោយស្ថាបនាផ្លូវ តភ្ជាប់ត្រើយខាងលិច (ឫស្សីកែវ) ៣០៣ ម៉ែត្រ និងផ្លូវ ភ្ជាប់ត្រើយខាងកើត (ជ្រោយចង្វារ) ១១៥ម៉ែត្រ ។ ស្ពាននេះមានគន្លងផ្លូវបត់ ស្តាំចេញពីស្ពានទំហំ៥ម៉ែត្រ ទាំងសងខាងតួស្ពាន និងគន្លងផ្លូវបត់ឆ្វេងឡើងស្ពានទិសដៅចូលរាជធានីភ្នំពេញនឹង ត្រូវសាងសង់ជា ស្ពានហោះទំហំ៥ម៉ែត្រ ត្រង់ចំណុច ខាងមុខទីលានប្រជាធិបតេយ្យ ។ ស្ពានបេតុងអាមេខ្សែកាបនេះ ជាស្ពានដែលមាន គន្លងធ្វើចរាចរណ៍ចំនួន ២ខ្សែ ទៅមក ដែលយានជំនិះ គ្រប់ប្រភេទអាចបើកបរ ក្នុងល្បឿន ៩០ គីឡូម៉ែត្រក្នុងមួយម៉ោង ។ នៅលើស្ពាន មានគន្លងផ្លូវរត់ ៣,៧៥ម៉ែត្រចំនួន ២សរុប ៧,៥ម៉ែត្រ, ចិញ្ចើមស្ពាន សងខាង សម្រាប់ថ្មើរជើងទំហំ ១,២៥ ម៉ែត្រ និងមានសសរសម្រាប់ព្យួរខ្សែកាបកម្ពស់ ៣៦ម៉ែត្រ។ ស្ពាននេះ នឹងជួយរំដោះចរាចរលើផ្លូវជាតិលេខ ៦ និងផ្លូវជាតិ លេខ ៥ និងជួយសម្រួល ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងការដឹកជញ្ជូនទំនិញពីបណ្តាខេត្តមករាជធានីភ្នំពេញ និងពីរាជធានីភ្នំពេញ ទៅតាមបណ្តាខេត្តនានាដែលកំពុងមានកំណើនឥតឈប់ឈរ ជាពិសេសជួយកាត់បន្ថយការចំណាយរបស់ ប្រជាពលរដ្ឋក្នុងការធ្វើដំណើរពីតំបន់ឫស្សីកែវ ទៅតំបន់អភិវឌ្ឍន៍ជ្រោយចង្វារ ដែលនឹងធ្វើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែ

មានជីវភាពល្អប្រសើរឡើង។ គួរបញ្ជាក់ផងដែរថាការសាងសង់ស្ពាននេះមិនទាន់បានស្ថាបនានៅឡើយ ស្ថិតនៅក្នុងការគ្រោងរបស់សាលាក្រុងរាជធានីភ្នំពេញសហការជាមួយក្រុមហ៊ុន OCIC។[35]

### ១.២.១.២. ការអភិវឌ្ឍសំណង់លំនៅឋាន

#### ក. ការងារសំណង់ខណ្ឌឫស្សីកែវ និងជីផ្លី

ការងារសំណង់ខណ្ឌឫស្សីកែវ និងជីផ្លីមានដូចជាៈ

- ចុះរុះរើ សំយ៉ាបស័ង្កសី អាហារដ្ឋានមួយកន្លែង ដែលបានសាងសង់ដោយមិនបានលិខិតអនុញ្ញាតិពីអាជ្ញាធរមានសមត្ថកិច្ច និងសង់រំលោភលើចំណីផ្លូវជាតិលេខ៥ ស្ថិតនៅភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[36]
- ការរំកិល និងរុះរើចេញនូវរោង តូប សំយ៉ាប និងការដាក់តាំងលក់ទំនិញ-សម្ភារៈគ្រប់ប្រភេទឲ្យផុតពីចំណីផ្លូវ និងពីទ្រូងផ្លូវនៅជុំវិញផ្សារទំនប់ **ជិន អាន** ស្ថិតនៅផ្លូវលេខ៥៩៨ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[37]
- ចុះរុះរើ សំយ៉ាបស័ង្កសី របស់អាហារដ្ឋានមួយកន្លែង ដែលបានសាងសង់ដោយមិនបានលិខិតអនុញ្ញាតិពីអាជ្ញាធរមានសមត្ថកិច្ច និងសង់រំលោភលើចំណីផ្លូវជាតិលេខ៥ ស្ថិតនៅភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[38]
- ករណីសាងសង់ ឃ្លាំងសម្ភារៈ របស់ការដ្ឋានសំណង់ ដែលមិនមានលិខិតអនុញ្ញាតិសាងសង់ពីរដ្ឋបាលរាជធានីភ្នំពេញ ទំហំ ២០ម×៣០ម ស្ថិតនៅភូមិ៤ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[39]
- ចុះរុះរើ សំយ៉ាបស័ង្កសី របស់ហាងលក់អាគុយ និងអំពូលភ្លើង មួយកន្លែង ដែលបានសាងសង់ដោយមិនបានលិខិតអនុញ្ញាតិពីអាជ្ញាធរមានសមត្ថកិច្ច និងសង់រំលោភលើចំណីផ្លូវជាតិលេខ៥ ស្ថិតនៅភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[40]

[35] គេហទំព័រ http://wgccpn.com/index.php/rusey-keo/9-rusey-keo/4137-2018-05-09-09-25-07
[36] សជណ លេខ ៧៥៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[37] សជណ លេខ ១២៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[38] សជណ លេខ ៧៥៧ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[39] សជណ លេខ ៧៥៦ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[40] សជណ លេខ ៧៥២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ

- ការចុះវាស់វែងអចលនទ្រព្យដែលមិនទាន់បានចុះបញ្ជី របស់ប្រជាពលរដ្ឋមួយគ្រួសារ ដែលស្ថិតនៅផ្ទះលេខ៣៤០J ផ្លូវលំ ភូមិគង្គាផុស សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[41]
- ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ស្តីពីការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំ ដែលមានការពាក់ព័ន្ធនឹងក្បាលដីចំនួន០១ ស្ថិតនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[42]
- រុះរើសំណង់លំនៅដ្ឋាន ដែលបានសាងសង់រំលោភចូលដីចំណីផ្លូវជាតិលេខ៥ ដែលសំណង់លំនៅដ្ឋានមួយនេះ ស្ថិតនៅផ្លូវជាតិលេខ៥ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[43]
- រុះរើសំណង់ លំនៅដ្ឋាន របស់ម្ចាស់ការដ្ឋានសាងសង់លំនៅដ្ឋាន ដែលបាននឹងកំពុងសាងសង់រំលោភលើដីចំណីទន្លេសាបដែលជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅផ្លូវជាតិលេខ៥ ភូមិផ្សារតូច សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[44]
- ការចុះវាស់វែង កំណត់ទំហំដីវិវាទរបស់ប្រជាពលរដ្ឋ ០៩គ្រួសារ ដែលស្ថិតនៅក្នុងភូមិបឹងរាំង សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ[45]
- ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅសង្កាត់ទាំង ០៦ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ រយៈពេល១ឆ្នាំ
- ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី នៅសង្កាត់ទាំង០៦ ចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បញ្ចប់នាថ្ងៃទី៣១ ខែធ្នូ រយៈពេល១ឆ្នាំ[46]

### ខ. ការអភិវឌ្ឍបុរីក្នុងខណ្ឌឫស្សីកែវ

ជាការពិតណាស់ ការបង្កើតបុរីពិតជាបង្កនូវលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ព្រោះបុរីត្រូវបានសាងសង់ដោយមានលក្ខណៈស្តង់ដារនៃការសាងសង់ត្រឹមត្រូវ។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍបុរីអាចជួយសម្រួលដល់ការ តាំងទីលំនៅផងដែរ កាលណាបុរីអភិវឌ្ឍន៍រួចម្ចាស់បុរីអាចផ្តល់លទ្ធភាពដល់

[41] សជណ លេខ ៣២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[42] សជណ លេខ ៦៦៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[43] សជណ លេខ ៩០៥ ចុះថ្ងៃច័ន្ទ ១៣រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក្ត ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[44] សជណ លេខ ៦៥០ ចុះថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក្ត ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[45] សជណ លេខ ១៣០២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
[46] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៥-២០១៧ ទំព័រទី២៥

ប្រជាពលរដ្ឋ តាមរយៈការបង់រំលោះបន្តិចម្តងៗ ក្នុងការទទួលបានសំណង់គេហដ្ឋានសម្រាប់ស្នាក់នៅតាមលក្ខណៈស្តង់ដារ និងសមរម្យ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍបុរី អាចកាត់បន្ថយនូវបញ្ហា សំណង់អនាធិបតេយ្យ និងការកាន់កាប់ដីរដ្ឋខុសច្បាប់។ តួយ៉ាង ការអភិវឌ្ឍបុរីនៅខណ្ឌឫស្សីកែវមានដូចជា ៖

- បុរី ពិភពថ្មី របស់ លោកឧកញ៉ា ហុង ពីវ
- បុរី លីម ឈាងហាក់ របស់ លោកឧកញ៉ា លីម ឈាងហាក់
- បុរី វីឡាទួលសង្កែ របស់លោកឧកញ៉ា គង់ ប៊ុនហាវ
- បុរី ប៉េង ហួត របស់លោកឧកញ៉ា ប៉េង ហួត
- បុរី រិទ្ធិ របស់លោកឧកញ៉ា សួ សារិទ្ធិ
- បុរី អង្គរ របស់លោកឧកញ៉ា ព្រំ សុធី
- បុរី មុខវីតាល់ (បុរី ភ្នំពេញថ្មី) របស់លោកឧកញ៉ា ប៊ុន ហៃ
- កាំពុ បុរី របស់លោកឧកញ៉ា លឹម ហាំងឃុង
- បុរី ភ្នំពេញសុខសាន្ត របស់លោក ញឹក ផល្លា
- បុរី មនោរម្យ របស់លោក ហុក ឈាងលីម។[47]

### ១.២.២. ទិសដៅនៃការអភិវឌ្ឍខណ្ឌ

ជាទូទៅ រាល់ការអភិវឌ្ឍតែងតែមានគោលដៅទុកជាមុន ដើម្បីត្រៀមក្នុងការអភិវឌ្ឍ ការរៀបចំផែនការ ឬគម្រោងទុកជាមុនបែបនេះ គឺងាយស្រួលដើម្បីឲ្យមានដំណើរការល្អ ហើយគម្រោងនេះត្រូវបានសរសេរទុកក្នុងសៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ។ ទិសដៅទៅថ្ងៃខាងមុខ គឺមានទាំងគោលដៅ គោលបំណង ព្រមទាំងយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍នៅក្នុងខណ្ឌ។

#### ១.២.២.១. គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍ

គោលដៅ និងយុទ្ធសាស្ត្រទៅថ្ងៃខាងមុខ គឺមានគម្រោងរំពឹងទុកថា និងបានអភិវឌ្ឍន៍ឲ្យល្អនៅឆ្នាំខាងមុខចំពោះវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យអគ្គិសនី ទឹកស្អាត និងអនាម័យ ដីធ្លី សន្តិសុខ និងសណ្តាប់ធ្នាប់។

##### ក. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន

គម្រោងការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឆ្នាំ ២០១៩ ខាងមុខ មានគោលដៅរំពឹងថានឹងសម្រេចលើការស្ថាបនាផ្លូវរួចពី ៦០ភាគរយ ឡើងទៅ ៧០ភាគរយ ដែលមានដូចជា ផ្លូវបេតុងឆ្អឹងដែក ការស្ថាបនាផ្លូវគ្រួសក្រហម ឬខ្សាច់ភ្នំ និងការស្ថាបនានូវប្រព័ន្ធលូ ប្រឡាយផ្សេងៗទៀត។ ការអភិវឌ្ឍន៍លើវិស័យនេះមានគោលបំណងធ្វើយ៉ាងណាឱ្យមានផ្លូវស្អាតសម្រាប់ប្រើប្រាស់ដល់ប្រជាជនគ្រប់ៗរូបក្នុងការប្រកបរបរ អាជីវកម្មផ្សេងៗ ដោយធ្វើការលើកកម្ពស់ការដឹកជញ្ជូនប្រកបដោយសុវត្ថិ

[47] ដកស្រង់ចេញពីតារាងរាយនាមឈ្មោះឧកញ៉ា ម្ចាស់អាជីវកម្មបុរី និង សំណង់ផ្ទះល្វែងក្នុងមូលដ្ឋានខណ្ឌឫស្សីកែវ

ភាព និងពង្រឹងការផ្តល់សេវាយានយន្តឲ្យមានប្រសិទ្ធិភាព។ ចំណែកឯយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍វិស័យនេះ គឺជាគន្លឹះដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធិភាពសេដ្ឋកិច្ច ជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងជីវភាពរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ដូច្នេះវិស័យហេដ្ឋារចនាសម្ព័ន្ធ គឺជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋាន ត្រូវពង្រឹងការស្ថាបនា និង ជួសជុលផ្លូវ លូ ស្ពាន ឲ្យមានគុណភាព និងប្រសិទ្ធិភាពខ្ពស់។[48]

## ខ. ការអភិវឌ្ឍលើវិស័យអគ្គិសនី

ការរំពឹងទុកនាឆ្នាំខាងមុខនាឆ្នាំ២០១៩ ប្រជាពលរដ្ឋមានភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់ និងមានភ្លើងបំភ្លឺតាមផ្លូវសាធារណៈបាន ៥០ភាគរយ ដោយមានការ តបណ្តាញអគ្គិសនី និងមានការដាក់បង្គោលភ្លើងបំភ្លឺតាមផ្លូវសាធារណៈ។ ចំពោះការអភិវឌ្ឍវិស័យអគ្គីសនីនេះផងដែរ ក្នុងគោលបំណងជម្រុញឲ្យការផ្គត់ផ្គង់អគ្គិសនីរដ្ឋបានគ្រប់គ្រាន់ និងដើម្បីឲ្យប្រជាពលរដ្ឋទទួលបាននូវការប្រើប្រាស់នូវបណ្តាញអគ្គិសនីរដ្ឋបានគ្រប់គ្រាន់ និងគ្រប់ទីកន្លែងទាំងអស់។ ម្យ៉ាងទៀត ដើម្បីសម្រេចបាននូវគោលបំណងនេះ គឺត្រូវមានយុទ្ធសាស្ត្រសម្រេចលើការអភិវឌ្ឍវិស័យអគ្គិសនីនេះ ដោយធ្វើយ៉ាងណា ធ្វើការលើកកម្ពស់ទៅលើការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ដើម្បីឲ្យប្រជាជនទទួលបាននូវការប្រើប្រាស់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងគ្រប់ៗគ្នា។[49]

## គ. ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ

ចំពោះគោលដៅអភិវឌ្ឍន៍នាថ្ងៃខាងមុខនាឆ្នាំ២០១៩ ប្រជាពលរដ្ឋប្រមាណ ៨០ភាគរយមានទឹកស្អាតប្រើប្រាស់ ដោយខណ្ឌបានរៀបចំបណ្តាញទឹកស្អាត និងជីកអណ្តូងស្នប់ផ្សេងៗសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់។ ការអភិវឌ្ឍទៅលើវិស័យទឹកស្អាត និងអនាម័យនេះក្នុងគោលបំណងជម្រុញឲ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋឲ្យបានគ្រប់គ្រាន់ និងមានអនាម័យនៅគ្រប់ទីកន្លែងនៅក្នុងខណ្ឌដោយខណ្ឌបានធ្វើការអនុវត្តទៅតាមផែនការអភិវឌ្ឍន៍សម្រាប់រយៈពេល៥ឆ្នាំ ក្នុងការជម្រុញការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដល់ប្រជាពលរដ្ឋ។ មួយវិញទៀត ដើម្បីសម្រេចនូវគោលបំណងនេះ ក៏ត្រូវមាននូវយុទ្ធសាស្ត្រសម្រេចលើការអភិវឌ្ឍវិស័យនេះ ដោយជម្រុញឲ្យមានការតបណ្តាញទឹកស្អាត ការសង់និងជួសជុលអណ្តូងស្នប់ និងការស្តារស្រះ ដើម្បីឲ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅគ្រប់មូលដ្ឋានទាំងអស់។[50]

[48] សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩

[49] សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩

[50] សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩

### ឃ. ការអភិវឌ្ឍលើវិស័យដីធ្លី

ចំពោះគោលដៅអភិវឌ្ឍន៍វិស័យដីធ្លីក្នុងខណ្ឌឫស្សីកែវនាឆ្នាំ២០១៩ ប្រជាពលរដ្ឋ ៥០ភាគរយទៅ ៨០ភាគរយមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ដោយមានការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ និងផ្សព្វផ្សាយពីច្បាប់ភូមិបាល។ ក្នុងការអភិវឌ្ឍវិស័យដីធ្លីនេះ គឺដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះមហន្តរាយ ដែលបណ្តាលមកពីគ្រោះធម្មជាតិក្នុងនោះផងដែរ ចំពោះការអភិវឌ្ឍលើវិស័យដីធ្លី គឺមានយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍដោយធ្វើការផ្សព្វផ្សាយច្បាប់ភូមិបាលឲ្យបានទូលំទូលាយ និងពីសារៈសំខាន់នៃការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិ ដោះស្រាយ និងសម្របសម្រួលទំនាស់ដីធ្លី។[51]

### ង. ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ចំពោះគោលដៅអភិវឌ្ឍន៍វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈខណ្ឌឫស្សីកែវ ទៅថ្ងៃអនាគត ដោយរំពឹងថា នឹងសម្រេចបានក្នុងឆ្នាំ២០១៩ ខាងមុខ ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសុវត្ថិភាព ដោយខណ្ឌមានការអភិវឌ្ឍទៅលើ៖

- ពង្រឹងសកម្មភាពរក្សាសន្តិសុខសណ្តាប់ធ្នាប់ ក្នុងមូលដ្ឋាន
- ទប់ស្កាត់ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- បង្ក្រាបអំពើចោរកម្ម និងល្បែងស៊ីសងគ្រប់ប្រភេទ
- ពង្រឹងការប្រើប្រាស់នូវអាវុធខុសច្បាប់
- ប្រមូលក្រុមជនពាលដើម្បីអប់រំ
- ពង្រឹងការងារគ្រប់គ្រងអ្នកស្នាក់នៅបណ្តោះអាសន្ន
- សង់/ជួសជុលប៉ុស្តិ៍ប្រជាការពារ
- ពង្រឹងវិធានការណ៍ ការពារគ្រោះថ្នាក់ចរាចរណ៍
- ការពង្រឹងសមត្ថភាព ការពារ ទប់ទល់គ្រោះអគ្គិភ័យ

ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងគោលបំណង បង្កើនការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដើម្បីធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋក្នុងខណ្ឌរស់នៅប្រកបដោយ សន្តិសុខ សុវត្ថិភាពបុគ្គល និងសុវត្ថិភាពសាធារណៈ គ្មានភាពភ័យខ្លាច ស្ងៀមស្ងាត់ ជាពិសេសនោះគឺ ការរស់នៅប្រកបដោយសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។ ដូច្នេះ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ខណ្ឌឫស្សីកែវ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ទៅលើវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានដូចខាងក្រោម៖

- ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន

[51] សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩

- ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន
- អនុវត្តន៍គោលនយោបាយ ឃុំ សង្កាត់ មានសុវត្ថិភាព
- រៀបចំសណ្តាប់ធ្នាប់សាធារណៈ
- ជម្រុញការចុះធ្វើរដ្ឋបាល។[52]

[52] សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩

# ជំពូកទី២

# ការរៀបចំសោភណ្ឌភាព

# ខណ្ឌឫស្សីកែវ

# ឆ្នាំ២០១៥ ដល់២០១៨

# ជំពូកទី២
# ការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥ ដល់ ២០១៨

តាមការវិភាគពីស្ថានភាព ក៏ដូចជាបញ្ហាសោភណ្ឌនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សរបញ្ជាក់ឲ្យឃើញថា ការរៀបចំសោភណ្ឌភាពនៅក្នុងខណ្ឌឫស្សីកែវនៅតាមទីសាធារណៈត្រូវបានសាលាខណ្ឌធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយសាលាខណ្ឌបានធ្វើការរក្សាភាពស្រស់ស្អាត ល្អ ហ្មត់ហ្មងព្រមទាំងថែរក្សានូវសោភណ្ឌភាពពេលថ្ងៃ និងពេលយប់ជូនប្រជាពលរដ្ឋក្នុងការរស់នៅផងដែរ។ ប៉ុន្តែបញ្ហាសោភណ្ឌក្នុងខណ្ឌឫស្សីកែវ ក៏នៅតែជាបញ្ហាចោទសម្រាប់សាលាខណ្ឌនៅឡើយ ដោយសារតែប្រជាពលរដ្ឋមួយចំនួនគាត់មិនបានយល់ដឹងច្បាស់ពីច្បាប់ និងប្រជាពលរដ្ឋមួយចំនួនបានបំពានច្បាប់ដែលជាហេតុធ្វើឲ្យសោភណ្ឌភាពក្នុងខណ្ឌមិនទាន់មានភាពល្អប្រសើរ។ បញ្ហាទាំងនេះហើយ គឺជាបញ្ហាចោទដ៏សំខាន់មួយ ដែលអាជ្ញាធរខណ្ឌគួរតែប្បីធ្វើការដោះស្រាយបញ្ហាឲ្យទាន់សភាពការណ៍ ដើម្បីការពារនូវសោភណ្ឌភាពក្នុងខណ្ឌឲ្យមានភាពល្អប្រសើរឡើង។

ម្យ៉ាងវិញទៀត មុននឹងឈានដល់ការរៀបចំ ឬការអភិវឌ្ឍត្រូវពិនិត្យមើលទៅលើប្លង់គោលជាមុនសិនក្នុងការរៀបចំសោភណ្ឌភាពឲ្យមានរបៀបរៀបរយ។

ប្លង់គោលជាឯកសារ ឬគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍរាជធានីដល់ឆ្នាំ២០២០។ ប្លង់គោល ជាប្លង់គ្រឹះ និងជាអ្នកតម្រង់ទិសក្នុងការរៀបចំបែងចែក កំណត់ផ្ទៃដី សម្រាប់តំបន់សំណង់ តំបន់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍ ក្នុងគោលដៅថែរក្សានូវសោភណ្ឌភាពនៅតំបន់នានា ដែលស្ថិតក្នុងការកំណត់របស់ប្លង់គោល។ [53]

ដូចមានក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រង់មាត្រា១៧ វាក្យខណ្ឌទី២បានចែងពីស្ថានភាពដីដែលមិនអាចសាងសង់ ដែលធ្វើឲ្យប៉ះពាល់ដល់សោភណ្ឌភាពបានចែងថា៖

- មិនអនុញ្ញាតិឲ្យសាងសង់បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិស្ថាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភណ្ឌភាពបច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ។[54]

ចំណែកឯមាត្រា១២ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់បានចែងថា៖

រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈត្រូវហាមឃាត់មិនឲ្យសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ:

- ទីបម្រុងទុកទឹក និងទំនប់ទឹក

[53] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី១៩៤

[54] មាត្រា១៧ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤

- ទីបម្រុងជីករ៉ែ និងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិរក្សន៍
- ដីបម្រុងទុកសម្រាប់ផ្លូវ បម្រុងសម្រាប់ចំណីផ្លូវ និងដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង និង អាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រមទាំងឆ្នេរច្រាំង។[55]

## ២.១. ទិដ្ឋភាពទូទៅនៃការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ

នៅដើមទស្សវត្សឆ្នាំទី១០ នៃសតវត្សទី២១ ទីក្រុងភ្នំពេញជាទីក្រុងមួយឈរជួរទី៣១៤ ក្នុងចំណោមទីក្រុងជាង៤០០ នៃទីក្រុងនានានៅលើពិភពលោក ដែលក្នុងនោះទីក្រុងភ្នំពេញមានប្រជាជនកំពុងរស់នៅលើសពីមួយលាននាក់ (ទីក្រុងភ្នំពេញមានចំនួនប្រជាជន ១.៣លាននាក់)។[56] សន្ទុះនៃកំណើនប្រជាជនបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំនៅទីក្រុងភ្នំពេញ ជាកត្តាមួយដែលជម្រុញឲ្យដំណើរនគរូបនីយកម្មបានកើតឡើងដោយឯកឯង ទន្ទឹមនឹងទីក្រុងនានាមិនទាន់បានធ្វើផែនការក្នុងការប្រើប្រាស់ដីធ្លី។ ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រដ្ឋាភិបាលកម្ពុជាបានបង្កលក្ខណៈឲ្យប្រជាជនខ្មែរដែលកំពុងរស់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ធ្វើមាតុភូមិនិវត្តន៍ចូលមករស់នៅក្នុងទឹកដីកម្ពុជា ដែលភាគច្រើនក្រោយមកពួកគាត់បានវិលមករស់នៅក្នុងទីក្រុង និងទីប្រជុំជនវិញ។ ចលនានេះ បានដើរទន្ទឹមគ្នានឹងលំហូរប្រជាជនចេញពីទីជនបទ ចូលមករស់នៅក្នុងទីក្រុងនានា ជាពិសេសក្រុងភ្នំពេញ និងបានបង្កើតឲ្យមានការតាំងទីលំនៅលើដីរដ្ឋមានដូចជា លើសួនច្បារសាធារណៈ លំហសាធារណៈ ដីឯកជនរបស់រដ្ឋ ដីរបស់បុគ្គល ដីវត្តអារាម លើប្រឡាយទឹក និងនៅលើទីតាំង ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពដូចជា លើប្រព័ន្ធលូបង្ហូរទឹកកាកសំណល់ និងលើទីតាំងដែលងាយរងគ្រោះថ្នាក់ ដូចជាលើដីចំណីផ្លូវ ផ្លូវរថភ្លើង លើទំនប់ទឹក ការពារទឹកជំនន់ លើច្រាំងទន្លេ ស្ទឹង ព្រែក លើដំបូលទេវ៉ាស...។[57]

ដោយឡែកនៅទីក្រុងភ្នំពេញ និងនៅតាមទីប្រជុំជននៃទីរួមខេត្តធំៗ មានចលនាប្រជាជនបានធ្វើចលនាបម្លាស់ទីចូលមកតាំងនៅជាបន្តបន្ទាប់ ជាពិសេសនៅតាមតំបន់ជាយក្រុង បង្កើតជាតំបន់រស់នៅគ្មានសណ្តាប់ធ្នាប់។ បច្ចុប្បន្ននៅតាមប្លុកខ្លះ តាមសង្កាត់ក្នុងខណ្ឌមួយចំនួន គេសង្កេតឃើញនៅមានផ្ទះខ្លះសង់បិទផ្លូវ ឬសង់លើដីចំណីផ្លូវ ដែលធ្វើឲ្យផ្លូវមានសភាពតូចចង្អៀត ឬសង់ពង្រីកបន្ថែមលើសំណង់ចាស់ដោយគ្មានច្បាប់អនុញ្ញាតិ និងបានប្រើប្រាស់ដីគ្មានសណ្តាប់ធ្នាប់ ឬសង់ឡើងដោយខ្លួនឯង ស្អេក

[55] មាត្រា១២ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤

[56] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ រ៉ឌី ត្រង់ទំព័រទី១២៥

[57] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ រ៉ឌី ត្រង់ទំព័រទី១២៧

ស្តុះ ចង្អៀត គ្មានជួរតម្រង់ ធ្វើឲ្យផ្លូវគ្មានចិញ្ចើម រៀច ក្រងិកក្រងក់ និងតូចចង្អៀតពេលមានអាសន្ន ឬគ្រោះអគ្គិភ័យកើតឡើង មិនអាចផ្តល់លទ្ធភាពឲ្យរថយន្តពន្លត់អគ្គិភ័យចូលប្រតិបត្តិការបានឡើយ។[58]

ចាប់តាំងពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ នគរូបនីយកម្មបានកើតឡើងដោយឯកឯង អាស្រ័យដោយចលនាបម្លាស់ទីចូលក្រុងជួបផ្សំនឹងកត្តាសេដ្ឋកិច្ច និងសង្គមកិច្ចដែលទើបមានជីវិតរស់ឡើងវិញ។ ចលនាបម្លាស់ទីចូលក្រុងនេះកើតមានជាបន្តបន្ទាប់ស្របពេលដែលប្រជាពលរដ្ឋមួយចំនួន ដែលធ្លាប់តែរស់នៅតំបន់ជនបទមិនទាន់មានការយល់ដឹងពីច្បាប់ទម្លាប់ក្នុងការរស់នៅក្នុងទីក្រុង និងទីប្រជុំជន និងនៅមានការខ្វះចន្លោះក្នុងការអនុវត្តច្បាប់។ ដោយប្រទេសកម្ពុជា ជាប្រទេសដែលទើបរួចផុតពីសង្គ្រាមផង និងរបបប្រល័យពូជសាសន៍ផង ជាកត្តាមួយដែលធ្វើឲ្យព្រឹត្តិការណ៍ទាំងឡាយក្នុងសង្គមតែងកើតឡើងមុនមានច្បាប់។ ករណីខ្លះកើតឡើងមកពីប្រជាជនដែលធ្លាប់រស់នៅជនបទ មិនបានយល់ដឹងពីច្បាប់ដែលធ្វើឲ្យការអនុវត្តរបស់ពួកគាត់ប្រព្រឹត្តផ្ទុយពីច្បាប់ដែលបានចែង និងការអនុវត្តរបស់ពួកគាត់តែងតែមានការខុសឆ្គង។ ទន្ទឹមនឹងនេះ ក៏មានជនមួយចំនួនតូច ដែលដឹងពីច្បាប់ហើយ តែនៅធ្វើបំពានដោយតាំងទីលំនៅ និងសាងសង់គ្មានការអនុញ្ញាតិ ឬធ្វើទៅតាមចិត្តដែលចង់បាន។ បើពិនិត្យមើលលើប្លង់ស្ថាបត្យកម្មវិញ ប្រជាពលរដ្ឋនៅមានការខ្វះខាតក្នុងការគោរពច្បាប់លើប្លង់អនុញ្ញាតិការសាងសង់ ក៏ដូចជាជួរតម្រង់ ដែលបានបង្ហាញពីការមិនឯកភាពគ្នា ដោយមានសំណង់ខ្លះលយចេញ ខ្លះលយចូល ធ្វើឲ្យបាត់បង់នូវសោភណ្ឌភាព និងក៏ជាការឆ្លុះបញ្ចាំងឲ្យឃើញ ការអនុវត្តច្បាប់នៅមានកម្រិត ជាពិសេសនៅពេលដែលព្រះរាជាណាចក្រកម្ពុជា មិនទាន់មានការឯកភាពជាតិនៅឡើយ។[59]

ដើម្បីទប់ស្កាត់នូវបញ្ហានៃការមកតាំងទីលំនៅខុសច្បាប់បន្តទៀត ក្នុងទីក្រុង និងទីប្រជុំជន រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន។ សារាចរនេះ មានអត្ថន័យដើម្បីទប់ស្កាត់កុំឲ្យមានការតាំងទីបែបនេះជាថ្មីទៀតនៅក្នុងរាជធានី ទីក្រុងនានា និងទីប្រជុំជន ក្នុងន័យរក្សាបាននូវសោភណ្ឌភាព និងបរិស្ថានក្រុង។[60] នៅអាណត្តិទី២ នៃរដ្ឋសភាជាតិ រាជរដ្ឋាភិបាលបានបង្កើត ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ក្រោយពីការបង្កើតក្រសួង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងបានខិតខំបង្កើតច្បាប់ និងក្របខណ្ឌគតិយុត្តជាច្រើនដើម្បីទុកឲ្យប្រជាពលរដ្ឋអនុវត្តន៍ច្បាប់។ ដូចនេះ រាល់សំណង់នានា ដែលនឹងត្រូវសង់ត្រូវតែគោរពទៅតាមបទដ្ឋានដែលច្បាប់បានដាក់ចុះ។ ទន្ទឹមនឹងនេះ សំណង់ដែលខុសច្បាប់ត្រូវមានការ

[58] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វឌី ត្រង់ទំព័រទី១៣៦

[59] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វឌី ត្រង់ទំព័រទី១៣៤, ១៣៥

[60] សៀវភៅប្រវត្តនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វឌី ត្រង់ទំព័រទី១២៩

កែលម្អឡើងវិញ ដើម្បីឲ្យស័ក្តិសមទៅនឹងនិយមន័យនៃទីក្រុង និងដើម្បីប្រែក្លាយមុខមាត់ទីក្រុងឲ្យមានសោភណ្ឌភាព និងសុខុមាលភាព។[61]

បើយើងត្រឡប់មើលទៅមុនឆ្នាំ១៩៩០វិញ ក្រុងភ្នំពេញជាទីស្ងប់ស្ងាត់នៅពេលថ្ងៃ បើពេលយប់ គឺមានសភាពងងឹត ដោយសារភ្លើងអគ្គិសនីមិនអាចបម្រើការបានគ្រប់គ្រាន់។ តែបច្ចុប្បន្ន គេសង្កេតឃើញថ្នាក់ដឹកនាំសាលារាជធានីភ្នំពេញមានការមមាញឹកក្នុងការពង្រីកផ្លូវជាបន្តបន្ទាប់ និងមានការបំពាក់ដោយកម្រាលឥដ្ឋលើចំណីផ្លូវ និងរក្សាបាននូវតំបន់បៃតងតាមដងផ្លូវ ដើម្បីធានាបាននូវសោភណ្ឌភាព និងបរិស្ថានទីក្រុង។ ក្នុងនោះផងដែរ រាជធានីភ្នំពេញនាពេលរាត្រីជាទីក្រុងមួយ ដែលប្រកបដោយភ្លើងពណ៌ចម្រុះមានមនុស្សម្នាទៅមកកកកុញ។ ផ្សារទំនើបកើតឡើងហូរហែរ មានភ្ញៀវជាតិ បរទេស ចេញចូលទិញ និងបរិភោគ ដែលជាកត្តាមួយបង្ហាញឲ្យឃើញពីសង្គមកម្ពុជាមានការអភិវឌ្ឍឈានឡើងយ៉ាងលឿនជាបន្តបន្ទាប់ពីមួយឆ្នាំ ទៅមួយឆ្នាំគួរឲ្យមានមោទនភាព។ នៅពេលថ្ងៃសកម្មភាពសេដ្ឋកិច្ចចរាចរណ៍ខ្វាត់ខ្វែងទៅនឹងមកយ៉ាងមមាញឹក។ ភ្នំពេញមានផ្លូវកាត់ខ្វាត់ខ្វែងជាក្រឡាចក្រត្រង្គ តែនៅពេលដែលល្បឿននគរូបនីយកម្មនៅមានកម្រិត មនុស្សម្នាច្រើនធ្វើចរាចរតាមមហាវិថីធំៗតែប៉ុណ្ណោះ ផ្ទុយពីបច្ចុប្បន្ន សកម្មភាពផ្លូវទាំងឡាយក្លាយជាអ៊ូអរ និងជាញឹកញាប់មានការកកស្ទះបានកើតឡើង។ ទន្ទឹមនឹងបញ្ហាចរាចរណ៍ ដែលពីមួយថ្ងៃទៅថ្ងៃកាន់តែមានការកកស្ទះនៅតាមផ្លូវមួយចំនួន សាលាក្រុងភ្នំពេញបានបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដើម្បីបញ្ចៀសការកកស្ទះ ដោយបានសាងសង់ស្ពាននៅតាមច្រកផ្លូវចេញទៅក្រៅក្រុងជាច្រើន។[62]

### ២.១.១. មូលហេតុដែលនាំឲ្យមានការរៀបចំ

ជាទូទៅរាល់ការអភិវឌ្ឍ ឬការរៀបចំអ្វីមួយ តែងតែមាននូវការរៀបចំផែនការក្នុងការធ្វើសកម្មភាពជាមុនសិនទើបការអភិវឌ្ឍនោះទទួលបាននូវលទ្ធផលដូចការគ្រោងទុក។ ការធ្វើផែនការសកម្មភាព គឺជាគោលការណ៍ដ៏សំខាន់មួយក្នុងការកំណត់ពីគោលដៅដែលត្រូវធ្វើ។ យ៉ាងណាមិញ បើយើងក្រឡេកទៅមើលការអភិវឌ្ឍនៅតាមតំបន់នានា ដូចជា ភូមិ ឃុំ ស្រុក ខណ្ឌ ក្នុងប្រទេសនានា ក៏ដូចជាតំបន់នានានៅក្នុងប្រទេសកម្ពុជារបស់យើង តែងតែមានការរៀបចំនូវគម្រោង ឬផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍ក្នុងតំបន់នោះ ទៅតាមស្ថានភាពជាក់ស្តែងនៃតំបន់នោះ ដោយក្នុងគោលបំណងធ្វើឲ្យទិដ្ឋភាពក្នុងតំបន់នោះប្រកបដោយភាពស្រស់ស្អាត ដែលជាតម្រូវការរបស់តំបន់នោះផងដែរ។

ជាក់ស្តែង បើយើងធ្វើការក្រឡេកមើលស្ថានភាពក្នុងខណ្ឌឫស្សីកែវក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយមកនេះ ខណ្ឌបានធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍន៍តំបន់នានាក្នុងខណ្ឌ ជាពិសេស គឺធ្វើការអភិវឌ្ឍទៅលើសោភណ្ឌភាពរបស់ខណ្ឌជាចម្បង។ ក្នុងការរៀបចំនូវសោភណ្ឌភាពខណ្ឌ

---

[61] សៀវភៅប្រវត្តនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វ៉ឌី ត្រង់ទំព័រទី១៣៦

[62] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វ៉ឌី ត្រង់ទំព័រទី១៣៧, ១៣៨

នេះ គឺអាស្រ័យទៅលើហេតុផលជាច្រើន ដែលនាំឲ្យមានការរៀបចំយ៉ាងយកចិត្តទុកដាក់ពីអាជ្ញាធរខណ្ឌ ចំណែកឯផល ដែលទទួលបានពីការរៀបចំនោះមានដូចជា ធ្វើឲ្យខណ្ឌមានភាពស្រស់ស្អាត មានផាសុខភាព ជាពិសេសគឺមានការកែលម្អពីភាពអនាធិបតេយ្យក្នុងខណ្ឌ ប្រែក្លាយមកជាភាពស្រស់ស្អាត ដែលធ្វើឲ្យប្រជាពលរដ្ឋក្នុងខណ្ឌផ្ទាល់ មានការរស់នៅដោយអនាម័យ សុខ សុវត្ថិភាព និងមានអារម្មណ៍ស្រស់ថ្លាជាមួយនឹងសោភណ្ឌភាពរបស់ខណ្ឌ។

ដូច្នេះហើយ បុព្វហេតុក្នុងការរៀបចំនូវសោភណ្ឌភាពរបស់ខណ្ឌឫស្សីកែវ គឺអាស្រ័យដោយកត្តាមួយចំនួនដូចខាងក្រោមៈ

### ២.១.១.១. តម្រូវការរបស់ប្រជាជន

ជាការពិតណាស់ ប្រជាជន គឺជាកោសិកានៃសង្គម ដែលជាកម្លាំងចលករដ៏សំខាន់មួយក្នុងការចូលរួមអភិវឌ្ឍសង្គមជាតិរបស់ខ្លួន។ កាលណាតំបន់មួយមានការកើនឡើងនូវចំនួនប្រជាជន នោះតម្រូវការក៏កាន់តែកើនឡើងបន្ថែមទៀតផងដែរ។ តម្រូវការរបស់ប្រជាជន គឺជាដើមចមដែលញ៉ាំងឲ្យមានការអភិវឌ្ឍ។ ជាក់ស្តែង នាពេលបច្ចុប្បន្ន ខណ្ឌឫស្សីកែវមានប្រជាជនមានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់ពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រៅពីតម្រូវការផ្នែកសេដ្ឋកិច្ច ប្រជាជនក្នុងខណ្ឌតែងតែចង់មានការរស់នៅប្រកបទៅដោយផាសុខភាព មានសួនច្បារ មានចិញ្ចើមផ្លូវសម្រាប់ថ្មើរជើង ជាពិសេស គឺមានអនាម័យល្អនៅក្នុងខណ្ឌ។

ខណ្ឌឫស្សីកែវត្រូវបានគេមើលឃើញថាមានការកើនឡើងទាំងតម្រូវការ និងការផ្គត់ផ្គង់លំនៅដ្ឋានដែលធ្វើឲ្យខណ្ឌមួយនេះក្លាយជាតំបន់លំនៅដ្ឋានដ៏សំខាន់ក្នុងឆ្នាំ២០១៦។ នេះក៏ព្រោះតែការពង្រីកក្រុងនៃតំបន់ជាយក្រុងជាច្រើនដើម្បីឲ្យឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាជនដែលកើនក្នុងទីក្រុង។[63] តម្រូវការសំណង់លំនៅដ្ឋាន បានធ្វើឲ្យខណ្ឌធ្វើការបើកឱកាសឲ្យមានការវិនិយោគពីសំណាក់បុគ្គលសាធារណៈក្នុងការសាងសង់សំណង់ផ្ទះល្វែងក៏ដូចជា បុរីនានាក្នុងខណ្ឌដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ។ សន្ទុះនៃសំណង់លំនៅដ្ឋានបានកើនឡើង តម្រូវឲ្យខណ្ឌបង្កើតនូវច្បាប់នានាដើម្បីធ្វើការគ្រប់គ្រងទៅលើសំណង់ទាំងនោះ ដោយមានជួរតម្រង់ មានការតុបតែង ដោយមានការបំពាក់ភ្លើងបំភ្លឺនាពេលរាត្រី មានសភាពភ្លឺថែងចាំងតាមដងផ្លូវ ដែលនេះកាន់តែធ្វើឲ្យសោភណ្ឌភាពរបស់ខណ្ឌកាន់តែមានភាពស្រស់ស្អាត និងមានភាពទាក់ទាញ។

### ២.១.១.២. តម្រូវការរបស់ខណ្ឌ

ជាទូទៅ រាល់ខណ្ឌនីមួយៗតែងតែចង់មានការអភិវឌ្ឍន៍សម្រាប់ខណ្ឌរបស់ខ្លួនដើម្បីឲ្យខណ្ឌមានការចាប់អារម្មណ៍ពីសំណាក់ប្រជាពលរដ្ឋ ព្រមទាំងមជ្ឈដ្ឋាននានា។ យ៉ាងណាមិញ មុននឹងឈានដល់ការសម្រេចនូវចក្ខុវិស័យក្នុងការអភិវឌ្ឍ ខណ្ឌនីមួយៗបានធ្វើការរៀបចំនូវផែនការសកម្មភាពនានា ដើម្បីធ្វើ

---

[63] គេហទំព័រ realestae.com.kh ចូលមើលថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩

យ៉ាងណាឲ្យមានការឆ្លើយតបទៅនឹងគោលបំណង និងតម្រូវការរបស់ខណ្ឌ។ យ៉ាងណាមិញ បើយើងក្រឡេកមើលមកខណ្ឌឫស្សីកែវវិញ ខណ្ឌបានធ្វើការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ ព្រមទាំងធ្វើការកែប្រែនូវសោភណ្ឌភាពក្នុងខណ្ឌទាំងមូលឲ្យមានភាពស្រស់ស្អាត មានអនាម័យ នៅតាមតំបន់នានា ដូចជាតាមសំណង់លំនៅឋាន តាមដងផ្លូវ ដើម្បីធ្វើឲ្យខណ្ឌមានភាពទាក់ទាញដល់សាធារណៈជន ជាពេសសនោះគឺ ក្លាយជាខណ្ឌដែលមានភាពស្រស់ស្អាតក្នុងបណ្ដាខណ្ឌនានាដែលមាននៅក្នុងរាជធានីភ្នំពេញ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន ខណ្ឌឫស្សីកែវ បានចូលរួមក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ដែលបានរៀបចំដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលហៅកាត់ថា គ.ជ.វ.ទ។ ចលនាប្រឡងប្រណាំងទីក្រុងស្អាតរៀបចំឡើងក្នុងគោលបំណងលើកកំពស់ សោភណ្ឌភាពបរិស្ថាន អនាម័យ និងសណ្ដាប់ធ្នាប់ ទីក្រុង ខណ្ឌ (២៦ទីក្រុង ១២ខណ្ឌ នៃរាជធានីភ្នំពេញ) នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេស ចូលរួមក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល។ ដើម្បីជាការលើកទឹកចិត្ត រាជរដ្ឋាភិបាលនឹងផ្ដល់រង្វាន់ដល់ទីក្រុង ខណ្ឌ ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងអភិវឌ្ឍន៍ទីក្រុងខ្លួន ជាពិសេសដើម្បីថែរក្សាការពារបរិស្ថាន និងបានជម្រុញឲ្យតួអង្គសំខាន់ៗក្នុងវិស័យទេសចរណ៍ បងប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធបានចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងបរិស្ថាននៅតាមបណ្ដាទីក្រុង។ ក្រៅពីរង្វាន់ ដែលផ្ដល់ដោយរាជរដ្ឋាភិបាលឲ្យ ទីក្រុង ខណ្ឌបេក្ខភាព ក៏នឹងទទួលបានស្លាកសញ្ញាសម្គាល់ទីក្រុងស្អាត ដែលចេញដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលហៅកាត់ថា គ.ជ.វ.ទ ផងដែរ ក្រោយពីទទួលបានវិញ្ញាបនបត្រ ដែលទទួលស្គាល់ដោយនាយករដ្ឋមន្ត្រី។[64]

បន្ទាប់ពីមានការបង្កើតឡើងនូវការប្រឡងប្រណាំងទីក្រុងស្អាត ខណ្ឌបានចូលរួមការប្រកួតប្រជែងជាមួយបណ្ដាក្រុង ខណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយទទួលបានជ័យលាភីការប្រលងប្រណាំងទីក្រុងស្អាតលើកទី២ ដោយទទួលបាន ឡាបិលរូបផ្កាវិដ្ឋូល១ទង ដែលជាសមិទ្ធិផលរបស់ខណ្ឌ។ សមិទ្ធិផលដែលទទួលបាននេះបានកើតចេញពីការខិតខំប្រឹងប្រែងរបស់ខណ្ឌ ក៏ដូចជាមានការសហការពីប្រជាពលរដ្ឋ បានធ្វើឲ្យខណ្ឌមានសោភណ្ឌភាពស្រស់ស្អាត មានបរិស្ថានល្អស្ទើរតែគ្រប់ទីកន្លែង ដែលជាវាតម្រូវការរបស់ខណ្ឌក្នុងការធ្វើយ៉ាងណាឱ្យខណ្ឌរបស់ខ្លួនមានការអភិវឌ្ឍផងដែរ។

### ២.១.១.៣. ផលវិបាកនៃការបាត់បង់សោភណ្ឌភាព

ជាទូទៅសោភណ្ឌភាព គឺសំដៅទៅលើភាពល្អ ហ្មត់ហ្មង។[65] កាលណាទីកន្លែងមួយបាត់បង់នូវសោភណ្ឌភាព នោះវានឹងបណ្ដាលឲ្យតំបន់នោះក្លាយជាតំបន់ដែលមិនមានភាពស្រស់ស្អាត មិនមានភាពទាក់ទាញសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះថែមទៀតផងដែរ។ ម្យ៉ាងទៀត តំបន់ដែលបាត់បង់

[64] គេហទំព័រ www.cambodiacleancity.gov.kh ចូលមើលថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩

[65] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រទី០១

នូវសោភណ្ឌភាពមិនត្រឹមតែធ្វើឱ្យប្រជាជននៅក្នុងតំបន់ទាំងនោះមានអារម្មណ៍មិនល្អប៉ុណ្ណោះទេថែមទាំងបាត់បង់នូវចំណូលសេដ្ឋកិច្ចផងដែរ ព្រោះកាលណាតំបន់នោះស្រស់ស្អាតធ្វើឱ្យមានភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិមកកំសាន្តច្រើនកុះករដែលធ្វើឱ្យប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅតំបន់ទាំងនោះមានការកើនឡើង ប៉ុន្តែផ្ទុយទៅវិញកាលណាតំបន់ទាំងនោះបាត់បង់នូវការរៀបចំឱ្យមានភាពល្អ ត្រឹមត្រូវអាចធ្វើឱ្យបាត់បង់នូវភ្ញៀវទេសចរណ៍ដូចគ្នា ដែលជាហេតុធ្វើឱ្យចំណូលធ្លាក់ចុះដូចគ្នាដែរ។ បើយើងនិយាយពីការបាត់បង់នូវសោភណ្ឌភាពវិញ ឃើញថា ពិតជាមាននូវផលប៉ះពាល់យ៉ាងច្រើន មិនត្រឹមតែប្រជាពលរដ្ឋដែលរស់នៅតំបន់ទាំងនោះទេ ក៏ប៉ុន្តែអាចប៉ះពាល់ទៅដល់មុខមាត់ប្រទេស ក្រុង ស្រុក ខណ្ឌនោះទៀតផង។ មួយវិញទៀត ការបាត់បង់នូវសោភណ្ឌភាពអាចធ្វើឱ្យបាត់បង់នូវអាកាសធាតុ និង បរិយាកាសល្អបរិសុទ្ធពីធម្មជាតិ ដោយសារតែមានការចោលសំរាម ផ្តេសផ្តាស ពាសវាល ពាសកាល ដោយសារតែមិនទាន់មានការរៀបចំឱ្យបានល្អត្រឹមត្រូវ។ ម្យ៉ាងទៀត កាលណាបាត់បង់នូវសោភណ្ឌភាព ធ្វើឱ្យបាត់បង់នូវភាពទាក់ទាញ និងភាពរស់រវើករបស់តំបន់មួយនោះមួយផ្នែកធំ ដូចជា បាត់បង់នូវភាពស្អាត ភាពបៃតងដែលក្នុងនោះមិនសូវមានការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាន។ តួយ៉ាងចំពោះការប្រលងប្រណាំងទីក្រុងស្អាតក៏មានការដាក់ពិន្ទុទៅលើការរៀបចំនូវសោភណ្ឌភាពឱ្យបានល្អ រួមទាំងបញ្ហាអនាម័យ សេវាកម្មល្អទៀតផង។ កត្តាទាំងអស់នេះហើយទើបជម្រុញឱ្យមានការរៀបចំនូវសោភណ្ឌភាពនៅគ្រប់ខណ្ឌទាំងអស់ក្នុងរាជធានីភ្នំពេញ ជាពិសេសខណ្ឌឫស្សីកែវក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការរៀបចំនូវសោភណ្ឌភាពខណ្ឌ ដើម្បីឱ្យទទួលបាននូវភាពស្រស់ស្អាត។ ក្នុងនោះផងដែរ ខណ្ឌក៏បានធ្វើការណែនាំប្រជាពលរដ្ឋទាំងអស់ក្នុងពេលយកសំរាមទៅបោះចោល នៅតាមដងផ្លូវទីសាធារណៈ នោះនឹងមានការផាកពិន័យ ដោយផ្តើមចេញពីការផ្សព្វផ្សាយអប់រំឱ្យប្រជាពលរដ្ឋចូលរួមសហការទើបទទួលបានលទ្ធផលល្អប្រសើរ និងណែនាំឱ្យប្រជាពលរដ្ឋ មានការចូលរួមបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ដោយធ្វើការវេចខ្ចប់សំរាម ដាក់ស្បោងប្លាស្ទិកឱ្យបានត្រឹមត្រូវ ដើម្បីឱ្យមានភាពងាយស្រួលដល់ក្រុមហ៊ុនក្នុងការប្រមូលយក និងដើម្បីថែរក្សានូវសោភណ្ឌភាពខណ្ឌផងដែរ។

## ២.២. ការរៀបចំសោភណ្ឌភាពខណ្ឌឫស្សីកែវ

ខណ្ឌឫស្សីកែវ ជាខណ្ឌមួយដែលមានផ្ទៃដី ២៦៥៤,៧ ហិកតា ដែលមានប្រជាពលរដ្ឋរស់នៅ ចំនួន ៣៣,៣៧៤ គ្រួសារ មានប្រជាជនសរុបចំនួន ១៥៣,៥០៧ នាក់ ក្នុងនោះមានស្រីចំនួន ៨១,៦១៤ នាក់ ដែលប្រជាពលរដ្ឋភាគច្រើនប្រកបរបរសេវាកម្ម ដែលមានទីតាំងបិតនៅភាគខាងជើងរាជធានីភ្នំពេញ ងាយស្រួល ក្នុងការវិនិយោគ ផ្នែកសំណង់លំនៅឋាន ឬប្រកបអាជីវកម្មផ្សេងៗ។[66] ចំនួនប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់នេះ គឺជាមូលហេតុចម្បងដែលញ៉ាំងឲ្យមានការរៀបចំនូវសោភណ្ឌភាពទាំងមូល

[66] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៦-២០១៨

របស់ខណ្ឌ ទាំងសោភណ្ឌភាពពេលថ្ងៃ និងសោភណ្ឌភាពពេលយប់។ សោភណ្ឌភាពពេលថ្ងៃមានដូចជា ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ (ការដាំដើមឈើតាមដងផ្លូវ, ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ, ការរៀបចំសំណង់អគារតាមដងផ្លូវ) ការរៀបចំសោភណ្ឌភាពសម្រាប់លំអនៅពេលយប់ (ការបំពាក់ភ្លើងតាមដងផ្លូវនៅពេលយប់, ការបំពាក់ភ្លើងតាមសួនច្បារ, ការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌តាមអគារសាធារណៈ អគារឯកជន និងការកសាងកន្លែងកំសាន្តនាពេលរាត្រី)ជាដើម។ កត្តាទាំងនេះ គឺជាផ្នែកមួយនៃការរៀបចំសោភណ្ឌរបស់ខណ្ឌផងដែរ។

### ២.២.១. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

បើយោងតាមវេបសាយរបស់សាលាក្រុងភ្នំពេញ បានរៀបរាប់បង្ហាញថា ភ្នំពេញស្ថិតនៅក្នុងតំបន់ខាងត្បូង-កណ្ដាលនៃប្រទេសកម្ពុជា នៅចំណុចប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់។ ទន្លេទាំងនេះផ្ដល់នូវប្រព័ន្ធអេកូឡូស៊ីទឹកសាប និងទន្លេប្រកបដោយសក្ដានុពល ជាធនធានដ៏សំខាន់សម្រាប់លក្ខខណ្ឌបរិស្ថានប្រកបដោយចិរភាព សោភណ្ឌភាព ធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុងចម្រើនសម្រាប់ប្រជាជននៅរាជធានីភ្នំពេញតាំងពីអតីតកាលរហូតមកទល់បច្ចុប្បន្ន។ រតនភណ្ឌនៃរាជធានីភ្នំពេញ ដែលត្រូវបានគេហៅថាអគារល្បីៗរួមមានដូចជា៖ ការិយាល័យប្រៃសណីយ៍ គេហដ្ឋានឯកជនមួយចំនួន សណ្ឋាគារឡឺរ៉ូយ៉ាល់ ក្រុមហ៊ុនឯកជនមួយចំនួន ស្ថានីយរាជាស្ម័យាន វត្តភ្នំ ព្រះបរមរាជវាំង សាលារាជធានីភ្នំពេញ មហាវិថីព្រះនរោត្តម រតនាគារជាតិ សារមន្ទីរជាតិ បណ្ណាល័យជាតិ ក្រសួងប្រៃសណីយ៍ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច សួនច្បារវិមានឯករាជ្យ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តុលាការកំពូល វិមានឯករាជ្យ។ ក្រៅពីសំណង់អគារល្បីៗទាំងនេះ យើងសង្កេតឃើញថា រាជធានីភ្នំពេញសព្វថ្ងៃបាន និងកំពុងរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានារួមមាន៖ ផ្លូវ ថ្នល់ សួនច្បារ ការដាក់ភ្លើងលំអ អគារពាណិជ្ជកម្ម អគារការិយាល័យរដ្ឋបាលភ្លើងស្តុប ស្ពានអាកាស សំណង់ផ្ទះប្រណីតនានាពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយសារតែកត្តាទាំងនេះហើយ ទើបរាជធានីភ្នំពេញនាពេលបច្ចុប្បន្នមានសន្ទុះកើនឡើងនៃភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើន ចូលមកទស្សនាភាពស្រស់ស្អាត នៃសោភណ្ឌភាពរបស់រាជធានីភ្នំពេញ។ ក្នុងចំណោមបណ្ដាជនជាតិអាស៊ីទាំងក្នុង និងក្រៅប្រទេសរាជធានីភ្នំពេញ គឺជារាជធានីដែលមានកេរ្តិ៍ឈ្មោះល្បីក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរ ច្រើនជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[67]

តួយ៉ាង បើយើងក្រឡេកមកមើលខណ្ឌឫស្សីកែវ ដែលជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ នៃរាជធានីភ្នំពេញដែលមានការរៀបចំ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌ។ ដើម្បីធ្វើការឆ្លើយតបទៅ

[67] ដកស្រង់ចេញពីសៀវភៅនីតិនគរូបនីយកម្មវិទ្យា របស់លោក សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ផ្នែកទី១ "ការរៀបចំក្រុងប្រទេសកម្ពុជា-ទីក្រុងភ្នំពេញ" ត្រង់ទំព័រទី១៥, ១៦ និង ១៧

នឹងតម្រូវការរបស់រាជធានីភ្នំពេញ ជាពិសេសតម្រូវការរបស់សាលាខណ្ឌផ្ទាល់ ខណ្ឌបានធ្វើការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធនានា ដែលជាការលំអសោភណ្ឌភាពរបស់ខណ្ឌមានដូចជា ការដាំដើមឈើតាមដងផ្លូវ ការបំពាក់ភ្លើងតាមដងផ្លូវ ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ ការរៀបចំសំណង់អគារតាមដងផ្លូវ ការបង្កើតសួនច្បារសាធារណៈតាមដងផ្លូវ។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទាំងនេះ បានប្រែក្លាយមុខមាត់ខណ្ឌឫស្សីកែវទៅជាខណ្ឌ ដែលមានភាពទាក់ទាញភ្ញៀវទេសចរនានាមកកំសាន្ត ដែលធ្វើឲ្យខណ្ឌក្លាយទៅជាខណ្ឌមួយដែលមានភាពស្រស់ស្អាតក្នុងចំណោមខណ្ឌនានានៃរាជធានីភ្នំពេញ។

### ២.២.១.១. ការដាំដើមឈើតាមដងផ្លូវ

សោភណ្ឌភាព សំដៅទៅលើភាពល្អឬហ្មត់ហ្មង ភាពស្រស់ស្អាត។ កាលណាតំបន់មួយមានភាពស្រស់ស្អាតនោះ វានឹងក្លាយទៅជាតំបន់មួយ ដែលពោរពេញទៅដោយភាពល្អប្រសើរនៃបរិស្ថាន ក៏ដូចជាមានធម្មជាតិស្រស់បំព្រងនៅក្នុងតំបន់នោះ។ ជាក់ស្តែងបើយើងងាកមកមើល សោភណ្ឌបរិស្ថានក្នុងខណ្ឌឫស្សីកែវវិញ ក្រៅពីការចាត់វិធានការគ្រប់គ្រងសំរាម សាលាខណ្ឌបានធ្វើការដាំដើមឈើនៅតាមដងផ្លូវដើម្បីធ្វើការកែលម្អនូវសោភណ្ឌភាពបរិស្ថានអោយមានភាពល្អប្រសើរទៀតផង។ ចំពោះការដាំដើមឈើតាមដងផ្លូវនៅក្នុងខណ្ឌរួមមានដើមឈើ តូច ធំ មួយចំនួននៅអមសងខាងតាមដងផ្លូវបានធ្វើឱ្យនៅតាមដងផ្លូវមួយចំនួនក្នុងខណ្ឌឫស្សីកែវមាន សោភណ្ឌភាព និងធ្វើឱ្យអ្នកធ្វើដំណើរទៅមកមានអារម្មណ៍ស្រស់ស្រាយផងដែរ។ ជាក់ស្តែងបើយើងក្រលេកមើលនៅតាមផ្លូវសួនច្បារគីឡូម៉ែតលេខ៦ ឃើញមានការដាំដើមឈើលម្អតាមដងផ្លូវដោយមានការយកចិត្តទុកដាក់កែលម្អ ធ្វើយ៉ាងណាដើម្បីលើកកម្ពស់សោភណ្ឌភាពក្នុងខណ្ឌ។ ម្យ៉ាងទៀត ចំពោះការថែទាំដើមឈើនៅគ្រប់ខណ្ឌទាំងអស់ក្នុងរាជធានីភ្នំពេញសាលាក្រុងភ្នំពេញ បានសហកជាមួយមន្ទីរសាធារណការ និង ដឹកជញ្ជូន រាជធានីភ្នំពេញ និង ក្រុមហ៊ុន អេកូ អ៊ែត&ហ្គ្រីន ខូ អិលធីឌីដើម្បីថែរក្សានូវដើមឈើនៅក្នុងខណ្ឌអោយមានភាពល្អប្រសើរ។ រដ្ឋបាលរាជធានីភ្នំពេញបានធ្វើការជម្រាបមកអភិបាលខណ្ឌ នៃគណៈអភិបាលខណ្ឌទាំង១២ ដែលក្នុងនោះ ខណ្ឌឫស្សីកែវក៏ជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ ដែលរដ្ឋបាលរាជធានីភ្នំពេញបានធ្វើការស្នើឱ្យក្រុមហ៊ុន អេកូ អ៊ែត&ហ្គ្រីន ខូ អិលធីឌី និង មន្ទីរសាធារណការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ យកចិត្តទុកដាក់ និងរៀបចំគម្រោងជួសជុល និងថែទាំដើមឈើឱ្យបានច្បាស់លាស់ ដើម្បីសោភណ្ឌភាពខណ្ឌ និងរាជធានីមានភាពស្រស់ស្អាត។[68]

[68] កំណត់ហេតុស្តីពីការត្រួតពិនិត្យស្ថានភាពសួនច្បារ និងដើមឈើដែលមានសភាពខូចខាតក្នុងរាជធានីភ្នំពេញរបស់រដ្ឋបាលរាជធានីភ្នំពេញ

### ២.២.១.២. ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ

ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ មានសារៈសំខាន់ណាស់សម្រាប់អ្នកដំណើរគ្រប់រូប ដូចជាការបំពាក់កាមេរ៉ាសុវត្ថិភាពជាដើម។ ការបំពាក់កាមេរ៉ាសុវត្ថិភាពបានចាប់ផ្តើមនៅក្នុងរាជធានីភ្នំពេញកាលពីឆ្នាំ២០១៥ រហូតដល់សព្វថ្ងៃ។ កាមេរ៉ាសុវត្ថិភាពមានផលប្រយោជន៍ចាំបាច់ណាស់ក្នុងការចូលរួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់ និងងាយស្រួលទទួលបានព័ត៌មានជាក់ស្តែងពីបទល្មើសផ្សេងៗដែលកើតមានឡើងនៅក្នុងប្រទេស។ តាមរយៈបច្ចេកវិទ្យានេះ នាយកដ្ឋានបំពាក់កាមេរ៉ាសុវត្ថិភាព ក៏មានបំណងសហការជាមួយក្រុមហ៊ុនឯកជននានា ដើម្បីបំពាក់កាមេរ៉ាតាមគេហដ្ឋាន ផ្សារ រមណីយដ្ឋានសាធារណៈ ដែលងាយមានបញ្ហា ហើយនេះជាការចូលរួមចំណែកមួយដែលអាចជួយដោះស្រាយបញ្ហាសង្គម និងដើម្បីផ្តល់សុវត្ថិភាពឲ្យបានល្អប្រសើរដល់ប្រជាជន។

ក្នុងនោះរាជរដ្ឋាភិបាលចង់បង្កើតជា ទីក្រុង «Smart City» ដែលមានបំណងសម្អាតតាមផ្លូវឲ្យមានសោភណ្ឌភាព និងការការពារសន្តិសុខសង្គម ព្រមទាំងបទល្មើសដែលបានកើតមានជាក់ស្តែងជាច្រើនករណីតាមរយៈការភ្ជាប់ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពក្រោមការចូលរួមសហការពីប្រទេសចិន។ សមត្ថភាពនៃការប្រើប្រាស់កាមេរ៉ាសុវត្ថិភាព គឺកាត់បន្ថយការប្រើប្រាស់ធនធានកងកម្លាំងមនុស្សច្រើនតាមទីសាធារណៈក្នុងការការពារសន្តិសុខ នៅក្នុងប្រទេសដែលមន្ត្រីសមត្ថកិច្ចងាយស្រួលទទួលបានបទល្មើសជាក់ស្តែង។

តាមរយៈបច្ចេកវិទ្យាកាមេរ៉ាសុវត្ថិភាព នៅប្រទេសគេបានប្រើប្រាស់កាមេរ៉ាសុវត្ថិភាព ដើម្បីទប់ស្កាត់ និងចាប់បទល្មើសតាមទីសាធារណៈដោយបង្កើតឲ្យភ្ញៀវទេសចរមានទំនុកចិត្ត ដែលជាឧទាហរណ៍មួយល្អសម្រាប់ប្រទេសកម្ពុជាដែរ។ កាមេរ៉ាសុវត្ថិភាពសាធារណៈមានសារៈប្រយោជន៍សម្រាប់ថតយករូបភាពពីទីតាំងតាមគោលដៅជាក់លាក់។ ទីតាំងគោលដៅ និងទិន្នន័យដែលយើងយកបានមកប្រើដូចជាវិស័យសន្តិសុខសុវត្ថិភាព(ចោរប្លន់) ដែលអាចជាតម្រុយបទល្មើស និងវិស័យចរាចរណ៍(គ្រោះថ្នាក់ចរាចរណ៍) ដែលអាចបញ្ជាក់ពីភស្តុតាងជាក់ស្តែង។ នៅពេលដែលកាមេរ៉ាសុវត្ថិភាពត្រូវបានតំឡើងរៀបចំតបណ្តាញទិន្នន័យ គឺត្រូវបានថតទុកទៅតាមបច្ចេកទេសស្តង់ដារ ដើម្បីរក្សាសន្តិសុខដល់ប្រជាពលរដ្ឋ។

កាមេរ៉ាសុវត្ថិភាពសាធារណៈជាង១០០០គ្រឿង មកពីសាលារាជធានីភ្នំពេញ ៦០០កាមេរ៉ា ដែលភ្ជាប់ជាមួយភ្លើងស្តុបថ្មីៗ ដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារ Jica (១០០គ្រឿង) បណ្តាញដែលកំពុងភ្ជាប់ និងកាមេរ៉ាបំពាក់ដោយអគ្គស្នងការនគរបាលជាតិចំនួន៦០០ ដែលបានបំពាក់នៅក្នុងរាជធានីភ្នំពេញតាមទីតាំងសាធារណៈរួចរាល់។ បច្ចុប្បន្ននេះ ក្នុងរាជធានីភ្នំពេញមានបំពាក់កាមេរ៉ាសុវត្ថិភាពចំនួន ២០០ កាមេរ៉ារួចហើយ។ សាលារាជធានីភ្នំពេញ និងបណ្តាខណ្ឌទាំងអស់ក្នុង

រាជធានីភ្នំពេញ បានខិតខំទាំងអស់គ្នាដើម្បី កែប្រែការគ្រប់គ្រងប្រព័ន្ធ ចរាចរណ៍ និងភ្លើងបំភ្លឺក្នុងរាជធានីយើងទៅជាការគ្រប់គ្រងដោយប្រព័ន្ធ IT។

ការបំពាក់កាម៉េរ៉ានេះ នឹងធ្វើឡើងនៅតាមច្រកសំខាន់ៗមួយចំនួន នៅក្នុងខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញ ក្នុងនោះផងដែរ ខណ្ឌឫស្សីកែវដែលជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញ បានធ្វើការបំពាក់កាមេរ៉ាសុវត្ថិភាពចំនួន ៥៣គ្រឿងនៅតាមចំណុចសំខាន់ៗ ជាពិសេសនៅតាមស្តុបនានា ដែលមាននៅក្នុងខណ្ឌផ្ទាល់ ដែលការបំពាក់នូវកាមេរ៉ាសុវត្ថិភាពនេះបានជួយសម្រួលនូវបញ្ហានានាដែលបានកើតឡើងក្នុងខណ្ឌទៅលើវិស័យសន្តិសុខសុវត្ថិភាព (ចោរប្លន់) ដែលអាចជាតម្រុយបទល្មើស និងវិស័យចរាចរណ៍ (គ្រោះថ្នាក់ចរាចរណ៍) ជាការពិតណាស់ប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ពិតជាមានសារៈសំខាន់ណាស់ក្នុងការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋ។[69]

ចំពោះបញ្ហាចិញ្ចើមផ្លូវក្នុងខណ្ឌឫស្សីកែវវិញ សាលាខណ្ឌបានចាត់វិធានការដើម្បីធ្វើការរៀបចំនូវបញ្ហាសណ្តាប់ធ្នាប់ តាមចិញ្ចើមផ្លូវមានដូចខាងក្រោម៖

១. ការិយាល័យអន្តរវិស័យខណ្ឌ ត្រូវសហការជាមួយការិយាល័យ ដនសភ (ការិយាល័យដែនដីនគរូបនីយកម្ម និងសំណង់ និងភូមិបាល) ខណ្ឌ និងសង្កាត់ចុះវាស់វែង និងថ្នាំកំណត់ទំហំផ្លូវ និងចិញ្ចើមផ្លូវត្រង់ចំណុចសួនច្បារផ្លូវភ្លោះ គីឡូម៉ែត្រលេខ៦ដើម្បីឲ្យប្រជាពលរដ្ឋដែលបានសាងសង់សំយ៉ាបរំលោភលើចំណីផ្លូវឲ្យរុះរើចេញវិញ។

២. ត្រូវបន្តចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវជាតិលេខ៥ ជាប្រចាំ និងធ្វើការណែនាំដល់ប្រជាពលរដ្ឋដែលកំពុងធ្វើអាជីវកម្មរំលោភលើចិញ្ចើមផ្លូវត្រូវរំកិល ឬថយចេញពីចិញ្ចើមផ្លូវឲ្យអស់។

៣. ត្រូវចុះណែនាំដល់ប្រជាពលរដ្ឋដែលរស់នៅតាមផ្លូវកប់ស្រូវ ឲ្យរុះរើសំណង់ផ្សេងៗចេញទៅតាមគំនូសថ្នាំដែលការិយាល័យខណ្ឌបានបាញ់រួចក្នុងរង្វង់២៥ម៉ែត្រពីអ័ក្សផ្លូវ។

៤. ត្រូវចេញសេចក្តីជូនដំណឹងឲ្យ ម្ចាស់សំណង់ រោង តូប ដែលបានសាងសង់រំលោភលើចំណីផ្លូវសាធារណៈ រុះរើចេញវិញដោយរក្សាស្ថានភាពដើម ។[70]

ម្យ៉ាងវិញទៀត តាមសេចក្តីណែនាំស្តីពី "**ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ**" បានចេញសេចក្តីណែនាំទៅចំពោះខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញក្នុងការណែនាំដល់ប្រជាពលរដ្ឋក្នុងខណ្ឌរបស់ខ្លួនផ្ទាល់ចំពោះការប្រើប្រាស់ដីចំណីផ្លូវ ក៏ដូចជាចិញ្ចើមផ្លូវដោយស្របតាមការកំណត់របស់សាលារាជធានីភ្នំពេញ ក្នុងគោលដៅ ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ និងលើកកម្ពស់សោភណ្ឌភាពទីក្រុង-ខណ្ឌ និងធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ចិញ្ចើមផ្លូវ ទាំងផ្នែកខាងលើ និងផ្នែកខាងក្រោមដី សម្រាប់បម្រើប្រយោជន៍សាធារណៈស្រប

[69] គេហទំព័រ http://www.freshnewsasia.com ចូលមើលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩

[70] គេហទំព័រ http://www.wgccpn.com ចូលមើលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

តាមលក្ខណៈបច្ចេកទេស។ ក្នុងសេចក្ដីណែនាំនោះដែរ សាលារាជធានីភ្នំពេញបានកំណត់ដោយការប្រើប្រាស់ចិញ្ចើមផ្លូវដូចខាងក្រោម៖

- ចិញ្ចើមផ្លូវទុកបម្រើដល់ការធ្វើចរាចរណ៍ដោយថ្មើរជើង
- បម្រើសកម្មភាព ដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៍ និងពិធីបុណ្យផ្សេងទៀត នៅលើដងផ្លូវ ប៉ុន្តែត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ទៅតាមកម្រិតនៃពិធី និងតាមភាពចាំបាច់
- បម្រើសកម្មភាពដឹកនាំជីកកប់បណ្ដាញក្រោមដី ដូចជា បណ្ដាញទឹកស្អាត ប្រព័ន្ធលូ ខ្សែបញ្ជូនអគ្គិសនី បំពង់ទុយោ ខ្សែកាបអុបទិចគ្រប់ប្រភេទ និងបរិក្ខារក្រោមដី ផ្សេងៗទៀត
- បម្រើសកម្មភាពសាងសង់ ក្នុងគម្រោងចាំបាច់មួយចំនួន ដូចជា បរិក្ខារបម្រើឲ្យវិស័យការពារជាតិសន្តិភាពជាតិ បរិក្ខារបម្រើឲ្យការគ្រប់គ្រង ឬ ការសាងសង់ផ្លូវ និងបរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀត តាមការចាំបាច់។
- សម្រាប់ប្រជាពលរដ្ឋដែលជាម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ គ្រឹះស្ថានអប់រំ-អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវចូលរួមប្រើចិញ្ចើមផ្លូវឲ្យស្របតាមការកំណត់របស់សាលារាជធានីភ្នំពេញ ដោយអាចប្រើប្រាស់ចិញ្ចើមផ្លូវត្រឹម ១/៣(មួយភាគបី) សម្រាប់ការរៀបចំ សម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក ២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើឲ្យការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍។ រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ម៉ូតូ មិនត្រូវឲ្យលើសពី ១/៣ (មួយភាគបី) នៃចិញ្ចើមផ្លូវឡើយ។[71]

ក្នុងនោះផងណា ខណ្ឌឫស្សីកែវជាខណ្ឌមួយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានីភ្នំពេញ ហើយជាខណ្ឌមួយដែលស្ថិតក្នុងចំណោមខណ្ឌទាំង ១២ក្នុងរាជធានីភ្នំពេញ ដែលបានចូលរួមក្នុងការអនុវត្ត នូវសេចក្ដីណែនាំរបស់សាលារាជធានីភ្នំពេញ ដើម្បីធ្វើយ៉ាងណាការពារចិញ្ចើមផ្លូវ ពីការរំលោភបំពានពីសំណាក់ប្រជាពលរដ្ឋក្នុងការទៅប្រើប្រាស់ធ្វើជាផលប្រយោជន៍បុគ្គលព្រមទាំងធ្វើការផាកពិន័យចំពោះបុគ្គល ដែលបានបំពានខ្លឹមសារនៃសេចក្ដីណែនាំនេះ ក្នុងគោលដៅថែរក្សា ការពារនូវសណ្ដាប់ធ្នាប់សោភណ្ឌភាពរបស់ខណ្ឌឲ្យមានលក្ខណៈល្អប្រសើរ។

[71] រដ្ឋបាលរាជធានីភ្នំពេញ លេខ: ០១៣/១៨ សជណ ស្ដីពីសេចក្ដីណែនាំស្ដីពី "ការរៀបចំសណ្ដាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ"

លើសពីនេះទៅទៀត ចំពោះបញ្ហានេះទៀតសោត គណៈអភិបាលខណ្ឌឫស្សីកែវបានធ្វើការណែនាំឱ្យប្រជាពលរដ្ឋ ក៏ដូចជាអាជីវករលក់ដូរទាំងអស់ ដែលបានយកចិញ្ចើមផ្លូវប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មណាមួយ ត្រូវតែអនុវត្តតាមការណែនាំជានិច្ច របស់រដ្ឋបាល សង្កាត់ ខណ្ឌ ក៏ដូចជា រដ្ឋបាលរាជធានីភ្នំពេញ ទៅតាមការបាញ់គំនូសសញ្ញា ចាប់ពីអ័ក្សចិញ្ចើមផ្លូវប្រវែង១ម៉ែត្រកន្លះក្នុងការរក្សាធ្វើយ៉ាងណាកុំឱ្យបាត់បង់សោភណ្ឌភាព និងបញ្ចៀសការកកស្ទះនូវចរាចរណ៍ទៀតផង។[72] លើសពីនេះទៅទៀត ការការពារចិញ្ចើមផ្លូវ គឺមានសារៈសំខាន់ណាស់ ដែលអាចទុកចន្លោះបម្រុងសម្រាប់អ្នកថ្មើរជើង ដែលបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរដែលអាចការពារសុវត្ថិភាពរបស់អ្នកថ្មើរជើងបានមួយភាគធំ។ ការរៀបចំចិញ្ចើមផ្លូវ គឺជាការទុកចន្លោះយ៉ាងតិច ៥ម៉ែត្រ ពីមុខគំនូសឆ្នូតកាត់ទទឹងទ្រូងផ្លូវសម្រាប់អ្នកថ្មើរជើង ឬនៅលើគំនូសនេះ។[73]

ចំពោះការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវត្រូវបានចែងក្នុងជំពូកទី២ មាត្រា៦ នៃច្បាប់ចរាចរណ៍ផ្លូវគោក ដែលសញ្ញាចែងថាៈ ចរាចរណ៍រួមមានផ្លាកសញ្ញាចរាចរនៅតាមផ្លូវភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត ។ ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍ នៅលើផ្លូវត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នា ជាហូរហែរនៅតាមកន្លែងមានសារៈប្រយោជន៍ ដែលធ្វើអោយអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ ។ សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈ មិនអចិន្ត្រៃយ៍ត្រូវដាក់ក្នុងចំងាយ សមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវដែលអាចធ្វើអោយអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន ។[74]

ចំណែកឯក្នុងខណ្ឌឫស្សីកែវវិញ សាលាខណ្ឌបានធ្វើការយកចិត្តទុកទៅលើបញ្ហាចរាចរណ៍នៅក្នុងខណ្ឌ រដ្ឋបាលរាជធានីភ្នំពេញ បានធ្វើការដំឡើងភ្លើងស្តុបថ្មីទី៣ នៅប្រសព្វផ្លូវជាតិលេខ៥ និងផ្លូវសាលាដែកខណ្ឌឫស្សីកែវ បានដាក់ឲ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦។[75] ការរៀបចំភ្លើងស្តុបអាចបញ្ចៀសនូវការកកស្ទះចរាចរណ៍នៅក្នុងខណ្ឌបានមួយចំណែក ដែលធ្វើឲ្យការធ្វើចរាចរណ៍ក្នុងខណ្ឌមានសណ្តាប់ធ្នាប់ ប្រកបដោយសោភណ្ឌភាព។ ចំណែកឯ ការដាក់គំនូសសញ្ញាពិតជាមានសារៈសំខាន់សម្រាប់អ្នកធ្វើដំណើរលើដងផ្លូវ ដែលវាបានបង្កលក្ខណៈងាយស្រួយសម្រាប់អ្នកបើកបរ និងអ្នកថ្មើរជើងដែលបានធ្វើការបែងចែកអាទិភាពនៃការបើកបរលើដងផ្លូវ មានដូចជាគំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ គំនូស

---

[72] គេហទំព័រ apsaracentral.com ចូលមើលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩

[73] ជំពូកទី៣ មាត្រា២៣ គ្រង់ចំណុចទី៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក អនុម័តថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤

[74] ជំពូកទី២ "សញ្ញាចរាចរណ៍" គ្រង់ មាត្រា៥ នៃច្បាប់ចរាចរណ៍ផ្លូវគោក អនុម័តថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤

[75] គេហទំព័រ http://freshnewsasia.com ចូលមើលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

សញ្ញាផ្សេងៗលើទ្រូងផ្លូវ។[76] ចំពោះការដាក់នូវផ្លាកសញ្ញាចរាចរណ៍វិញ សាលារាជធានីភ្នំពេញបានធ្វើការរៀបចំដាក់តាមបណ្ដោយផ្លូវនានានៅក្នុងខណ្ឌទាំង១២ ដើម្បីផ្ដល់ព័ត៌មានសម្រាប់អ្នកបើកបរ ក៏ដូចជាអ្នកថ្មើរជើងឲ្យមានការប្រុងប្រយ័ត្នទុកជាមុន ដែលអាចជួយកាត់បន្ថយ ក៏ដូចជាបញ្ចៀសនូវបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលបានកើតឡើងជាយថាហេតុ។ បើយើងធ្វើការងាកមកមើលខណ្ឌឫស្សីកែវវិញ សាលារាជធានីភ្នំពេញបានធ្វើការបំពាក់នូវផ្លាកសញ្ញាចរាចរណ៍នៅតាមបណ្ដាផ្លូវសំខាន់ៗ ជាពិសេសផ្លូវជាតិលេខ៥ ដែលជាផ្លូវមានការធ្វើចរាចរណ៍យ៉ាងមមាញឹកជារៀងរាល់ថ្ងៃដែលក្នុងនោះប្រភេទនៃផ្លាកសញ្ញចរាចរណ៍មានដូចជា សញ្ញាហាមឃាត់ សញ្ញាបញ្ជា សញ្ញាអាទិភាព សញ្ញាគ្រោះថ្នាក់ សញ្ញាប្រកាសអាសន្ន សញ្ញាបង្ហាញទិសដៅ សញ្ញាបង្ហាញតំបន់ព្រំប្រទល់ និងចាកចេញពីព្រំប្រទល់ទិសដៅ សញ្ញាបង្ហាញព័ត៌មាន សញ្ញាដាក់បន្ថែមពីក្រោម សញ្ញាប្រាប់ដំណឹង សញ្ញាប្រាប់ឈ្មោះតំបន់ និងសញ្ញាប្រាប់ឈ្មោះផ្លូវ។[77]

ដូច្នេះហើយ ដោយសារតែមានការយកចិត្តទុកដាក់រៀបចំនូវ ប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ ក្នុងខណ្ឌឫស្សីកែវ ទើបធ្វើឲ្យខណ្ឌប្រកបដោយសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាព ដល់ប្រជាពលរដ្ឋ ជាពិសេសធ្វើឲ្យសោភណ្ឌភាពរបស់ខណ្ឌកាន់តែមានភាពប្រសើរឡើងជាលំដាប់។[78]

### ២.២.១.៣. ការរៀបចំសំណង់អគារតាមដងផ្លូវ

បើយើងក្រលេកមើលនាពេលបច្ចុប្បន្ននេះ វិស័យឧស្សាហកម្មសំណង់នៅក្នុងប្រទេសកម្ពុជាកំពុងមានការរីកចម្រើនយ៉ាងខ្លាំង។ នេះបើយោងតាមទិន្នន័យក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ វិស័យសំណង់មានការកើនឡើងគួរឱ្យកត់សម្គាល់។ ក្នុងនោះផងដែរចំពោះការរៀបចំសំណង់អគារនៅតាមដងផ្លូវក៏មានសារៈសំខាន់ខ្លាំងណាស់ផងដែរ កាលណារៀបចំអគារតាមដងផ្លូវដែលមានជួរតម្រង់បានត្រឹមត្រូវ នេះក៏អាចបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ដើម្បីសោភណ្ឌភាពនៅក្នុងតំបន់មួយ ឬទីក្រុងមួយ។ ការអភិវឌ្ឍវិស័យសំណង់អគារបច្ចុប្បន្នកំពុងមានសកម្មភាពយ៉ាងខ្លាំងទូទាំងគ្រប់ខណ្ឌនៅក្នុងរាជធានីភ្នំពេញ ដែលបានប្រែក្លាយតំបន់លំនៅឋានទាបៗ ទៅជាអគារខ្ពស់ៗ និងតំបន់ដីទំនេរក្លាយជាបុរីលំនៅឋានដ៏ស្រស់ស្អាត ហើយក្នុងចំណោមខណ្ឌទាំង១២ គឺខណ្ឌឫស្សីកែវ ទទួលបានការវិនិយោគឈានមុខគេលើការសាងសង់លំនៅឋានជាលក្ខណៈបុរី នេះបើយោងតាមរបាយការណ៍ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជាក់ស្ដែង គណៈអភិបាលខណ្ឌឫស្សីកែវ បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការរៀបចំសំណង់អគារនៅតាមដងផ្លូវឱ្យមានរបៀបរៀបរយ ដើម្បីលើកកម្ពស់នូវសោភណ្ឌនៅតាមផ្លូវនៅក្នុងខណ្ឌ។

---

[76] គេហទំព័រ https://www.google.com ចូលមើលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

[77] គេហទំព័រ https://www.google.com ចូលមើលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

[78] គេហទំព័រ http://www.khmerrean.com ចូលមើលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

### ២.២.២. ការរៀបចំសោភណ្ឌភាពសម្រាប់លំអនៅពេលយប់

ជាការពិតណាស់ការរៀបចំនូវសោភណ្ឌភាព មិនមែនសំដៅទៅលើការរៀបចំនូវសោភណ្ឌភាពពេលថ្ងៃតែប៉ុណ្ណោះទេ ថែមទាំងមានការរៀបចំសម្រាប់ពេលរាត្រីទៀតផង។ ការលំអសោភណ្ឌភាពនាពេលរាត្រីមិនត្រឹមតែជាគ្រឿងលំអតែមួយនោះទេ ប៉ុន្តែការរៀបចំនេះ ថែមទាំងធ្វើឲ្យទិដ្ឋភាពក្នុងខណ្ឌទាំងមូលមានសភាពភ្លឺថ្លា ដែលវាបានជួយសម្រួល ក៏ដូចជាជួយបំភ្លឺតាមអ្នកធ្វើដំណើរដែលអាចកាត់បន្ថយគ្រោះថ្នាក់បានមួយកម្រិតផងដែរ។ ចំណុចពិសេសនោះគឺ បង្កើននូវសោភណ្ឌភាពរបស់ខណ្ឌឲ្យមានភាពស្រស់ស្អាត ទាក់ទាញភ្ញៀវទេសចរចូលមកកំសាន្តពេលរាត្រីដែលអាចជួយឆ្កើននូវកម្រិតប្រាក់ចំណូលថែមទៀតផង។ ការរៀបចំសោភណ្ឌភាពសម្រាប់លំអនៅពេលយប់មានដូចខាងក្រោម៖

#### ២.២.២.១. ការបំពាក់ភ្លើងតាមដងផ្លូវនៅពេលយប់

ចំពោះការបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវ ជាកត្តាមួយសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់ សោភណ្ឌភាពទីក្រុង ជាពិសេសនោះការបំភ្លឺផ្លូវក្នុងពេលរាត្រីរបស់អ្នកដែលធ្វើដំណើរតាមដងផ្លូវទៅមក។ តួយ៉ាងចំពោះខណ្ឌឫស្សីកែវ ដែលជាខណ្ឌមួយក្នុងរាជធានីភ្នំពេញ ក្នុងនោះសាលាក្រុងភ្នំពេញក៏បានធ្វើការយកចិត្តទុកដាក់ទៅលើការដាក់ភ្លើងបំភ្លឺជូនដល់ខណ្ឌឫស្សីកែវនៅតាមដងផ្លូវសំខាន់ៗមួយចំនួននៅក្នុងខណ្ឌបន្ថែមទៀត។ ការបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវមិនត្រឹមតែធ្វើឱ្យមាន សោភណ្ឌភាពនៅតាមដងផ្លូវ និងនៅក្នុងខណ្ឌប៉ុណ្ណោះទេ ការបំពាក់ភ្លើងនេះក៏ជាមធ្យោបាយដ៏ល្អមួយក្នុងការថែរក្សា សន្តិសុខ សុវត្ថិភាពដល់ប្រជាពលរដ្ឋដែលបើកបរនៅពេលរាត្រីទៀតផង។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០១៨ ក្រោយពីដាំបង្គោលភ្លើងបំពាក់អំពូល Solar LED ដើម្បីបំភ្លឺនៅតាមផ្លូវសាធារណៈមួយចំនួននៅសង្កាត់គីឡូម៉ែត្រលេខ៦ទៀតផង។ ក្នុងនោះផងដែរ ខណ្ឌក៏បានធ្វើការយកចិត្តទុកដាក់ក្នុងការដាក់បង្គោលភ្លើងសូឡា Solar LED បន្ថែមសម្រាប់បំភ្លឺតាមដងផ្លូវសាធារណៈមួយចំនួនទៅតាមសំណូមពរពីប្រជាពលរដ្ឋរស់នៅតាមខ្នងផ្ទះក្នុងការរក្សាសន្តិសុខ សុវត្ថិភាពផ្សេងៗ ដែលមានទីតាំងស្ថិតក្នុងភូមិទួលសង្កែ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨។ ក្នុងនោះផងដែរគណៈអភិបាលខណ្ឌ គ្រោងនឹងបំពាក់ភ្លើង Solar LED ប្រើពន្លឺថ្ងៃបន្ថែមនៅតាមបណ្តាផ្លូវសាធារណៈមួយចំនួនទៀត ក្នុងពេលឆាប់ៗនេះ ក្នុងចំណោមសង្កាត់ទាំង៧ នៃភូមិសាស្ត្រខណ្ឌឫស្សីកែវ ដែលសរុបតម្លៃជាង ១ម៉ឺនដុល្លារ ដើម្បីបំភ្លឺផ្លូវឡើងវិញក្នុងការរក្សាសន្តិសុខ សុវត្ថិភាពផ្សេងៗ ក្រោយពីទទួលបានសំណូមពរ និងតម្រូវការចាំបាច់ចំពោះមុខពីប្រជាពលរដ្ឋក្នុងមូលដ្ឋានផងដែរ។[79]

#### ២.២.២.២. ការបំពាក់ភ្លើងតាមសួនច្បារ

ចំពោះការបំពាក់ភ្លើងនៅតាមសួនច្បារ យើងសង្កេតឃើញថាខណ្ឌក៏បានយកចិត្តទុកដាក់ផងដែរ ដើម្បីធ្វើយ៉ាងណាលើកកម្ពស់សោភណ្ឌភាពតាមដងទន្លេ អោយកាន់តែមានភាពស្រស់ស្អាតថែមមួយ

[79] គេហទំព័រ http://m.campost.news ចូលមើលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩

កម្រិតទៀត ដោយក្នុងនោះមន្ទីរសាធារណៈការបានសិក្សាជាប្លង់សួនច្បារ នៅតាមច្រាំងទន្លេសាប ចាប់ពីស្ពានជ្រោយចង្វារ ដល់ឃ្លាំងសាំងសូគីម៉ិច ឫស្សីកែវ ក្នុងខណ្ឌ ឫស្សីកែវ ដោយយើងឃើញថា ប្លង់នេះបានចាប់ផ្ដើមលេចចេញជារូបរាងជាបណ្ដើរៗហើយ។

ប្លង់នេះបានសិក្សាចប់រួចហើយ ដោយបានបែងចែកជាតំបន់ៗដូចជា៖ តំបន់កំសាន្តសួនផ្កា, តំបន់កំសាន្តសួនទឹក អាងទឹក, តំបន់ស្ថានីយ៍កាណូតអ្នកដំណើរ, តំបន់កាណូតទេសចរណ៍, តំបន់សំដែងសិល្បៈកំសាន្តទីវាល, តំបន់ពិព័រណ៍ទូក, តំបន់លក់ភេសជ្ជៈ និងហាងទំនិញ វត្ថុអនុស្សាវរីយ៍ តំបន់ចំណតរថយន្ត, តំបន់រោងជ្រកកំដៅថ្ងៃ និងភ្លៀង, តំបន់ហាត់កីឡា និងតំបន់ក្មេងកំសាន្តជាដើម។[80] ម្យ៉ាងវិញទៀត សាលាខណ្ឌបានគ្រោងនឹងដាក់ភ្លើងបំភ្លឺចម្រុះពណ៌នៅតាមសួនច្បារសាធារណៈនានា ក្នុងខណ្ឌដើម្បីបម្រើដល់ការកំសាន្តរបស់ប្រជាពលរដ្ឋនាពេលរាត្រី ដែលបង្កបរិយាកាសស្រស់ស្រាយ អារម្មណ៍ស្រស់ថ្លាដល់ប្រជាជន ជាពិសេសនោះគឺ ដើម្បីបង្កើននូវសោភណ្ឌភាពរបស់ខណ្ឌឲ្យមានភាពទាក់ទាញថែមទៀតផង។

### ២.២.២.៣. ការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌តាមអគារសាធារណៈ អគារឯកជន និងការកសាងកន្លែងកំសាន្តនាពេលរាត្រី

បើយើងក្រលេកទៅមើលវចនានុក្រមខ្មែររបស់ សម្ដេច ព្រះសង្ឃរាជ ជួនណាត ពាក្យថា សោភណ្ឌភាព គឺសំដៅលើភាព ល្អ ឬត់ហ្មង ។ ដូច្នេះយើងអាចនិយាយបានថា ការរៀបចំសោភណ្ឌភាព គឺធ្វើយ៉ាងណាឱ្យមានភាពល្អប្រសើរនៅគ្រប់ទីកន្លែងទាំងអស់ ដូចជា ការរៀបចំឱ្យមានសួនច្បារ សម្រាប់កំសាន្ត ការទុកដាក់សំរាមអោយបានត្រឹមត្រូវ ការដាំដើមឈើតាមផ្លូវជាដើម ជាពិសេសទៅទៀតនោះការយកចិត្តទុកដាក់ទៅលើការលំអនៅតាមអគារ ដូចជា អគារសាធារណៈ អគារឯកជន និងការបង្កើតកន្លែងកំសាន្តនាពេលរាត្រី ពិតមានសារៈសំខាន់ផងដែរសម្រាប់តំបន់ ក្រុង ឬខណ្ឌមួយ។ ជាក់ស្ដែង យើងសង្កេតឃើញថា ខណ្ឌឫស្សីកែវត្រូវបានឲ្យដឹងថាជាខណ្ឌមួយ ដែលពោរពេញទៅដោយសំណង់អគារលក្ខណៈបែបបុរី ផ្ទះល្វែង ដោយមានការលំអភ្លើងនៅពេលយប់ធ្វើឱ្យរំលេចឡើងនូវភ្លើងចម្រុះពណ៌នាពេលរាត្រី ដែលធ្វើឱ្យសំណង់អគារទាំងនោះមានភាពស្រស់ស្អាតមួយកម្រិតទៀតនៅពេលយប់។ ម្យ៉ាងទៀតការបំពាក់ភ្លើងចម្រុះពណ៌នេះមិនត្រឹមតែធ្វើការយកចិត្តទុកដាក់បំពាក់ទៅលើអគារឯកជនប៉ុណ្ណោះទេ សូម្បីតែអគារសាធារណៈ(អគាររដ្ឋបាល) ក៏មានបំពាក់ផងដែរ ក្នុងគោលបំណងលើកកម្ពស់សោភណ្ឌភាពខណ្ឌ។ ក្នុងនោះផងដែរ ការបំពាក់ភ្លើងនៅតាមអគារ យើងសង្កេតឃើញថាមានភាពកាន់តែពិសេសទៅទៀតនោះ គឺនៅថ្ងៃបុណ្យជាតិផ្សេងៗ ដើម្បីធ្វើយ៉ាងណាទាក់ទាញនូវសាធារណៈជនឱ្យមានចំណាប់អារម្មណ៍ទៅលើសោភណ្ឌភាពរបស់ខណ្ឌទៀតផង។

[80] គេហទំព័រ https://urbanvoicecambodia.net ចូលមើលនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩

ក្រៅពីមានការបំពាក់ភ្លើងបំភ្លឺនាពេលយប់នៅតាមអគារសាធារណៈ និងឯកជនរួចមក យើងសង្កេតឃើញថា ខណ្ឌឫស្សីកែវបានធ្វើការរៀបចំបង្កើតកន្លែងកំសាន្តនាពេលរាត្រី ដែលការបង្កើតនេះបានធ្វើឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នេះទាំងមូល មានពេលវេលាគ្រប់គ្រាន់ដើម្បីមកកំសាន្តលំហែកាយ រំសាយអារម្មណ៍ជាមួយនឹងក្រុមគ្រួសារ ក៏ដូចជាមិត្តភក្តិនាពេលសម្រាកពីការងារ។ ចំពោះការបង្កើតកន្លែងកំសាន្តនេះផងដែរ មិនត្រឹមតែធ្វើឱ្យខណ្ឌមានសោភណ្ឌភាពល្អប៉ុណ្ណោះទេ ក៏ប៉ុន្តែ ថែមទាំងបង្កើននូវភាពទាក់ទាញសម្រាប់ខណ្ឌ ដែលអាចទាក់ទាញមនុស្សម្នាទាំងឡាយឲ្យមកចូលរួមលេងកំសាន្ត ដែលទាំងនេះ គឺជាកត្តាមួយក្នុងការបង្កើននូវចំណូលជូនប្រជាពលរដ្ឋក្នុងខណ្ឌ ក៏ដូចជាបង្កើននូវចំណូលសេដ្ឋកិច្ចជាតិបានទៀតផង។

## ២.៣. ការរៀបចំបរិស្ថានក្នុងខណ្ឌឫស្សីកែវ

បរិស្ថាន គឺផ្នែកមួយនៃសោភណ្ឌភាព។ កាលណាតំបន់មួយមានបរិស្ថានស្រស់ស្អាត នោះតំបន់នោះក៏មានសោភណ្ឌភាពល្អផងដែរ។ យ៉ាងណាមិញ បើយើងធ្វើការក្រឡេកមើលទៅបណ្តាខណ្ឌនានានៅក្នុងរាជធានីភ្នំពេញ មានការយកចិត្តទុកដាក់ជាខ្លាំងទៅលើបញ្ហាបរិស្ថាននៅក្នុងខណ្ឌនោះផ្ទាល់។ ជាក់ស្តែង ខណ្ឌឫស្សីកែវ ជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំងអស់ក្នុងរាជធានីភ្នំពេញដែលបានធ្វើការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាន ជាពិសេសទៅលើផលប៉ះពាល់ដែលបណ្តាលមកពីបរិស្ថានមិនស្អាត គ្មានអនាម័យ ដែលជាហេតុនាំឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពរបស់ប្រជាពលរដ្ឋទាំងមូលក្នុងខណ្ឌ ដោយសារតែមានមេរោគ ក៏ដូចជាបញ្ហាក្លិនមិនល្អដែលធ្វើឲ្យប៉ះពាល់ដល់ផ្លូវដង្ហើមរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងមូលដ្ឋាននៃតំបន់កខ្វក់ដោយសារកាកសំណល់ទាំងនោះ។ ដោយតែហេតុផលទាំងនេះ ទើបសាលាខណ្ឌឫស្សីកែវបានធ្វើការយ៉ាងយកចិត្តទុកដាក់បំផុតទៅលើបញ្ហាបរិស្ថានក្នុងខណ្ឌ ដើម្បីធ្វើយ៉ាងណាកែប្រែ ថែរក្សានិង ការពារនូវភាពស្រស់បំព្រង ភាពបៃតងនៃបរិស្ថាន ជាពិសេសនោះដើម្បីបង្កើននូវសោភណ្ឌភាពរបស់ខណ្ឌឲ្យមានភាពល្អប្រសើរ។

### ២.៣.១. ការរៀបចំកាកសំណល់ក្នុងខណ្ឌ

សំរាម គឺជាបញ្ហាចោទមួយ ដែលប៉ះពាល់ដល់សោភណ្ឌភាពក្នុងតំបន់មួយយ៉ាងខ្លាំង។ តួយ៉ាងដោយខ្លាចប៉ះពាល់ទៅដល់សុខភាពប្រជាពលរដ្ឋ និងដើម្បីលើកកម្ពស់បញ្ហាបរិស្ថានឲ្យកាន់តែប្រសើរឡើងនោះ អភិបាលនៃគណៈអភិបាលខណ្ឌឫស្សីកែវបានជម្រុញបន្ថែមឲ្យក្រុមហ៊ុន **ស៊ិន ទ្រី** ដែលជាផ្នែកមួយដ៏សំខាន់ ធ្វើយ៉ាងណាពន្លឿន ក្នុងការប្រមូលកាកសំណល់សំរាមផ្សេងៗឲ្យអស់ នៅក្នុងភូមិសាស្ត្រខណ្ឌឫស្សីកែវ ក្នុងការជួយសម្អាតបរិស្ថានល្អបរិសុទ្ធជុំវិញការរស់នៅរបស់ប្រជាពលរដ្ឋ ហើយក៏ដើម្បីលើកកម្ពស់ សោភណ្ឌភាពរាជធានីភ្នំពេញផងដែរ។

ការជម្រុញឲ្យក្រុមហ៊ុន **ស៊ិន ទ្រី** ជួយពន្លឿនការប្រមូលកាកសំណល់សំរាមនេះដែរ ត្រូវបានអភិបាលនៃគណៈអភិបាលខណ្ឌត្រូវបានដឹកនាំក្រុមការងារ ដោយបានធ្វើការសហការជាមួយក្រុមហ៊ុន

**ស៊ិន ទ្រី** ដើម្បីចុះទៅទៅរៀបចំសណ្ដាប់ធ្នាប់ ក៏ដូចជាធ្វើការបោសសម្អាតលើសួនច្បារ និងតាមបណ្ដោយផ្លូវសាធារណៈ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៧ នៅតាមបណ្ដោយផ្លូវជាតិលេខ៥ ស្ថិតក្នុងក្រុម៦ ភូមិ២ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ។[81] ដូច្នេះ ការរៀបចំកាកសំណល់ក្នុងខណ្ឌមានដូចខាងក្រោមៈ

### ២.៣.១.១. ការរៀបចំកន្លែងទុកដាក់កាកសំណល់ក្នុងខណ្ឌ

សំរាម គឺជាកត្តាមួយដែលបង្កឲ្យមានជម្ងឺ ឈឺ ថ្កាត់ ដែលប៉ះពាល់ដល់សុខភាពមនុស្ស។ ការរៀបចំកន្លែងទុកដាក់កាកសំណល់ គឺជាចំណុចមួយដ៏សំខាន់ ដែលខណ្ឌបាននឹងកំពុងធ្វើការយកចិត្តទុកដាក់រៀបចំនូវកន្លែងកាកសំណល់ឲ្យមានរបៀបរៀបរយ ចៀសវាងការទុកដាក់កាកសំណល់ពាសវាលពាសកាល ដែលបង្កឲ្យមានភាពរប៉ាត់រប៉ាយនៅក្នុងខណ្ឌ។ បើយោងទៅតាមអនុក្រឹត្យស្ដីពី "ការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន" មាត្រា៣៦ បានចែងថា រដ្ឋបាលរាជធានីក្រុង ស្រុក ត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឲ្យស្របតាមទីតាំង ស្ថានភាព ភូមិសាស្ត្រជាក់ស្ដែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែង សម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹង ទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹង ទីប្រជុំជន ត្រូវស្នើសុំការពិនិត្យសម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការ ការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។[82] ជាក់ស្ដែង បើយើងធ្វើការសង្កេតទៅលើខណ្ឌឫស្សីកែវទាំងមូលមិនទាន់បានធ្វើការរៀបចំទុកដាក់រៀបចំនូវទីលានដាក់កាកសំណល់នៅក្នុងខណ្ឌឱ្យបានល្អប្រសើរនៅឡើយ ដោយនៅមានការខ្វះខាតទីតាំងសម្រាប់ទុកដាក់សំរាម ក៏ប៉ុន្តែខណ្ឌបាននឹងកំពុងរៀបចំ ក៏ដូចជាបានកំណត់ទីតាំងសមស្របមួយចំនួនសម្រាប់ទុកដាក់សំរាមតាមដងផ្លូវ ដើម្បីធ្វើយ៉ាងណាជួយកែលម្អនូវ សោភណ្ឌភាពក្នុងខណ្ឌឱ្យមានភាពល្អប្រសើរឡើងជាងមុន។ ម្យ៉ាងទៀតចំពោះការរៀបចំទីកន្លែងទុកដាក់សំរាមក្នុងខណ្ឌគឺ ក្នុងគោលបំណងជួយសម្រួលដល់បងប្អូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងខណ្ឌឱ្យមានភាពងាយស្រួលក្នុងការទុកដាក់សំរាមឱ្យបានល្អជាងមុន ដើម្បីកុំឱ្យមានការទុកដាក់ពាសពេញផ្លូវ ដែលជាមូលហេតុអាចបណ្ដាលឱ្យធុំក្លិនមិនល្អជះឥទ្ធិពល បង្កផលប៉ះពាល់ដល់សុខភាព ប្រជាពលរដ្ឋ និងបាត់ទាំងសោភណ្ឌភាពផងដែរ។

---

[81] គេហទំព័រ http://freshnewsasia.com ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩

[82] អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្ដីពី "ការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន" ជំពូកទី៦ មាត្រា៣៦

### ២.៣.១.២. ការរៀបចំកាកសំណល់តាមទីសាធារណៈ និងឯកជន

ជាក់ស្តែង នៅតាមដងផ្លូវតូច-ធំជាច្រើន ក្នុងភូមិសាស្ត្រខណ្ឌឬស្សីកែវ ពេញមួយថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩នេះ កម្លាំងសណ្តាប់ធ្នាប់ខណ្ឌ សហការជាមួយភ្នាក់ងារឃ្លាំមើលសំរាមតាមសង្កាត់ និងភ្នាក់ងារប្រមូលសំរាម របស់ក្រុមហ៊ុន **ស៊ិន ទ្រី** បាននាំគ្នាធ្វើអនាម័យ ដើម្បីប្រមូលរាល់កាកសំណល់សំរាមនានា ក្នុងការរក្សាបរិស្ថានឲ្យបានល្អ ក្រៅពីការចូលរួមចំណែកយ៉ាងសកម្ម ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ឲ្យមានរបៀបរៀបរយ ទាំងធ្វើចរាចរណ៍សម្រួលតាមដងផ្លូវ និងជួសជុលលាងសម្អាតផ្លូវ ជូនប្រជាពលរដ្ឋរស់នៅធ្វើដំណើរ ដោយសុវត្ថិភាព ផ្លូវតូច-ធំជាច្រើន ក្នុងភូមិសាស្ត្រខណ្ឌឬស្សីកែវ ដែលមានកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ សហការជាមួយភ្នាក់ងារឃ្លាំមើលសំរាមតាមសង្កាត់ និងភ្នាក់ងារប្រមូលសំរាម របស់ក្រុមហ៊ុន **ស៊ិន ទ្រី** បាននាំគ្នាធ្វើអនាម័យ ដើម្បីប្រមូលរាល់កាកសំណល់សំរាមនានា ក្នុងការរក្សាបរិស្ថានឲ្យបានល្អ ក្រៅពីការចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ឲ្យមានរបៀបរៀបរយ ទាំងធ្វើចរាចរសម្រួលតាមដងផ្លូវ និងជួសជុលលាងសម្អាតផ្លូវ ជូនប្រជាពលរដ្ឋរស់នៅធ្វើដំណើរដោយសុវត្ថិភាព។

### ២.៣.២. ការវេចខ្ចប់កាកសំណល់

ជាការពិតណាស់ សំរាមគឺជាប្រភពដ៏សំខាន់ក្នុងការបំផ្លាញភាពស្រស់ស្អាត ភាពស្រស់បំព្រង។ កាលណាតំបន់មួយមានការទុកដាក់សំរាមផ្តេសផ្តាស មិនមានការវេចខ្ចប់ត្រឹមត្រូវ នោះសំរាមវានឹងបង្កលក្ខណៈអនាធិបតេយ្យ ហើយតំបន់នោះវានឹងក្លាយទៅជាតំបន់ដែលមានក្លិនមិនល្អ បំផ្លាញខ្យល់អាកាសបរិសុទ្ធ ខ្យល់ដង្ហើមរបស់មនុស្សដែលរស់នៅតំបន់នោះ ជាពិសេសគឺវាបានបំផ្លាញដល់សណ្តាប់ធ្នាប់ សោភណ្ឌភាពរបស់តំបន់នោះទៀតផង។

យ៉ាងណាមិញ បើយើងងាកមកមើលទិដ្ឋភាពនៃការគ្រប់គ្រងសំរាមក្នុងខណ្ឌឬស្សីកែវវិញ អភិបាល នៃគណៈអភិបាលខណ្ឌ បានខិតខំប្រឹងប្រែងបើកយុទ្ធនាការក្នុងការអប់រំប្រជាពលរដ្ឋក្នុងមូលដ្ឋានផ្ទាល់ឲ្យបានយល់ដឹងច្បាស់ពីផលប៉ះពាល់ ដែលបណ្តាលមកពីការទុកដាក់សំរាមមិនបានត្រឹមត្រូវតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងបានចុះបង្រៀនប្រជាពលរដ្ឋពីរបៀបនៃការវេចខ្ចប់ និងញែកកាកសំណល់ទៅតាមប្រភេទនៃកាកសំណល់ដែលក្នុងនោះផងដែរ។ ក្នុងនោះសាលាខណ្ឌឬស្សីកែវបានធ្វើការអនុវត្តតាមការណែនាំរបស់រដ្ឋបាលរាជធានី។ តាមអនុក្រឹត្យស្តីពី "ការគ្រប់គ្រងសំរាមសំណល់រឹង ទីប្រជុំជន" មាត្រា១៩ វាក្យខណ្ឌទី១ បានចែងថា រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃប្រជុំជននីមួយៗ និងត្រូវធានាឲ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រងគ្រងសំរាម

សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភណ្ឌភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន។[83] ដើម្បីឲ្យសោភណ្ឌភាពក្នុងខណ្ឌឫស្សីកែវមានអនាម័យ និងមានភាពស្រស់ស្អាត សាលាខណ្ឌបានផ្តោតសំខាន់ទៅលើចំណុចដូចខាងក្រោម៖

### ២.៣.២.១. ការញែក ភាគសំណល់រឹង និងរាវ

ការញែកសំរាមទៅតាមប្រភេទនីមួយៗរបស់វា គឺជាវិធីសាស្ត្រដ៏ល្អក្នុងការចូលរួមចំណែកការពារបរិស្ថាន។ ក្នុងនោះផងដែរ សំណល់មានពីរប្រភេទគឺ សំណល់រឹង និងសំណល់រាវ។

សំណាង់រឹង សំដៅលើសំរាម ឯសំណល់រាវ សំដៅលើលូ(ទឹកកខ្វក់)។ ដើម្បីឲ្យទីក្រុងស្អាត យើងត្រូវធ្វើនូវវិធានការបើជាចាំបាច់ គឺការវេចខ្ចប់សំរាមបានត្រឹមត្រូវ ការប្រមូលសំរាមបានត្រឹមត្រូវ និងការកែច្នៃសំរាមបានត្រឹមត្រូវ។[84]

- ចំពោះការវេចខ្ចប់៖ ការវេចខ្ចប់ គឺមានពីរប្រភេទគឺ ប្រភេទសំណល់ចេញពីផ្ទះបាយត្រូវប្រើប្រាស់ថង់ពណ៌ខ្មៅ និងប្រភេទសំណល់ស្ងួត ត្រូវប្រើប្រាស់ថង់ពណ៌ស។ ការញែកសំរាមជាពីរប្រភេទបែបនេះ វាបង្កលក្ខណៈងាយស្រួលដល់ការប្រមូល និងធ្វើឲ្យសំរាមមិនមានភាពរប៉ាត់រប៉ាយ។
- ចំពោះការប្រមូល៖ ការប្រមូលនេះដែរ សាលាខណ្ឌបានសហការជាមួយក្រុមហ៊ុន **ស៊ិន ទ្រី** ក្នុងការប្រើប្រាស់កម្មករ និងរថយន្តធំៗដើម្បីប្រមូលសំរាមទាំងនោះឲ្យបានស្អាត។ ចំពោះការប្រមូលសំរាមនៅតាមផ្លូវធំៗក្នុងខណ្ឌ មានដូចជា ផ្លូវជាតិលេខ៥ ផ្លូវ៧០ ផ្លូវ៥៩៨ ការប្រមូលសំរាមគឺ ក្រុមហ៊ុនធ្វើការប្រមូលជារៀងរាល់ថ្ងៃ។ ចំណែកឯការប្រមូលសំរាមនៅគ្រប់ផ្សារទាំងអស់នៅក្នុងខណ្ឌក្រុមហ៊ុនក៏បានធ្វើការប្រមូលជារៀងរាល់ថ្ងៃដូចគ្នា ដោយឡែក ចំពោះការប្រមូលសំរាមនៅតាមភូមិ ក្រុមហ៊ុនបានធ្វើការប្រមូលរៀងរាល់ ២ថ្ងៃ ទៅ៣ថ្ងៃម្តង។
- ចំពោះការកែច្នៃ៖ សំណល់ផ្ទះបាយ គេអាចកែច្នៃធ្វើជាជី សំណល់រឹងយកទៅផលិតប្រើប្រាស់ឡើងវិញ និងសំណល់កែច្នៃមិនបាន គឺដុតចោល។

### ២.៣.២.២. ការសំអាត ការទុកដាក់ និងការបញ្ចេញសំរាម

ដើម្បីឲ្យខណ្ឌមានសោភណ្ឌភាពល្អ សាលាខណ្ឌបានរៀបចំ ការសំអាត ការទុកដាក់ និងការបញ្ចេញសំរាមឲ្យបានត្រឹមត្រូវ។ តាមអនុក្រឹត្យស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន" មាត្រា ១៧ បានចែងថា "ម្ចាស់សំរាម សំណល់រឹងទីប្រជុំជន ត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

[83] អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" ជំពូកទី៣ មាត្រា១៩

[84] សៀវភៅ នីតិនិតរូបនីយកម្ម របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ២៦៥

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការត្រួតពិនិត្យឲ្យបានម៉ឺងម៉ាត់លើការអនុវត្ត ការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹង ទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈ រង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់"។[85]

ជាក់ស្តែង នៅក្នុងខណ្ឌឫស្សីកែវទាំងមូលបានកំណត់ការទុកដាក់សំរាមទៅតាមកន្លែងដែលបានកំណត់ ព្រមទាំងបានកំណត់ពេលម៉ោងក្នុងការបញ្ចេញសំរាមដោយធ្វើការកំណត់ចាប់ពីម៉ោង ៦ល្ងាច រហូតដល់ ម៉ោង ៨យប់។ បន្ទាប់ពីមានការប្រមូលនូវកាកសំណល់សំរាមរួចរាល់ ប្រជាពលរដ្ឋ ជាពិសេសម្ចាស់លំនៅឋានបានចូលរួមក្នុងការលាងសំអាតកាកសំណល់ដែលនៅសេសសល់ ដើម្បីកាត់បន្ថយនូវក្លិនមិនល្អចេញ ដើម្បីធ្វើឲ្យខណ្ឌមានខ្យល់អាកាសស្រស់ថ្លា និងចូលរួម ថែរក្សា ការពារសោភណ្ឌរបស់ខណ្ឌផងដែរ។

### ២.៣.៣. ការចាត់វិធានការ ចំពោះការមិនគោរពច្បាប់បរិស្ថាន

ទោះបីជាសាលាខណ្ឌ បានដាក់ចេញនូវច្បាប់នានាដែលពាក់ព័ន្ធទៅនឹងការថែរក្សា និងការពារបរិស្ថានក៏ដោយ ប៉ុន្តែការអនុវត្តនៅមិនទាន់មានប្រសិទ្ធភាពទាំងស្រុងនៅឡើយ ដោយសារតែប្រជាពលរដ្ឋមួយចំនួននៅតែមិនចូលរួមសហការជាមួយសាលាខណ្ឌ ដែលបុគ្គលខ្លះមិនទាន់បានយល់ច្បាស់ពីការការផ្សព្វផ្សាយច្បាប់ ហើយក៏មានបុគ្គលខ្លះបានបំពាននូវច្បាប់ទាំងនោះដោយចេតនា។ ដូច្នេះហើយ ដើម្បីឲ្យការពារនូវសណ្តាប់ធ្នាប់ និងសោភណ្ឌភាពរបស់ខណ្ឌ សាលាខណ្ឌបានចាត់វិធានការ ចំពោះការមិនគោរពច្បាប់បរិស្ថាន មានដូចជា ការចុះណែនាំដល់មូលដ្ឋាន និងធ្វើការផាកពិន័យចំពោះបុគ្គលដែលបំពានច្បាប់បរិស្ថាន។

#### ២.៣.៣.១. ការចុះណែនាំពីបញ្ហាកាកសំណល់

ដោយយល់ឃើញពីភាពជាក់ស្តែងទៅលើបញ្ហាសំរាម អភិបាល នៃគណៈអភិបាលខណ្ឌឫស្សីកែវទាំងអស់ ក្នុងពេលយកសំរាមទៅបោះចោល នៅតាមដងផ្លូវទីសាធារណៈ មានដូចជាៈ បានធ្វើការលើកឡើងដើម្បីជំរុញបញ្ហាកាកសំណល់សំរាម គឺចាំបាច់ណាស់ត្រូវធ្វើការណែនាំប្រជាពលរដ្ឋ

- ជម្រុញឲ្យប្រជាពលរដ្ឋមានការញែក វេចខ្ចប់ទៅតាមប្រភេទនៃកាកសំណល់ឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់
- ជម្រុញឲ្យប្រជាពលរដ្ឋមានការទុកដាក់សំរាមឲ្យបានត្រឹមត្រូវតាមកន្លែងកំណត់
- អប់រំប្រជាពលរដ្ឋឲ្យបញ្ចេញកាកសំណល់ទៅតាមពេលម៉ោងដែលបានកំណត់
- អប់រំប្រជាពលរដ្ឋកុំឲ្យចោលសំរាមផ្តេសផ្តាសតាមទីសាធារណៈ។[86]

---

[85] អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" ជំពូកទី៣ មាត្រា១៧

[86] គេហទំព័រ Freshnewsasia.com ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩

### ២.៣.៣.២. ការផាកពិន័យ

ចំពោះបុគ្គលណាដែលមិនបានគោរពតាមការណែនាំរបស់សាលាខណ្ឌ សាលាខណ្ឌបានធ្វើការចាត់វិធានការសម្រាប់អ្នកចាក់សំរាមចោលគ្មានប្រក្រតី នៅតាមផ្លូវសាធារណៈដូចជា ការចាក់សំរាមចោលចូលទៅលើលូ និងចាក់សំរាមចោលនៅលើផ្លូវសាធារណៈ ត្រូវអនុវត្តផាកពិន័យទៅតាមច្បាប់អន្តរក្រសួងដែរបានចែងរួចហើយ ដែលកំណត់ឱ្យមានការផាកពិន័យជាប្រាក់ចាប់ពី ១ (មួយ) ម៉ឺនរៀល ទៅ ២០ (ម្ភៃ) ម៉ឺនរៀល និងប្ដឹងដល់តុលាការ ចំពោះជនណាដែលចោលសំរាមមិនបានត្រឹមត្រូវ។ យោងតាមអនុក្រឹត្យស្ដីពី "ការគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជន" មាត្រា៣៩បានចែងថា "ការមិនអនុវត្តតាមកំណត់ របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជន ដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដូចមានចែងក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោមៈ

- ចំនួន ១០,០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០,០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០,០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។[87]

ចំពោះបុគ្គលដែលបញ្ចេញសំរាមខុសពេលម៉ោងអនុញ្ញាតិត្រូវទទួលការផាកពិន័យដូចខាងតទៅៈ

តាមអនុក្រឹត្យស្ដីពី "ការគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជន" មាត្រា៤០ បានចែងថា "បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈខុសពេលម៉ោងអនុញ្ញាតិឲ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោមៈ

- ចំនួន ២០,០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០,០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០,០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។
- ក្នុងករណីមិនរាងចាលត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។[88]

---

[87] អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្ដីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" ជំពូកទី៧ មាត្រា៣៩

[88] អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្ដីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" ជំពូកទី៧ មាត្រា៤០

វិធានការផាកពិន័យ ពុំសូវទទួលបានលទ្ធផលល្អប្រសើរឡើយ សំខាន់ផ្តើមចេញពីការផ្សព្វផ្សាយ អប់រំ ឲ្យប្រជាពលរដ្ឋចូលរួមសហការ ទើបទទួលបានលទ្ធផលល្អប្រសើរ ក្នុងការចូលរួមថែរក្សា ការពារបរិស្ថានក្នុងចលនា ប្រឡងប្រណាំងទីក្រុងស្អាត សេវាកម្មល្អ អនាម័យល្អ ខ្យល់អាកាសបរិសុទ្ធ និង គោលដៅសំខាន់ គឺដើម្បីធ្វើឲ្យខណ្ឌទាំងមូលមានសណ្តាប់ធ្នាប់ និងសោភណ្ឌភាពល្អប្រសើរ។

### ២.៣.៤. ការរៀបចំប្រព័ន្ធលូទឹកស្អុយក្នុងខណ្ឌ

ខណ្ឌឫស្សីកែវ គឺជាខណ្ឌមួយនៅស្ថិតនៅក្នុងតំបន់ទីក្រុងរណបនៃរាជធានីភ្នំពេញ ដែលតំបន់នេះស្ថិតនៅទិសខាងជើងនៃរាជធានីភ្នំពេញ ដែលជាតំបន់សម្រាប់ធ្វើកសិកម្ម ដូចជាផលិត ត្រី សាច់ សម្រាប់ផ្គត់ផ្គង់ក្នុងរាជធានីភ្នំពេញ។[89] ដោយសារតែកត្តានេះហើយ ប្រជាជនដែលរស់នៅក្នុងខណ្ឌឫស្សីកែវភាគច្រើនបានប្រកបរបរ នេសាទ ត្រី លក់សាច់ ព្រមទាំងលក់បន្លែជាច្រើននៅលើទីផ្សារនាំចេញទៅកាន់ទីក្រុងភ្នំពេញ ជាពិសេស គឺការធ្វើអាជីវកម្មនៅក្នុងទីផ្សារនៅក្នុងខណ្ឌរបស់ខ្លួនផ្ទាល់ មានដូចជា ផ្សារច្រាំងចំរេះទី២ ផ្សារព្រែកព្នៅ ផ្សារគីឡូម៉ែត្រលេខ៦ និងផ្សារទួលសង្កែ។ ទីផ្សារកាន់តែច្រើន អាជីវករលក់ដូរ ត្រី សាច់ បន្លែ ក៏កាន់តែកើនឡើង ដែលសន្ទុះនៃកំណើននេះបានធ្វើឲ្យបញ្ហាការទុកដាក់កាកសំណល់មិនបានត្រឹមត្រូវ ដោយអាជីវករខ្លះបានចោលកាកសំណល់ផ្សេងៗដែលសេសសល់ពីការលក់ដូរ ដោយធ្វើការបោះចោលតាមប្រព័ន្ធលូបង្ហូរទឹកក្នុងខណ្ឌ ដែលបង្កឲ្យមានការកកស្ទះការហូរទឹកក្នុងបំពង់លូ ដែលធ្វើឲ្យមានការហូរច្រាលចេញមកខាងក្រៅបង្កើតបានជាភក់ជ្រាំ និងមានក្លិនមិនល្អដែលបង្កមកពីសំរាម ត្រី សាច់ បន្លែរលួយ ដែលសាយភាយពាសពេញខណ្ឌ ដែលធ្វើឲ្យបាត់បង់នូវខ្យល់អាកាសបរិសុទ្ធ និងសោភណ្ឌខណ្ឌ។ ដោយមើលឃើញពីបញ្ហាទាំងនេះ សាលាខណ្ឌបានធ្វើការរៀបចំប្រព័ន្ធបង្ហូរទឹកស្អុយ និងចាត់វិធានការធ្វើការចម្រោះទឹកមុននឹងបញ្ចេញទៅតាមប្រព័ន្ធបង្ហូរទឹកក្នុងខណ្ឌ។

#### ២.៣.៤.១. ការរៀបចំប្រព័ន្ធបង្ហូរទឹកស្អុយ

ជាទូទៅ កាលណាតំបន់មួយពោរពេញទៅដោយមនុស្សរស់នៅច្រើន តែងតែមានតម្រូវការសម្រាប់ការរស់នៅ មានដូចជា សុវត្ថិភាពរូបកាយ និងសុវត្ថិភាពចំណីអាហារ។ តម្រូវការដ៏ច្រើនបានជម្រុញឲ្យមានការផលិតច្រើន ហើយការប្រើប្រាស់ក៏កាន់តែច្រើនផងដែរ។ ក៏ប៉ុន្តែ កត្តាទាំងនេះវាបានធ្វើឲ្យតំបន់មួយចំនួនបានជួបនូវគុណវិបត្តិជាច្រើនក្នុងការគ្រប់គ្រងប្រជាជន ជាពិសេសគឺផ្នែកបរិស្ថាន។ ជាក់ស្តែង ខណ្ឌឫស្សីកែវ គឺជាខណ្ឌមួយដែលមានប្រជាជនរស់នៅច្រើនកកកុញ ដែលមានការកើនឡើងផ្នែកសេដ្ឋកិច្ច និងផ្នែកអាជីវកម្ម។ បញ្ហាបរិស្ថានក្នុងខណ្ឌឫស្សីកែវ បានបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងសម្រាប់រដ្ឋបាលខណ្ឌ ព្រោះដោយសារតែប្រជាជនមួយចំនួនដែលជាម្ចាស់អាជីវកម្ម ព្រមទាំងអាជីវករក៏ដូចជាប្រជាពលរដ្ឋមួយចំនួនធំមិនបានយល់ដឹងពីការទុកដាក់សម្រាមឲ្យបានត្រឹមត្រូវ។

កំណើនសំរាមពីមួយថ្ងៃទៅមួយថ្ងៃ នៅតាមមាត់លូ ឬក៏ក្នុងប្រព័ន្ធដែលបង្កឲ្យមានការកកស្ទះ លិច លង់

[89] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រ ២៦៣

តំបន់ផ្ទះប្រជាពលរដ្ឋដែលរស់នៅជិតតំបន់ប្រព័ន្ធលូទឹកស្អុយ។ អភិបាល នៃគណៈអភិបាលខណ្ឌបានយល់ឃើញថា បញ្ហាកកស្ទះប្រព័ន្ធលូបង្ហូរទឹកក្នុងខណ្ឌ គឺផ្តើមចេញពីកាកសំណល់សំរាមដែលនៅក្នុងប្រព័ន្ធលូ ដែលធ្វើឲ្យទឹកជន់លិចពេលមានភ្លៀងធ្លាក់ម្តងៗ។ កាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៧កន្លងទៅ អភិបាល នៃគណៈអភិបាលខណ្ឌ បានចាត់កម្លាំងដើម្បីធ្វើការប្រមូលកាកសំណល់សម្អាតសំរាម ជូនប្រជាពលរដ្ឋ នៅតាមដងផ្លូវ ចៀសវាងការហូរចូលសំរាមក្នុងប្រព័ន្ធលូពេលមានភ្លៀងធ្លាក់ នៅចំណុចកែងស្តុបផ្លូវលេខ៥៩៨ (ម្តុំលក់ផ្កា) ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។[90]

ម្យ៉ាងវិញទៀត ការប្រមូលសំរាមតែម្យ៉ាង គឺមិនអាចដោះស្រាយបញ្ហាទាំងស្រុងនោះទេ ដូច្នេះសាលាខណ្ឌឫស្សីកែវ បានធ្វើការជួសជុល និងបង្កើតប្រព័ន្ធលូថ្មី ដោយបានធ្វើការស្តារលូមួយចំនួនដែលមានការកកស្ទះ ជាពិសេសការរៀបចំដាក់លូនៅតាមផ្សារនានាដែលស្ថិតក្នុងខណ្ឌ ព្រមទាំងធ្វើការដាក់លូថ្មីបន្ថែម ដែលមានទំហំធំជាងមុន ដើម្បីកាត់បន្ថយការកកស្ទះនេះ។ កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញបានដាក់លូបេតុងប្រអប់នៅប្រឡាយថ្មី១ខ្សែតភ្ជាប់ពីប្រឡាយបាក់ទូកទៅប្រឡាយអូរវែង ក្នុងខណ្ឌឫស្សីកែវ ដើម្បីដោះស្រាយបញ្ហាទឹកលិចនៅរាជធានីភ្នំពេញ។ គម្រោងដាក់លូបេតុងប្រអប់ប្រឡាយថ្មី១ខ្សែនេះ មានទំហំ ២.៤ម៉ែត្រ កំពស់ ២ម៉ែត្រ ប្រវែង ៣៦០ម៉ែត្រ តភ្ជាប់ពីប្រឡាយបាក់ទូកទៅប្រឡាយអូរវែង ដែលជាតំបន់ភូមិសាស្ត្រសង្កាត់ទួលសង្កែ ក្នុងខណ្ឌឫស្សីកែវ។ ដោយឃើញថាបច្ចុប្បន្ននេះ នៅរាជធានីភ្នំពេញជួបប្រទះ និងបញ្ហាលិចផ្លូវ ដែលបណ្តាលឲ្យស្ទះលូនៅពេលមានភ្លៀងធ្លាក់ខ្លាំង សាលាក្រុងភ្នំពេញបានរៀបចំដាក់លូបេតុងប្រអប់ប្រឡាយថ្មី១ខ្សែបន្ថែមទៀត ដើម្បីសម្រួលដល់ការបង្ហូរផ្លូវទឹកអោយបានល្អប្រសើរ។[91]

ការស្តារលូ និងរៀបចំប្រព័ន្ធលូឡើងវិញ បានធ្វើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានសភាពប្រសើរជាងមុន ដែលអាចកាត់បន្ថយបញ្ហាទឹកកខ្វក់ ទឹកស្អុយ បង្កើតឲ្យមានខ្យល់អាកាសបរិសុទ្ធ ព្រមទាំងជួយឲ្យខណ្ឌមានសោភណ្ឌភាពប្រសើរជាងមុន។

#### ២.៣.៤.២. ផលប៉ះពាល់នៃការបង្ហូរទឹកស្អុយដោយមិនបានធ្វើការចម្រោះ

ការបង្ហូរទឹកស្អុយតាមលូបញ្ចូលក្នុងទន្លេដោយគ្មានចម្រោះ បានធ្វើឲ្យសុខភាពពលរដ្ឋកាន់តែរងគ្រោះ និងកាន់តែបំផ្លាញបរិស្ថានតាមដងទន្លេ។ ពលរដ្ឋដែលរស់នៅតាមដងប្រឡាយទឹកស្អុយបង្ហូរចេញពីរាជធានីភ្នំពេញមួយកន្លែង នៅម្តុំសង្កាត់ស្វាយប៉ាក ក្នុងខណ្ឌឫស្សីកែវ ក្រៅពីព្រួយបារម្ភបញ្ហាសុខភាព ពួកគេក៏បានរអ៊ូរទាំថាគ្មានសុភមង្គលក្នុងគ្រួសារ ដោយសារតែក្លិនស្អុយនៃទឹកលូនេះ។ សង្គមស៊ីវិល ថាការបង្ហូរទឹកស្អុយនេះប៉ះពាល់ទាំងសុខភាពមនុស្ស និងបរិស្ថានចម្រុះក្នុងទឹកទន្លេ។ ពលរដ្ឋដែលមានផ្ទះលើខ្នងប្រឡាយទឹកស្អុយគីឡូម៉ែត្រលេខ៩ បានត្អូញត្អែរអំពីក្លិនស្អុយនៃលូបង្ហូរទឹកស្អុយពីរាជធានីភ្នំពេញ

---

[90] គេហទំព័រ http://grandnewsasia.com ចូលមើលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩

[91] គេហទំព័រ https://urbanvoicecambodia.net/សាលាក្រុងភ្នំពេញ ចូលមើលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩

ចូលក្នុងទឹកទន្លេ ព្រោះតែទឹកស្អុយហូរតាមប្រឡាយនេះ មិនបានចម្រោះ ឬមិនបានធ្វើប្រព្រឹត្តិកម្មឲ្យទឹកស្អាតជាមុន។ ការបង្ហូរទឹកស្អុយតាមប្រឡាយគីឡូម៉ែត្រលេខ៩ ដោយគ្មានការចម្រោះត្រឹមត្រូវនេះ ក្រៅពីពលរដ្ឋដែលរស់នៅ និងឆ្លងកាត់រងផលប៉ះពាល់ហើយនោះ ទឹកទន្លេ និងជីវចម្រុះក្នុងទន្លេ ក៏រងផលប៉ះពាល់ខ្លាំងដែរ។ សង្គមស៊ីវិលស្នើឲ្យអាជ្ញាធរ គួរតែមានវិធានការក្នុងការច្រោះទឹកកង្វក់ឲ្យបានស្អាតជាមុន មុននឹងបង្ហូរចូលទឹកទន្លេ។ ចំពោះការបង្ហូរទឹកស្អុយដោយគ្មានចម្រោះឲ្យបានស្អាតជាមុន មុនពេលបង្ហូរចូលក្នុងទន្លេ វានឹងជះឥទ្ធិពលអាក្រក់សម្រាប់បរិស្ថាន ហើយអ្នកដែលរងគ្រោះពីការបង្ហូរទឹកស្អុយ គឺជាប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកដោយផ្ទាល់ ត្រី និងជីវចម្រុះក្នុងទន្លេ ព្រោះថា ពេលដែលបង្ហូរចូលទៅក្នុងទន្លេធម្មជាតិ ឬមួយបឹងបួរ ធម្មជាតិ វាធ្វើឲ្យកើតមានទាក់ទងការបំពុលទឹកកើតឡើង។ អ្នកដែលទទួលរងផលប៉ះពាល់ អាចជាមច្ឆជាតិ រុក្ខជាតិនានា ដែលជាធនធានដែលមានជីវិតនៅក្នុងទឹក ហើយអាចជាប្រជាពលរដ្ឋដែលគាត់ប្រើប្រាស់ទឹកផ្ទាល់ពីអាងទន្លេ។[92] ចំពោះវិធានការក្នុងការច្រោះទឹកឱ្យបានស្អាតមុនបង្ហូរចូលទៅក្នុងទឹកទន្លេ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយការពារបរិស្ថានទាំងធនធានចម្រុះដែលរស់នៅក្នុងទឹកទន្លេ និង ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ទាំងនោះ។ ម្យ៉ាងទៀតការច្រោះទឹកឱ្យបានស្អាតមុនបង្ហូរចូលទឹកទន្លេ គឺជាគោលដៅមួយក្នុងការចូលរួមការពារបរិស្ថាន បំបាត់នូវភាពកង្វក់ និងបញ្ហាទឹកស្អុយ ជាពិសេសនោះគឺជួយក្នុងការការពារសុខភាពប្រជាពលរដ្ឋដែលរស់នៅតំបន់ទាំងនោះ និងអាចញ៉ាំងឱ្យបរិយាកាសនៅតំបន់នោះមានខ្យល់អាកាសបរិសុទ្ធក្នុងគោលបំណងធ្វើឱ្យសោភណ្ឌភាពបរិស្ថាននៅក្នុងខណ្ឌមានភាពល្អប្រសើរជាងមុន។

### ២.៤. បញ្ហាប្រឈម និងដំណោះស្រាយចំពោះសោភណ្ឌភាព

ជាទូទៅ រាល់អ្វីៗទាំងអស់ដែលបានកើតឡើងក្នុងសង្គម គឺវាមិនមានភាពស្ថិតស្ថេរនោះទេ ពោលគឺតែងតែមានបញ្ហាប្រឈមដែលវាតែងតែកើតឡើង ហើយរាល់បញ្ហាប្រឈមតែងតែមានដំណោះស្រាយដើម្បីធ្វើយ៉ាងណារកយុត្តិសាស្ត្រមកដោះស្រាយបញ្ហាទាំងនោះឲ្យមានភាពប្រសើរឡើង។ សោភណ្ឌភាពគឺជាចំណុចចម្បងមួយដែលត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំងនោះតាមតំបន់នានា។ ដូច្នេះកាលណាខណ្ឌមួយជួបនូវបញ្ហាប្រឈម នោះគេនឹងព្យាយាមរកដំណោះស្រាយថ្មីៗជាច្រើនដើម្បីឲ្យស្ថានភាពរបស់ខណ្ឌនោះមានសោភណ្ឌភាពឡើងវិញ។

#### ២.៤.១. បញ្ហាប្រឈម

ជាទូទៅរាល់ការអភិវឌ្ឍ និង ការរៀបចំនូវសោភណ្ឌភាពនៅក្នុងសង្គមមួយ ឬតំបន់មួយឲ្យទទួលបាននូវភាពល្អប្រសើរឡើង រមែងតែងតែមានជួបនូវបញ្ហាប្រឈមមួយចំនួនដែលត្រូវធ្វើការដោះស្រាយ។ ជាក់ស្តែង បើយើងក្រលេកមើលទៅលើការរៀបចំនូវសោភណ្ឌភាពខណ្ឌឫស្សីកែវ ក៏មាននូវបញ្ហាប្រឈមមួយចំនួនមានដូចក្រោម ៖

[92] គេហទំព័រ https://www.rfa.org/khmer/news/environment ចូលមើលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩

- **បញ្ហាទី១៖ គមនាគមន៍**

ខណ្ឌឫស្សីកែវមានផ្លូវជាតិលេខ៥ ឆ្លងកាត់ ដែលជាផ្លូវសេដ្ឋកិច្ចយ៉ាងសំខាន់ និងមានផ្លូវបេតុងឆ្លងកាត់ពីសង្កាត់មួយទៅសង្កាត់មួយ ពីភូមិមួយ ទៅភូមិមួយទៀតជាច្រើនខ្សែ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ភូមិសាស្ត្រខណ្ឌឫស្សីកែវនៅតែមានផ្លូវមួយចំនួនខូច និងមានផ្លូវដីជាច្រើនខ្សែ ធ្វើឲ្យពិបាកក្នុងការធ្វើដំណើរ។[93]

- **បញ្ហាទី២៖ ការប្រើប្រាស់ដីធ្លី**

ចំពោះបញ្ហាការប្រើប្រាស់ដីធ្លីនៅក្នុងខណ្ឌ នៅតែបន្តមានការរំលោភកាន់កាប់ដីសាធារណៈរបស់រដ្ឋ ដោយមានទំនាស់ព្រំប្រទល់ជាបន្តបន្ទាប់ មានការតាំងលំនៅឋានមួយចំនួន មិនទាន់បានគោរព តាមនគរូបនីយបញ្ញត្តិ ការសាងសង់គ្មានច្បាប់អនុញ្ញាតិ។ កត្តាទាំងនេះកើតឡើងដោយសារការមិនគោរពច្បាប់ មានជនខិលខូចឆ្លៀតឱកាស ទៅដីប្រជាពលរដ្ឋមួយចំនួនដែលមិនទាន់មាន ប័ណ្ណកម្មសិទ្ធិ តំបន់មិនទាន់អភិវឌ្ឍន៍ ប្រជាជនមួយចំនួនបានរំលោភកាន់កាប់ទៅលើដីរបស់រដ្ឋ ដូចជា លើប្រឡាយ ចំណីផ្លូវ និងបង្កការលំបាកដល់អាជ្ញាធរក្នុងការគ្រប់គ្រង ការពាររបៀបរៀបរយ និងសោភណ្ឌភាពរបស់ខណ្ឌព្រមទាំងបង្កវិវាទជាញឹកញាប់។[94]

- **បញ្ហាទី៣៖ បរិស្ថាន**

ចំពោះបញ្ហាបរិស្ថាននៅក្នុងខណ្ឌ សំរាមនៅតែចោទជាបញ្ហា ដោយមានការកកស្ទះកន្លែងមួយចំនួននៅសេសសល់តាមសំណង់មិនរៀបរយ ការទុកដាក់សំរាមចោលរាយប៉ាយ រថយន្តចូលមិនរួច ផ្លូវតូចចង្អៀត ស្ទះប្រព័ន្ធលូ ដោយសារប្រជាពលរដ្ឋមួយចំនួនមិនយល់ដឹងពីវិធីញែកសំរាម នៅមានទម្លាប់ចោលសំរាមផ្តេសផ្តាសតាមប្រឡាយប្រជាពលរដ្ឋបញ្ចេញសំរាមខុសជើងរថយន្ត។[95]

### ២.៤.២. ដំណោះស្រាយ

បើទោះបីជា ខណ្ឌឫស្សីកែវមានបញ្ហាប្រឈមបានកើតឡើងក៏ដោយ ប៉ុន្តែសាលាខណ្ឌបានធ្វើការយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់ដើម្បីធ្វើយ៉ាងណាកែប្រែនូវស្ថានភាពខណ្ឌឲ្យមានសោភណ្ឌភាពល្អប្រសើរឡើងវិញដូចជា

- **ដំណោះស្រាយបញ្ហាទី១៖ គមនាគមន៍**

ចំពោះបញ្ហាគមនាគមន៍ សាលាខណ្ឌបានធ្វើការដោះស្រាយជូនប្រជាពលរដ្ឋ ដើម្បីធ្វើឲ្យផ្លូវថ្នល់មានសភាពប្រសើរឡើងដូចខាងក្រោម៖

  - ចាត់វិធានការជួសជុលផ្លូវខូច

---

[93] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០ របស់ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រង់ទំព័រទី១៨

[94] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០ របស់ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រង់ទំព័រទី២១

[95] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០ របស់ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រង់ទំព័រទី២១

- កសាងផ្លូវដោយការចាក់បេតុងអាមេ និងកៅស៊ូ
- ត្រួតពិនិត្យការបើកបររបស់ប្រជាពលរដ្ឋដែលដឹកលើសចំណុះ និងចាត់វិធានការចំពោះឡានសណ្តោងដែលធ្វើឲ្យខូចខាតផ្លូវ។

➢ **ដំណោះស្រាយបញ្ហាទី២៖ ការប្រើប្រាស់ដីធ្លី**

ចំពោះបញ្ហាក្នុងការប្រើប្រាស់ដីធ្លីក្នុងខណ្ឌវិញ សាលាខណ្ឌបានធ្វើការដោះស្រាយជូនប្រជាពលរដ្ឋចំពោះវិវាទដែលបានកើតឡើងដូចខាងក្រោម៖

- ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ
- ផ្តល់ប័ណ្ណកម្មសិទ្ធិដីជូនប្រជាពលរដ្ឋ
- ផ្សព្វផ្សាយច្បាប់ភូមិបាល

➢ **ដំណោះស្រាយបញ្ហាទី៣៖ បរិស្ថាន**

ចំពោះបញ្ហាបរិស្ថានដែលបានកើតឡើងក្នុងខណ្ឌឫស្សីកែវវិញ ដោយមានការយកចិត្តទុកដាក់ពីបញ្ហាសោភណ្ឌភាពរបស់ខណ្ឌ ក៏ដូចជាសុខភាពប្រជាពលរដ្ឋទាំងមូលនៅក្នុងខណ្ឌ សាលាខណ្ឌបានធ្វើការដោះស្រាយ និងមានវិធានការដូចខាងក្រោម៖

- អប់រំចំណេះដឹងស្តីពីបរិស្ថាន និងច្បាប់បរិស្ថាន
- អប់រំប្រជាពលរដ្ឋឲ្យយល់ដឹងពីការញែកសំរាម វេចខ្ចប់សំរាម ទុកដាក់សំរាម
- ចាត់វិធានការគ្រប់គ្រងកាកសំណល់ឲ្យបានត្រឹមត្រូវ
- ដាកពិន័យចំពោះជនណា ដែលបំពានទៅលើច្បាប់បរិស្ថាន
- ដាក់បម្រាមចំពោះការទុកដាក់ និងចោលសំរាមផ្តេសផ្តាសគ្មានរបៀបរៀបរយ។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើបានបង្ហាញថា ការរៀបចំសណ្ដាប់ធ្នាប់ និងសោភណ្ឌភាពពិតជាមានសារៈសំខាន់ណាស់ ក្នុងគោលបំណងធ្វើឲ្យទីក្រុងមានរបៀបរៀបរយ និងមានសោភណ្ឌភាពល្អ។ ដោយឡែក ទោះបីជាមានការកសាង និងការអភិវឌ្ឍក៏ពិតមែន ក៏វានៅតែមានភាពខ្វះចន្លោះនៅឡើយ។ ការរៀបចំសណ្ដាប់ធ្នាប់ និងសោភណ្ឌភាពក្នុងខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់២០១៨ កន្លងមក នៅតែមានការជួបប្រទះទៅនឹងបញ្ហាមួយចំនួនដូចខណ្ឌដទៃទៀតដែរ មានន័យថាទោះបីជាខណ្ឌនេះមានការរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ថ្នល់ ប្រព័ន្ធលូទឹកស្អុយ សួនច្បារ ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវ សួនច្បារ ការរៀបចំចិញ្ចើមផ្លូវ សំណង់អគារ ដាំដើមឈើលំអផ្លូវបរិស្ថាន មានការសម្អាត និងគ្រប់គ្រងសំរាមទីសាធារណៈ....ក៏ពិតមែន ប៉ុន្តែខណ្ឌនៅតែជួបប្រទះនូវបញ្ហាសណ្ដាប់ធ្នាប់ និងសោភណ្ឌភាពនៅតាមតំបន់មួយចំនួននៅឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាខណ្ឌមានការរៀបចំ និងការអភិវឌ្ឍយ៉ាងច្រើនស្ទើរគ្រប់វិស័យក៏ពិតមែន ក៏ប៉ុន្តែយើងសង្កេតឃើញថា ការអភិវឌ្ឍរបស់ខណ្ឌនៅតែមិនទាន់ទទួលបានលទ្ធផលដូចជាការរំពឹងទុករបស់ផែនការអភិវឌ្ឍរបស់ខណ្ឌនៅឡើយ។ ជាក់ស្តែង បញ្ហាសណ្ដាប់ធ្នាប់ និងសោភណ្ឌរបស់ខណ្ឌ គឺជាបញ្ហាចម្បងមួយ ដែលខណ្ឌបាននឹងកំពុងធ្វើការយកចិត្តទុកដាក់ក្នុងការកែប្រែរៀបចំកសាង ហេដ្ឋារចនាសម្ព័ន្ធបន្ថែម ព្រមទាំងយកចិត្តទុកដាក់ទៅលើការរៀបចំសោភណ្ឌភាពរបស់ខណ្ឌ ដើម្បីឲ្យខណ្ឌមានសណ្ដាប់ធ្នាប់ និងសោភណ្ឌភាពកាន់តែល្អប្រសើរជាងមុន។ ជាពិសេសសាលាខណ្ឌបានធ្វើការរៀបចំនូវសណ្ដាប់ធ្នាប់តាមខណ្ឌ មានដូចជា ការរៀបចំគ្រប់គ្រងសណ្ដាប់ធ្នាប់របស់អាជីវករតាមទីផ្សារដែលបានយកចិញ្ចើមផ្លូវធ្វើជាអាជីវកម្មផ្ទាល់ខ្លួន ការរុះរើសំយ៉ាបផ្ទះរបស់ប្រជាពលរដ្ឋដែលប៉ះពាល់លើដីចំណីផ្លូវសាធារណៈ ការគ្រប់គ្រងសំណង់អគារ ផ្ទះល្វែង បុរី ការគ្រប់គ្រងក្មេងទំនើងលួច ឆក់ ប្លន់ គ្រប់ប្រភេទ ការផលិត ការចែកចាយ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការលេងល្បែងស៊ីសងខុសច្បាប់ប្រភេទ ដែលទាំងនេះជាប្រឈម ដែលប៉ះពាល់យ៉ាងខ្លាំងទៅដល់សណ្ដាប់ធ្នាប់របស់ខណ្ឌ។ លើសពីនេះ យើងសង្កេតឃើញថា សាលាខណ្ឌបានធ្វើការយកចិត្តទុកដាក់លើបញ្ហាការរៀបចំស្តារនូវប្រព័ន្ធលូទឹកស្អុយ ដែលបង្កមកពីការកកស្ទះដោយសារសំរាម ការកសាង និងជួសជុលផ្លូវ ដែលខូចខាត លិចលង់ ការរៀបចំកសាងសួនច្បារ ការដាក់ភ្លើងបំភ្លឺតាមដងផ្លូវ ជាពិសេសការគ្រប់គ្រងសំរាមនៅតាមដងផ្លូវ ដែលបង្កឲ្យមានក្លិនមិនល្អ ព្រមទាំងហូរចូលប្រព័ន្ធលូដែលបង្កឲ្យមានការកកស្ទះពេលមានភ្លៀង ដែលទាំងនេះជាបញ្ហាប្រឈម ដែលធ្វើឲ្យប៉ះពាល់ទៅដល់សោភណ្ឌភាពខណ្ឌផងដែរ។

យ៉ាងណាមិញ ក្នុងការសិក្សាស្វែងយល់ទៅលើប្រធានបទសារណា **“ការរៀបចំសណ្ដាប់ ធ្នាប់ និងសោភណ្ឌភាពក្នុងខណ្ឌឫស្សីកែវ ឆ្នាំ២០១៥ ដល់២០១៨”** នេះទៀតសោត បានធ្វើឲ្យយើងខ្ញុំទាំងពីរនាក់បានយល់ដឹងកាន់តែច្បាស់ពីផលប៉ះពាល់នៃការរៀបចំសណ្ដាប់ធ្នាប់ និងសោភណ្ឌភាពរបស់ខណ្ឌ

ឫស្សីកែវព្រមទាំងបានយល់ដឹងកាន់តែច្បាស់ពីផលប្រយោជន៍នៃការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាពផងដែរ។ ផលប្រយោជន៍ដែលបានមកពីការរៀបចំនោះ មិនត្រឹមតែធ្វើឲ្យខណ្ឌមានរបៀបរៀបរយ និងសោភណ្ឌភាពប៉ុណ្ណោះទេ គឺថែមទាំងធ្វើឲ្យក្រុងកាន់តែមានភាពទាក់ទាញ ដោយសារសោភណ្ឌភាពរបស់ខណ្ឌជាផ្នែកមួយនៃសោភណ្ឌភាពរបស់ក្រុង។ ម៉្យាងវិញទៀត ផលប្រយោជន៍នៃការរៀបចំនេះ បានធ្វើឲ្យខណ្ឌមានការអភិវឌ្ឍស្ទើរតែគ្រប់វិស័យទៀតផង។ លើសពីនេះទៅទៀត ការរៀបចំនូវសណ្តាប់ធ្នាប់បានធ្វើឲ្យខណ្ឌទាំងមូល មានសុវត្ថិភាព សន្តិសុខពេញលេញ ដែលធ្វើឲ្យប្រជាពលរដ្ឋមានការរស់នៅប្រកបដោយសេចក្តីសុខ និងពោរពេញទៅដោយភាពស៊ីវិល័យ ឬទាន់សម័យទៅតាមសម័យកាលបច្ចុប្បន្ន។

សរុបមកយើងអាចសន្និដ្ឋានបានថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាព គឺពិតជាមានសារៈសំខាន់ណាស់ ទោះបីជាក្នុងពេលនេះមិនទាន់នឹងទទួលបានជោគជ័យក៏ពិតមែន ប៉ុន្តែនៅពេលខាងមុខពិតជាអាចទទួលបាននូវភាពជោគជ័យជាក់ជាមិនខាន ព្រោះថាបើកាលណាមានការចូលរួមសហការរវាងរាជរដ្ឋាភិបាល ក៏ដូចជា អាជ្ញាធរពាក់ព័ន្ធ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ជាពិសេសនោះគឺ បងប្អូនប្រជាពលរដ្ឋមានការចូលរួមសហការក្នុងការជួយរៀបចំសណ្តាប់ធ្នាប់ និងសោភណ្ឌភាព ពិតប្រាកដណាស់អាចនឹងទទួលបាននូវភាពស្រស់ស្អាត បរិយាកាសរស់នៅល្អ មានផាសុខភាព ប្រជាពលរដ្ឋមានការរស់នៅប្រកបទៅដោយសុខ សុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ជាពិសេសនោះធ្វើឱ្យសណ្តាប់ធ្នាប់ និងសោភណ្ឌភាពកាន់តែមានភាពល្អប្រសើរតទៅមុខជារៀងរហូត។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ខណ្ឌឫស្សីកែវក៏មានបញ្ហាប្រឈមមួយចំនួនដែល បញ្ហាទាំងនោះភាគច្រើនដែលបានកើតឡើងដដែលៗ ទោះបីជាមានការអភិវឌ្ឍខ្លះក៏ពិតមែន ប៉ុន្តែវានៅតែចោទជាបញ្ហា ដែលប្រជាពលរដ្ឋចង់ឱ្យអាជ្ញាធរ ធ្វើការកែសម្រួលនូវបញ្ហាទាំងនេះ ដែលមានដូចជា ផ្លូវថ្នល់ លូ ការលក់ដូរគ្មានសណ្តាប់ធ្នាប់តាមចិញ្ចើមផ្លូវ និងបញ្ហាអសន្តិសុខផ្សេងៗ។ ម្យ៉ាងវិញទៀត បញ្ហាកាកសំណល់ ឬសំរាម វាជាបញ្ហាដែលកើតមានឡើង ព្រោះសំរាមតាមដងផ្លូវ និងការទុកដាក់គ្មានសណ្តាប់ធ្នាប់ ដែលធ្វើឱ្យប៉ះពាល់ដល់សោភណ្ឌភាព និងបរិស្ថានរបស់ខណ្ឌ ព្រមទាំងធ្វើឱ្យមានការកកស្ទះដល់ប្រព័ន្ធលូបង្ហូរទឹកផ្សេងៗ។ ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ យើងខ្ញុំទាំងពីរនាក់ សូមមានមតិយោបល់ដូចតទៅ ៖

- សូមអំពាវនាវដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ សូមជួយយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើបញ្ហាទាំងអស់នេះដូចជា សន្តិសុខ សណ្តាប់ធ្នាប់ និងបន្ថែមការប្រុងប្រយ័ត្នចំពោះបញ្ហាចោរកម្ម ក្មេងទំនើង គ្រឿងញៀន និងត្រួតពិនិត្យលើបញ្ហាសំរាម ដើម្បីកុំឱ្យមានផលប៉ះពាល់ ទៅដល់សុវត្ថិភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ និងសោភណ្ឌភាពរបស់ខណ្ឌ។
- សូមធ្វើការអំពាវនាវទៅដល់សាលារាជធានីភ្នំពេញ សូមឱ្យមានការផ្តល់នូវកញ្ចប់ថវិកាទៅដល់ខណ្ឌឫស្សីកែវឱ្យបានគ្រប់គ្រាន់ ដើម្បីជួយសម្រួលឱ្យខណ្ឌមានភាពងាយស្រួល ក្នុងការអភិវឌ្ឍខណ្ឌរបស់ខ្លួនឱ្យបានល្អប្រសើរឡើង។
- សូមអំពាវនាវទៅដល់អាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ធ្វើការកែលម្អ និងយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាចម្បងសំខាន់ៗនៅក្នុងខណ្ឌដូចជា បញ្ហាកកស្ទះចរាចរណ៍ បញ្ហាស្ទះលូ បញ្ហាសំរាម ការកសាងសួនច្បារ និងការដាំដើមឈើតាមដងផ្លូវ ឱ្យបានកាន់តែល្អប្រសើរជាងមុន។
- សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមឱ្យមានការអភិវឌ្ឍទៅលើបណ្តាហេដ្ឋារចនាសម្ព័ន្ធឱ្យបានច្រើនជាងមុនជាពិសេស ធ្វើការកែលម្អ និងជួសជុលនូវផ្លូវដែលមានការខូចខាតឱ្យមានភាពល្អវិញ ក៏ដូចជាកែប្រែពីផ្លូវដីមកជាផ្លូវចាក់បេតុង ឬផ្លូវកៅស៊ូជាដើម ហើយក៏សូមសំណូមពរផងដែរទៅលើបញ្ហាប្រព័ន្ធលូបង្ហូរទឹក សូមធ្វើការអភិវឌ្ឍឱ្យបានទាន់ពេលវេលា ជាពិសេសធ្វើការកែលម្អប្រព័ន្ធលូពីតូចទៅធំនៅតាមតំបន់មួយចំនួន ដែលរងនូវការជន់លិចនៅពេលមានភ្លៀងធ្លាក់ និងធ្វើការស្តារនូវប្រព័ន្ធលូចាស់ៗឡើងវិញ ដែលនេះជាបញ្ហាមួយដែលគួរយកចិត្តទុកដាក់ឱ្យបានល្អជាទីបំផុត។ ដូច្នេះ សូមធ្វើការរៀបចំឱ្យមានភាពល្អប្រសើរ និងតាមស្តង់ដារនៅគ្រប់ទីកន្លែងទាំងអស់ ដើម្បីចៀសវាងមានការខូចខាតផ្លូវបន្តទៀត និងចៀសវាងនូវការកកស្ទះនូវប្រព័ន្ធលូ ដែលនាំឱ្យពិបាកក្នុងការធ្វើដំណើរ ជាពិសេសបាត់បង់នូវសណ្តាប់ធ្នាប់ និងសោភណ្ឌភាពក្នុងខណ្ឌ និងរាជធានីភ្នំពេញទាំងមូល។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

## ១. លិខិតបទដ្ឋានគតិយុត្តិ

- ច្បាប់ស្តីពី "ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" អនុម័តថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៤
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- ច្បាប់ស្តីពី "ចរាចរណ៍ផ្លូវគោក" អនុម័តថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ និងប្រកាសជាផ្លូវការនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥
- គោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" អនុម័តថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០
- សជណ លេខ ៧៥៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ១២៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៧៥៧ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៧៥៦ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៧៥២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៣២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៦៦៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៩០៥ ចុះថ្ងៃច័ន្ទ ១៣រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក្ត ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៦៥០ ចុះថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ១៣០២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ ០១៣/១៨ ស្តីពីសេចក្តីណែនាំស្តីពី "ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ"
- សជណ លេខ ១២៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៧៥៧ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ
- សជណ លេខ ៧៥៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលខណ្ឌឫស្សីកែវ

## ២. សៀវភៅ

- សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា របស់បណ្ឌិត អ៊ូ វ៉ឌី គ្រឹះស្ថានបោះពុម្ពផ្សាយ ឆ្នាំ ២០១២
- សៀវភៅប្រវត្តិសាស្ត្រខ្មែរភាគទី១ បោះពុម្ពលើកទី១ គ.ស១៩៧៣ ព.ស ២៥១៧ ដោយ សាស្ត្រាចារ្យ ត្រឹង ងា
- សៀវភៅប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដោយបណ្ឌិត មីសែល ត្រាណេ ឆ្នាំ២០០៦
- សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០១៩
- សៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ឆ្នាំ២០១៥-២០១៧ របស់ខណ្ឌឫស្សីកែវ
- សៀវភៅភូមិវិទ្យា សេដ្ឋកិច្ច និងមនុស្ស នៃប្រទេសកម្ពុជា ដែលរៀបរៀងដោយ គណ:កម្មការរៀបរៀងគឺ លោក-លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៤
- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៥- ២០១៧) របស់ខណ្ឌឫស្សីកែវ
- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៦-២០១៨) របស់ខណ្ឌឫស្សីកែវ
- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌឫស្សីកែវឆ្នាំ២០១៨-២០២០
- សៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ខណ្ឌឫស្សីកែវ ឆ្នាំ ២០១៥-២០១៩
- សៀវភៅនីតិនគរូបនីយកម្មវិទ្យា របស់លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ឆ្នាំសិក្សា ២០១៧-២០១៨

## ៣. គេហទំព័រ

- គេហទំព័ររបស់សាលារាជធានីភ្នំពេញ www.phnompenh.gov.kh
- គេហទំព័ររបស់សាលារាជធានីភ្នំពេញ www.phnompenh.gov.kh ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧
- គេហទំព័រ mrd.gov.kh>2015-01-Phnom-Penh របាយការណ៍ខែមករា ឆ្នាំ២០១៥ របស់មន្ទីរ អភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ
- គេហទំព័រ http://phnompenh.gov.kh
- គេហទំព័រ https://khmersaharika.com
- គេហទំព័រ http://wgccpn.com/index.php/rusey-keo/9-rusey-keo/4137-2018-05-09-09-25-07
- គេហទំព័រ realestae.com.kh

- គេហទំព័រ www.cambodiacleancity.gov.kh
- https://urbanvoicecambodia.net/សាលាក្រុងភ្នំពេញ
- https://www.rfa.org/khmer/news/environment
- http://grandnewsasia.com
- គេហទំព័រ Freshnewsasia.com
- គេហទំព័រ http:// Freshnewsasia.com
- https://urbanvoicecambodia.net
- គេហទំព័រ https://m.campost.news
- គេហទំព័រ https://www.google.com
- គេហទំព័រ https://www.khmerrean.com
- គេហទំព័រ apsaracentral.com
- គេហទំព័រ www.cambodiacleancity.gov.kh

## ៤. វចនានុក្រម

- វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

## ៥. ផ្សេងៗ

- តារាងវចនាសម្ព័ន្ធខណ្ឌឫស្សីកែវឆ្នាំ២០១៩
- របាយការណ៍ស្តីពី តួនាទី ភារកិច្ចរបស់ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុខណ្ឌឫស្សីកែវ
- កំណត់ហេតុស្តីពីការត្រួតពិនិត្យស្ថានភាពសួនច្បារ និងដើមឈើដែលមានសភាពខូចខាតក្នុងរាជធានីភ្នំពេញរបស់រដ្ឋបាលរាជធានីភ្នំពេញ

# ឧបសម្ព័ន្ធ

## មាតិកាឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖ ច្បាប់ស្ដីពី "ការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់"**

**ឧបសម្ព័ន្ធទី២៖ អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្ដីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន"**

**ឧបសម្ព័ន្ធទី៣៖ ច្បាប់ចរាចរណ៍ផ្លូវគោក**

**ឧបសម្ព័ន្ធទី៤៖ ផែនការណែនាំស្ដីពី ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព"**

**ឧបសម្ព័ន្ធទី៥៖ ផែនទីភូមិសាស្ត្រខណ្ឌឬស្សីកែវ**

**ឧបសម្ព័ន្ធទី៦៖ ប្លង់រាជធានីភ្នំពេញ**

**ឧបសម្ព័ន្ធទី៧៖ ប្លង់គោលរាជធានីភ្នំពេញ ឆ្នាំ២០២០**

**ឧបសម្ព័ន្ធទី៨៖ រចនាសម្ព័ន្ធខណ្ឌឬស្សីកែវ**

**ឧបសម្ព័ន្ធទី៩៖ តារាងរាយឈ្មោះឧកញ៉ា ម្ចាស់អាជីវកម្មបុរី និងសំណង់ផ្ទះល្វែងក្នុងមូលដ្ឋានខណ្ឌឬស្សីកែវ**

**ឧបសម្ព័ន្ធទី១០៖ រូបភាពសាលាខណ្ឌឬស្សីកែវ**

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

# ច្បាប់

## ស្តីពី

# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់
# ស្តីពី
# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

## ជំពូកទី ១
## កម្មវត្ថុ

មាត្រា ១.-

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំកែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

- គោរពប្រយោជន៍រួមនិងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផងនិងត្រួតពិនិត្យការសាងសង់ផង ។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រនិងលក្ខណៈពិសេសនៃជនបទនីមួយៗ ។
- ធានាលើកតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍និងរក្សាបាននូវគុណភាពបរិដ្ឋាន ។

មាត្រា ២.-

ច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែឬផ្លាស់ប្តូរ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នឹងត្រូវកែច្នៃអោយស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

មាត្រា ៣.-

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលមានសមាជិកនិងសំណើការតែងតាំងនឹងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់សំរាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំ-ពេញឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ សំរាប់ក្រុងភ្នំពេញត្រូវកំរិតដោយអនុក្រឹត្យ ។

ចំពោះខេត្ត ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលដឹកនាំដោយអភិបាលខេត្ត ក្រុង និងអង្គភាពបច្ចេកទេសខេត្ត ក្រុង ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយសេចក្តីសំ-រេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ ។

〰〰〰

# ជំពូកទី ២

## ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

មាត្រា ៤.-

ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ អោយសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិដ្ឋានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

មាត្រា ៥.-

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានីភ្នំពេញឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ខេត្ត ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំនិងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់និងកំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាននិងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានភារៈរៀបចំប្លង់គោលសំរាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

# ជំពូកទី ៣
## ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់

មាត្រា ៦.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

មាត្រា ៧.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់ សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខាសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

មាត្រា ៨.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៩.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់សំរាប់រាជធានីនិងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានី ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ទៀត ។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងដែរ ។

មាត្រា ១០.-

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុណាដែលនឹងផ្ដល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេស ។ បញ្ជីអចលនវត្ថុឬ

រមណីយដ្ឋានទាំងនោះនិងកំណត់ដោយអនុក្រឹត្យ ។ ការរុះរើ ការផ្លាស់ប្តូរទ្រង់ទ្រាយនិងការគ្រប់គ្រងអចលនវត្ថុនិងរមណីយដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

បទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ដល់ផ្នែក ពុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្មនិងអភិ-វឌ្ឍន៍និងចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជីអចលនវត្ថុដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពនិងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនេះ តាមបញ្ញត្តិច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

ൟൟൟ

## ជំពូកទី ៤
## ការខាររនិងសំណង់

មាត្រា ១១.-

រាល់ការកកាយរុករកឬការស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យាឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចអោយបានជ្រាបភ្លាមៗ ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ផ្អាកសំណង់ជាបន្ទាន់ ។

មាត្រា ១២.-

រាល់បុគ្គលឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនអោយសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ ៖

- ទីបំរុងទុកទឹកនិងទំនប់ទឹក
- ទីបំរុងជីករ៉ែនិងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យានិងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈនិងតំបន់អភិរក្ស
- ដីបំរុងទុកសំរាប់ផ្លូវ បំរុងសំរាប់ចំណីផ្លូវនិងដីបំរុងទុកសំរាប់ផ្លូវរថភ្លើងនិងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសង់ ។

លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខណ្ឌសំណង់ឬតាំងទីលំនៅធុនស្រាល បណ្តោះអាសន្ន អនុញ្ញាតបានដោយអនុក្រឹត្យ

មាត្រា ១៣.-

ការងារសាងសង់និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់នេះ ។

មាត្រា ១៤.-

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាពឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារនិងប្លង់ចាំបាច់ ។ និតិវិធីក្នុងការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៥.-

ឯកសារនិងប្លង់ចាំបាច់សំរាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។

លក្ខខ័ណ្ឌដែលទាមទារអំពីសញ្ញាបត្រនិងទាមទារការទទួលស្គាល់ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៦.-

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដីឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី ។

មាត្រា ១៧.-

មិនអនុញ្ញាតអោយសាងសង់នូវសំណង់ណាក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោលឬប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

មិនអនុញ្ញាតអោយសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិដ្ឋាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពបច្ចេកទេសឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ ។

មិនអនុញ្ញាតអោយសាងសង់ បើសិនជាពុំមានការរៀបចំអោយមានហេដ្ឋារចនាសម្ព័ន្ធឬបរិក្ខាសាធារណៈអោយបានគ្រប់គ្រាន់និងតំរោងសំណង់ដែលសុំ ។

មាត្រា ១៨.-

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ អាជ្ញាធរខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យពាក្យសុំនិងចេញលិខិតអនុញ្ញាតសាងសង់ ។

មាត្រា ១៩.-

ចំពោះគំរោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ។

ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សំរាប់ដំណើរការផ្នែករដ្ឋបាល ។

ការអនុញ្ញាតនេះមិនអាចនាំអោយមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈនិងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ ។

មាត្រា ២០.-

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជនបានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកអោយរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ ។

មាត្រា ២១.-

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ឬចេញលិខិតអនុញ្ញាតសាងសង់ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលមួយយ៉ាងយូរ ៤៥ ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគំរោងសាងសង់និងចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្របនឹងបទបញ្ញត្តិ ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគំរោងដែលបានអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ទណ្ឌកម្មផ្នែករដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល ។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់អោយរុះរើកែសំណង់អោយស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ គឺចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ ។

មន្ត្រីរាជការណាដែលរួមគំនិត នឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈនិងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជម្ងឺចិត្ត ។

មាត្រា ២២.-

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើវាយកំទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេសនិងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា។

មាត្រា ២៣.-

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ ច័ន្ទ ទី ២៣ ខែឧសភា ឆ្នាំ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភាលើកទី ២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្តីទី

# ឧបសម្ព័ន្ធទី២

# ឧបសម្ព័ន្ធទី៣

# ឧបសម្ព័ន្ធទី៤

ក្រសួងមហាផ្ទៃ

# ផែនការណែនាំស្តីពី

# ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព

## លក្ខណៈសម្បត្តិភូមិ ឃុំ មានសុវត្ថិភាពរួមមាន៖

១. គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ

២. គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើស គ្រប់ប្រភេទ

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

*លេខ៖ ០៦០ ផ.ក*

# ផែនការណែនាំ
# ស្តីពី
# ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព"

*សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។*

*នាឱកាសមិទ្ទិញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០* **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាង* ***ភូមិ, ឃុំមានសុវត្ថិភាព*** *ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា ។*

*ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យក* ***ភូមិ, ឃុំមានសុវត្ថិភាព*** *ធ្វើជាគោលនយោបាយអាទិភាពមួយសំរាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគត់មត់ល្អនៅគ្រប់ភូមិ, ឃុំទូទាំងប្រទេស ។*

*ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖*

**I-<u>គោលបំណង និងសំណុមពរ ៖</u>**

*១-បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ, ឃុំ, សង្កាត់ ទូទាំង*

ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែបានល្អប្រសើរថែមទៀត ។

២-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត ***គោលនយោបាយភូមិ, ឃុំមានសុវត្ថិភាព*** ។

### II-លក្ខណៈសម្បត្តិ ភូមិ, ឃុំមានសុវត្ថិភាព

***ភូមិ, ឃុំមានសុវត្ថិភាព គឺភូមិ, ឃុំដែលមានលក្ខណៈសម្បត្តិ ៥យ៉ាង ដូចខាងក្រោម៖***

**១**-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

**២**-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

**៣**-គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

**៤**-គ្មានក្មេងទំនើង

**៥**-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

### III-វិធានការ និងផែនការសកម្មភាព

#### ក-វិធានការ៖

**១**-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។

**២**-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៣**-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា <u>(ឯកសារយោង ផែនការសកម្មភាពលេខ ០២៣ ស.ក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និង</u>

ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់ ។

២-ចាត់វិធានការទប់ស្កាត់ និងបង្រ្កាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ (ឯកសារយោង សារាចរលេខ ០៦ស.រ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០៨.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ-ផែនការសកម្មភាព**

**១**-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តអោយបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព** ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំ លេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានលេខាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**២**-នគរបាលប៉ុស្តិ៍រដ្ឋបាល មាននួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកំលាំងស្នូលពិតប្រាកដ នៃចលនាការពារ "**ភូមិ, ឃុំ មានសុវត្ថិភាព**" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ ៖

-ត្រូវរៀបចំឲ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាច ព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង មេរៀនជកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សំភារៈសំរាប់បំរើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណីមានសភាពការណ៍បទល្មើស ឬឧប្បត្តិហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំងដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានា ក្នុងចលនា**ភូមិ, ឃុំមានសុវត្ថិភាព** ។

**៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវ៖**

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ជាប្រចាំ ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវបញ្ជាអោយអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ, សង្កាត់ នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយក**ភូមិ**ធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ, ឃុំ** ។

៤-ក្រោមការសំរបសំរួលរបស់រដ្ឋបាលឃុំ, សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនីមួយៗ ឬក្រុមភូមិត្រូវរៀបចំឲ្យមានវេទិកាសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ, ឃុំ** ។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស (ឯកសារយោងផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ **"ចលនាប្រជាការពារ"** លេខ ០៣៨៨ក ចុះថ្ងៃទី០៣ នៃវិច្ឆកា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។ ក្នុងវេទិការនេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយ

មិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ ។

**៥-ក្រសួងមហាផ្ទៃសូមអំពាវនាវ**

-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន ចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការ លើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ... ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

**៦**-ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទរសំរាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃដំណេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" (ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ទិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥) ។

**IV-ការចាត់តាំងអនុវត្ត**

**១**-ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បី សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដឹកនាំ និងចាត់តាំងអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាពនេះ** ។ (ភ្ជាប់ជាមួយឧបសម្ព័ន្ធ) ។

**២**-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រៅពីលេខាធិការរបស់ខ្លួន ត្រូវរៀបចំអោយមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយក**ភូមិ**ជាគោលដៅ ដើម្បីសហការអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព** ។

**៣**-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ "**ភូមិ, ឃុំ មានសុវត្ថិភាព**" ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមគោលវិធីន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់ និមួយៗ ។

៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និង លើកទិសដៅបន្តក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលសំរេច ។

**៥**-ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និង ចាត់តាំងអនុវត្តជាទូទៅ ។

**៦**-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃ លក្ខណៈសម្បត្តិរបស់**ភូមិ, ឃុំ មានសុវត្ថិភាព** ។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គល ដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។

**៧**-អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សំភារៈ បំរើដល់ការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព**នេះ ក្រសួងមហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមអនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស : ខេង**

# ឧបសម្ព័ន្ធទី៥

# ផែនទីភូមិសាស្ត្រខណ្ឌឫស្សីកែវ



# ឧបសម្ព័ន្ធទី៦


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
1:100,000
www.phnompenh.gov.kh
រក្សាសិទ្ធិ © copyright

# ឧបសម្ព័ន្ធទី៧




ផែនទី SCAN


/FocusPropertyCambodia
/FocusPropertyKH
www.focus-property.com
info@focus-property.com

# ឧបសម្ព័ន្ធទី៨

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌឫស្សីកែវ ឆ្នាំ២០១៩



# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌឫស្សីកែវ

## តារាងរាយនាមឈ្មោះឧកញ៉ា ម្ចាស់អាជីវកម្មបុរី និងសំណង់ផ្ទះល្វែងក្នុងមូលដ្ឋានខណ្ឌឫស្សីកែវ

| ល.រ | ឈ្មោះ | ផ្សេងៗ |
|---|---|---|
| 1. | លោកឧកញ៉ា ហុង ពីច | ម្ចាស់បុរី ពិភពថ្មី |
| 2. | លោកឧកញ៉ា លឹម ឈាងហាក់ | ម្ចាស់បុរី លឹម ឈាងហាក់ |
| 3. | លោកឧកញ៉ា គង់ ម៉ិនហាច | បុរីវីឡា ទួលសង្កែ |
| 4. | លោកឧកញ៉ា ម៉េង ហួត | ម្ចាស់បុរី ម៉េង ហួត |
| 5. | លោកឧកញ៉ា កុក រេន | |
| 6. | លោកឧកញ៉ា លី ហួរ | ប្រធានក្រុមហ៊ុន លី ហួរ |
| 7. | លោកឧកញ៉ា ណាង ឃុន | |

| | | |
|---|---|---|
| 8. | លោកឧកញ៉ា ឡាយ ម៉ុនឆាំ | |
| 9. | លោកឧកញ៉ា ពុង ឃាងសែ | OCIC |
| 10. | លោកឧកញ៉ា ស៊ួ សារិទ្ធិ | ម្ចាស់បុរី រិទ្ធិ |
| 11. | លោកជំទាវ អ្នកឧកញ៉ា ស៊ុយ សុផាន | ប្រធានក្រុមហ៊ុន ផាន អ៊ីមិច |
| 12. | លោកឧកញ៉ា ព្រំ សុធី | បុរីអង្គរ |
| 13. | លោកឧកញ៉ា លឹម ហាំងឃុង | កាំពុបុរី |
| 14. | លោកឧកញ៉ា ម៉ុន ហៃ | បុរី មុខទីតាល(បុរីភ្នំពេញថ្មី) |
| ឈ្មោះម្ចាស់បុរី និងសំណង់ផ្ទះល្វែង | | |
| 15. | លោក អ៊ុច ពិសាល | សេចេនរ៉េស៊ីឌិន |
| 16. | លោក ញ៉ឹក ឧណ្ណា | បុរី ភ្នំពេញសុខសាន្ត |
| 17. | លោក ហុក ឈាងលីម | បុរី មនោរម្យ |
| 18. | លោក ស៊ុន សុខគាង | ផ្ទះល្វែង ស៊ុន សុខគាង |
| 19. | លោក ឡាយ ឡុង (កូន លោក កៃ ចាន់) | ផ្ទះល្វែង សម្បត្តិមាស |
| 20. | លោក ឡាយ គង់ | ផ្ទះល្វែង ឡាយ គង់ |

| | | |
|---|---|---|
| 21. | លោក ហុក លី | ផ្ទះល្វែង ហុក លី |
| 22. | លោក លីម គុន្ធី | ផ្ទះល្វែង លីម គុន្ធី |
| 23. | លោក ឆាយ ហ៊ិរ | ផ្ទះល្វែង ឆាយ ហ៊ិរ |
| 24. | ហ៊ុី មន្តលត្ល់ពេញថ្មី | ខល់មុខទីតាល់ |
| 25. | លោក ឡាង ម៉ាណ៉ី | ផ្ទះល្វែង ឡាង ម៉ាណ៉ី |
| 26. | លោក គីម សុខអេង (ផ្ទះល្វែងTCC) | |
| 27. | លោក ហ្លះ សុខហេង (ហ៊ុី ជេនសៀល) | |
| 28. | ផ្ទះល្វែង គុង សេង | |
| 29. | លោក អ៊ិង ចំរាក់សេង | ផ្ទះល្វែង ST |

# ឧបសម្ព័ន្ធទី១០


RUSSEY KEO DISTRICT
RUSSEY KEO DISTRICT